សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២២

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ណៃ រីណែត**
**ថៅ គីមលី**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ហេង ច័ន្ទបូលីន**

ថ្នាក់បរិញ្ញាបត្រ គណនេយ្យ
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ការបោះផ្សាយលក់មូលបត្រជាសាធារណៈ
# លើកដំបូងនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែ មីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ណៃ រីណែត**

**ថៅ គីមលី**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ណៃ រីណែត** និង **ថៅ គីមលី** ជានិស្សិតថ្នាក់បរិញ្ញាបត្រគណនេយ្យ ឆ្នាំទី៤ ជំនាន់ទី១៧ ក្រុម A4C2 ឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើកិច្ចការសិក្សាស្រាវជ្រាវក្រោមប្រធានបទ "ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅកម្ពុជា" សូមថ្លែងអំណរគុណ និងគារវកិច្ចយ៉ាងជ្រាលជ្រៅចំពោះ៖

- **លោកឪពុក** និង**អ្នកម្ដាយ** ជាអ្នកមានគុណជាទីស្រលាញ់ ដែលបានផ្ដល់កំណើត ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ និងជួយទំនុកបម្រុង ឧបត្ថម្ភគាំពារសព្វគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និងហិរញ្ញវត្ថុ ព្រមទាំងអប់រំកូន ដោយក្ដីស្រឡាញ់ មេត្តា និងករុណាតាំងពីកុមារភាពរហូតមកដល់ពេលនេះ ដោយបានតស៊ូ ជំនះ នូវរាល់ឧបសគ្គគ្រប់បែបយ៉ាង។
- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គ្រប់មហាវិទ្យាល័យ លោក លោកស្រីប្រធាន អនុប្រធាន គ្រប់ដេប៉ាតឺម៉ង់ លោក លោកស្រីប្រធាន អនុប្រធានការិយាល័យ លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ជាដំបូន្មានល្អៗ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនយើងខ្ញុំ ដោយយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត។
- លោកស្រីសាស្ត្រាចារ្យ **ហេង ច័ន្ទបូលីន** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្ហាញ ផ្ដល់នូវដំបូន្មាន និងណែនាំវិធីសាស្ត្រ ក៏ដូចជាយោបល់ល្អៗ ក្នុងការណែនាំយើងខ្ញុំសរសេរ និងរៀបចំសារណាបញ្ចប់ការសិក្សាមួយនេះ ឲ្យមានភាពល្អប្រសើរ និងមានខ្លឹមសារ អត្ថន័យល្អគ្រប់គ្រាន់។
- មិត្តរួមថ្នាក់ A4C2 ក៏ដូចជាមិត្តនិស្សិតរួមជំនាន់ដែលបានផ្ដល់គំនិត យោបល់ព្រមទាំងការលើកទឹកចិត្តដល់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរ លោកអ្នកមានគុណទាំងពីរ លោក លោកស្រី សាស្ត្រាចារ្យ ក៏ដូចជាមិត្តរួមជំនាន់ទាំងអស់សូមឲ្យមានសុខភាពល្អ ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារទាំងអស់។

# អារម្ភកថា

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រគណនេយ្យ ឆ្នាំទី៤ ជំនាន់ទី ១៧ ក្រុម A4C2 ឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើការស្រាវជ្រាវ និងចងក្រងកិច្ចការស្រាវជ្រាវនេះឡើង ក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹង និងព្រមទាំងមូលដ្ឋានគ្រឹះសំខាន់ៗ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជា ទាំងទ្រឹស្ដី និងការអនុវត្តជាក់ស្ដែងដែលបានឆ្លងកាត់ តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមកនេះ។

ខ្លឹមសារសំខាន់នៅក្នុងកិច្ចការស្រាវជ្រាវដែលស្ដីអំពី ″ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅកម្ពុជា″ នេះ គឺមានគោលបំណងជួយឲ្យសិស្ស និស្សិត ពង្រីកចំណេះដឹង និងស្វែងយល់បន្ថែមឲ្យកាន់តែច្បាស់ទៅលើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈលើកដំបូងនៅកម្ពុជា។ ការស្រាវជ្រាវនេះ នឹងផ្ដល់ជាជំនួយមួយដ៏សំខាន់សម្រាប់បង្កើនចំណេះដឹងមួយកម្រិតទៀតសម្រាប់មិត្តអ្នកអានទាំងអស់ឲ្យកាន់តែយល់ច្បាស់ ក៏ដូចជាបង្កើនចំណេះដឹងបន្ថែម និងជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្ត។

យើងខ្ញុំក៏សុំអភ័យទោសទុកជាមុនផងដែរ នូវរាល់កំហុសឆ្គងដែលកើតមានឡើង ដោយអចេតនាទាំងអត្ថន័យ ខ្លឹមសារ និងអក្ខរាវិរុទ្ធ ក្នុងកិច្ចការស្រាវជ្រាវនេះដែរ បើទោះបីជាយើងខ្ញុំ បានពិនិត្យយ៉ាងល្អិតល្អន់ ម្ដងជាពីរដងរួចហើយយ៉ាងណាក៏ដោយ ក៏ប្រាកដជានៅមានចំណុចខ្វះខាត ដែលកើតឡើងដោយអចេតនាដែរ។ យើងខ្ញុំរីករាយ នឹងទទួលយកនូវរាល់មតិរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងមហាជនគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីធ្វើឲ្យសារណានេះកាន់តែមានភាពល្អប្រសើរជាងមុនមួយកម្រិតថែមទៀត។

ជាចុងក្រោយ យើងខ្ញុំសូមគោរពអរគុណដល់លោកគ្រូ អ្នកគ្រូ មិត្តនិស្សិតអ្នកអានទាំងអស់ និងសូមឲ្យលោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិត ទទួលជោគជ័យក្នុងការបំពេញភារកិច្ចការងារ និងមានសុខភាពល្អ។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ......... vi

បញ្ជីតារាង ......... vii

បញ្ជីរូបភាព ......... ix

បញ្ជីក្រាហ្វិច ......... x


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ......... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ......... ១

៣. គោលបំណងនៃការស្រាវជ្រាវ ......... ២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ......... ៣

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ......... ៣

៦. សារៈសំខាន់ការស្រាវជ្រាវ ......... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......... ៤


## ជំពូកទី១

## រំលឹកទ្រឹស្តី


១.១. មូលបត្រ ......... ៦

១.១.១. និយមន័យមូលបត្រ ......... ៦

១.១.២. ប្រភេទនៃមូលបត្រ ......... ៦

១.១.២.១. មូលបត្រកម្មសិទ្ធិ ......... ៦

១.១.២.២. មូលបត្របំណុល ......... ៧

១.១.២.៣. ឧបករណ៍និស្សន្ទ ......... ៨

១.២. ទីផ្សារមូលត្រ ......... ៨

១.២.១. និយមន័យទីផ្សារមូលបត្រ ......... ៨

១.២.២. ប្រវត្តិទីផ្សារមូលបត្រ ......... ៩

១.២.៣. ប្រភេទទីផ្សារមូលបត្រ ......... ១០

១.២.៣.១. ទីផ្សារដំបូង ......... ១០

១.២.៣.២. ទីផ្សារបន្ទាប់ ..................................................................................................... ១០
១.៣. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ............................................................ ១១
១.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ .......................................................................................... ១១
១.៤.១. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន ...................................................................... ១១
១.៤.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ .............................................................. ១២
១.៤.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ ................................................................... ១៤

## ជំពូកទី២

## ស្ថានភាពទូទៅនៃនិយ័តករមូលបត្រ និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

២.១. ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា ............................................................................. ១៥
២.១.១. ប្រវត្តិរបស់និយ័តករមូលបត្រកម្ពុជា .................................................................................... ១៥
២.១.២. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា ............................................................................... ១៦
២.១.៣. រូបសញ្ញា អត្ថន័យនៃរូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា ............................................................. ១៧
២.១.៤. ចក្ខុវិស័យ និងបេសកកម្ម .................................................................................................. ១៨
២.១.៤.១. ចក្ខុវិស័យ ..................................................................................................................... ១៨
២.១.៤.២. បេសកកម្ម ..................................................................................................................... ១៩
២.១.៥. មុខងារនិយ័តករមូលបត្រកម្ពុជា ........................................................................................... ១៩
២.១.៦. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា ................................................................................. ២០
២.១.៧. គោលដៅ និងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា .............................................................. ២០
២.១.៨. អង្គការចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា ........................................................................... ២១
២.១.៨.១. រចនាសម្ព័ន្ធចាត់តាំង ........................................................................................................ ២១
២.១.៨.២. នាយកដ្ឋានរបស់និយ័តករមូលបត្រកម្ពុជា ................................................................................. ២១
២.១.៨.៣. អង្គភាពសវនកម្មផ្ទៃក្នុងនៃនិយ័តករមូលបត្រកម្ពុជា ...................................................................... ២២
២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ............................................................................................... ២២
២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................................................ ២២
២.២.២. ចក្ខុវិស័យ ........................................................................................................................ ២៣
២.២.៣. បេសកកម្ម ........................................................................................................................ ២៣
២.២.៤. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា ..................................................................... ២៣

២.២.៥. ព័ត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ....................................២៤
២.២.៦. រចនាសម្ព័ន្ធនៃការគ្រប់គ្រង....................................................................................២៥
២.៣. តួអង្គពាក់ព័ន្ធក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈដំបូង ..............................២៥
២.៣.១. និយ័តករមូលបត្រកម្ពុជា .........................................................................................២៥
២.៣.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា....................................................................................២៥
២.៣.៣. ក្រុមហ៊ុនមូលបត្រ ...................................................................................................២៦
២.៣.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ..........................................................................៣០
២.៣.៤.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)...................................................................៣០
២.៣.៤.២. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល(GTI).........................................................៣១
២.៣.៤.៣. កំពង់ផែស្វយ័តក្រុងភ្នំពេញ(PPAP)........................................................................ ៣២
២.៣.៤.៤. ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) ................................................... ៣៣
២.៣.៤.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ(PAS) ......................................................................៣៤
២.៣.៤.៦. ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC)........................................................................៣៥
២.៣.៤.៧. ក្រុមហ៊ុន ផេកចិក (ខេមបូឌា) ម.ក.(PEPC)...............................................................៣៦
២.៣.៤.៨. ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក. (DBDE) ...................................................................... ៣៧
២.៣.៥. ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុល..........................................................................៣៨
២.៣.៥.១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត ..........................................................៣៨
២.៣.៥.២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូរអិលស៊ី (ខេមបូឌា) ភីអិលស៊ី ........................................៣៩
២.៣.៥.៣. ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់.................................................................................. ៤១
២.៣.៥.៤. ធនាគារភ្នំពេញពាណិជ្ជ “ភីភីស៊ីប៊ែង” ម.ក ...............................................................៤២
២.៣.៥.៥. អ អិម អេ (ខេមបូឌា) ម.ក......................................................................................៤៣
២.៣.៥.៦. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ....................................................................... ៤៤
២.៣.៥.៧. ក្រុមហ៊ុន តែលកូចេក ............................................................................................ ៤៥
២.៣.៦. ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ.............................................................. ៤៦
២.៣.៧. ភ្នាក់ងារបញ្ជិកាមូលបត្រ..........................................................................................៤៧
២.៣.៨. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ.....................................................................................៤៧
២.៣.៩. ភ្នាក់ងារទូទាត់ ........................................................................................................៤៧

២.៣.១០. ក្រុមហ៊ុន និងការិយាល័យមេធាវីផ្តល់សេវាផ្នែកច្បាប់ក្នុងវិស័យមូលបត្រ ........................ ៤៨
២.៣.១១. ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ ........................................................ ៤៨
២.៣.១២. ក្រុមហ៊ុនផ្តល់សេវាកម្មវាយតម្លៃនៅក្នុងវិស័យមូលបត្រ ............................................ ៤៩
២.៣.១៣. ក្រុមហ៊ុនផ្តល់សេវាបកប្រែ ....................................................................................... ៤៩
២.៣.១៤. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ........................................................................ ៤៩
២.៣.១៥. ភ្នាក់ងារវាយតម្លៃលទ្ធភាពសង ................................................................................. ៥០

## ជំពូកទី៣

## ការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារដំបូងនៅកម្ពុជា

៣.១. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ............................................ ៥១
៣.២. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង .............................................. ៥២
៣.២.១.លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនិងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ........................................................................................... ៥២
៣.២.២. ការរៀបចំរបស់ក្រុមហ៊ុន ដើម្បីទទួលបានហិរញ្ញប្បទានពីទីផ្សារមូលបត្រ ............................ ៥៤
៣.២.៣. ការរៀបចំឯកសារផ្តល់ព័ត៌មាន ..................................................................................... ៥៦
៣.២.៤.ឯកសារភ្ជាប់ដើម្បីដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនិងចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា ........................................................................ ៥៧
៣.២.៤.១. ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ............................ ៥៧
៣.២.៤.២. ពាក្យស្នើចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា .......................................... ៥៨
៣.២.៥. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈការធ្វើប៊ុកបៀលឌីង (Book Building) ........................ ៥៩
៣.២.៦. ការធ្វើបរិវិសកកម្មមូលបត្រ (Subscription) ................................................................. ៦០
៣.២.៧. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ........................ ៦១
៣.២.៧.១. ថ្លៃសេវាលើក្រុមការងារ IPO ................................................................................ ៦១
៣.២.៧.២. ថ្លៃសេវាលើការដាក់ពាក្យស្នើសុំ .......................................................................... ៦១
៣.២.៧.៣. ថ្លៃសេវាផ្សេងៗ .................................................................................................. ៦៣
៣.៣. ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈលើកដំបូង ............................................... ៦៣
៣.៣.១. ប្រភេទមូលបត្របំណុលដែលធ្វើសំណើលក់ ..................................................................... ៦៣
៣.៣.២. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ........................ ៦៤

៣.៣.២.១. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណធម្មតា ................................ ៦៤
៣.៣.២.២. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា........................ ៦៤
៣.៣.២.៣.លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា.................... ៦៥
៣.៣.៣. ឯកសារប្រើសម្រាប់ស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ...................... ៦៥
៣.៣.៤. ឯកសារផ្តល់ព័ត៌មាន.........................................................................................៦៧
៣.៣.៥. ការធ្វើបរិវិសកម្ម ............................................................................................... ៦៨
៣.៣.៦. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ.................... ៦៨
៣.៤. ទិដ្ឋភាពទូទៅនៃការបោះផ្សាយលក់មូលបត្រ..................................................................... ៦៩
៣.៤.១. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ........................................................................ ៦៩
៣.៤.១.១. ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ................................................... ៦៩
៣.៤.១.២.តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនិងចំនួនហ៊ុនដែលបានបោះផ្សាយ......................................................................................................................៧០
៣.៤.២. ការបោះផ្សាយលក់មូលបត្របំណុល.........................................................................៧១
៣.៤.២.១. ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ....................................................៧១
៣.៤.២.២.ចំនួនបោះផ្សាយលក់មូលបត្របំណុលជា(ឯកតា)អត្រាគូប៉ុងប្រចាំឆ្នាំរយៈពេលឥណប្រតិទាន ........................................................................................................... ៧៣

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ....................................................................................................៧៥
២. ការផ្តល់អនុសាសន៍ ..................................................................................................៧៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ម.ក៖ គណៈកម្មការមូលបត្រកម្ពុជា

ន.ម.ក៖ និយ័តករមូលបត្រកម្ពុជា

ផ.ម.ក៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ABA៖ Advanced Bank of Asia Limited (ធនាគារវឌ្ឍនៈអាស៊ីចំកាត់)

ABC៖ Aceleda Bank Plc. (ធនាគារអេស៊ីលីដា)

CSX៖ Cambodia Securities Exchange (ផ្សារមូលបត្រកម្ពុជា ឬ ផ.ម.ក.)

GTI៖ Grand Twin International (ក្រុមហ៊ុន ហ្គ្រេនធ្វីនអ៊ីនធើណេសិនណាល)

HKL៖ Hattha Kaksekar Limited (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកសិករ លីមីតធីត)

IPO៖ Initial Public Offering (ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង)

LOLC៖ LOLC (Cambodia) Plc. (គ្រឹះស្ថានហិរញ្ញវត្ថុ អិលអូអិលស៊ី ភីអិលស៊ី)

PAS៖ Port Autonome De Sihanoukville (កំពង់ផែស្វយ័តក្រុងព្រះសីហនុ ឬ ក.ស.ស.)

PEPC៖ PESTECH (ផេសថិក (ខេមបូឌា) ម.ក

PPAP៖ Phnom Penh Autonomous Port (កំពង់ផែស្វយ័តក្រុងភ្នំពេញ ឬ ក.ស.ភ.)

PPCB៖ Phnom Penh Commercial Bank Plc. (ធនាគារភ្នំពេញពាណិជ្ជ ម.ក)

PPSEZ៖ Phnom Penh Special Economic Zone (ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី)

PRA៖ PRASAC Microfinance Institution Plc. (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក)

PWSA៖ Phnom Penh Water Supply Authority (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឬ រ.ទ.ស.ភ.)

RMA៖ RMA Cambodia Plc. (ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក)

SECC៖ Securities and Exchange Commission of Cambodia (គណៈកម្មការមូលបត្រកម្ពុជា)

TCT៖ Telecotech AN Ezecom Company (ក្រុមហ៊ុនតេលេកូថេក)

# បញ្ជីតារាង

ទំព័រ

តារាង២.១៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPWSA...........៣១
តារាង២.២៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងGTI .............. ៣២
តារាង២.៣៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPPAP........... ៣៣
តារាង២.៤៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPPSEZ..........៣៤
តារាង២.៥.លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPAS ................៣៥
តារាង២.៦.លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងABC................៣៦
តារាង២.៧.លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPEPC ............ ៣៧
តារាង២.៨.លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងDBDE .............៣៨
តារាង២.៩. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ ហត្ថាកសិករ...............................៣៩
តារាង២.១០. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ អិល អូ អិល ស៊ី........................ ៤០
តារាង២.១១. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់......... ៤១
តារាង២.១២. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី១របស់ ភីភីស៊ីប៊ែង...................៤២
តារាង២.១៣. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២របស់ ភីភីស៊ីប៊ែង ..................៤៣
តារាង២.១៤. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២របស់ អ អិម អេ ................... ៤៤
តារាង២.១៥. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២របស់ ប្រាសាក់ ..................... ៤៥
តារាង២.១៦. លទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២របស់ តែលកូថេក.................. ៤៦
តារាង៣.១. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ .....................៥២
តារាង៣.២. លក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា .................៥៣
តារាង៣.៣. ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក .............. ៦១
តារាង៣.៤៖ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក....................៦២
តារាង៣.៥៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.......................................៦២
តារាង៣.៦៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ ..........................................................៦៣
តារាង៣.៧. ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធ ........................................................ ៦៩
តារាង៣.៨៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈដំបូង និងចំនួនហ៊ុនដែលបាន បោះផ្សាយ
.......................................................................................................................៧០

តារាង៣.៩៖ ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល...................................................... ៧២
តារាង៣.១០. ចំនួនបោះផ្សាយលក់មូលបត្របំណុលជា (ឯកតា) អត្រាគូប៉ុងប្រចាំឆ្នាំ និងរយៈពេលឥណប្រតិទាន ......................................................................................................................... ៧៣

# បញ្ជីរូបភាព

ទំព័រ

រូបភាព២.១. ទីស្នាក់ការនិយ័តករមូលបត្រកម្ពុជា ........ ១៦

រូបភាព២.២. រូបសញ្ញានិយ័តករមូលបត្រកម្ពុជា ........ ១៧

រូបភាព២.៣. ត្រានិយ័តករមូលបត្រកម្ពុជា ........ ១៨

រូបភាព២.៤. រចនាសម្ព័ន្ធចាត់តាំងនិយ័តករមូលបត្រកម្ពុជា ........ ២១

រូបភាព២.៥. ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រ ........ ២៤

រូបភាព២.៦. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ២៥

រូបភាព២.៧. ស្លាកសញ្ញាPWSA ........ ៣០

រូបភាព២.៨. ស្លាកសញ្ញាGTI ........ ៣១

រូបភាព២.៩. ស្លាកសញ្ញាPPAP ........ ៣២

រូបភាព២.១០. ស្លាកសញ្ញាPPSEZ ........ ៣៣

រូបភាព២.១១. ស្លាកសញ្ញាPAS ........ ៣៤

រូបភាព២.១២.ស្លាកសញ្ញាABC ........ ៣៥

រូបភាព២.១៣. ស្លាកសញ្ញាPEPC ........ ៣៦

រូបភាព២.១៤. ស្លាកសញ្ញា DBDE ........ ៣៧

រូបភាព២.១៥. ស្លាកសញ្ញាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត ........ ៣៨

រូបភាព២.១៦. ស្លាកសញ្ញាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូរ អិល ស៊ី (ខេមបូឌា) ភីអិលស៊ី ........ ៣៩

រូបភាព២.១៧. ស្លាកសញ្ញាធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ........ ៤១

រូបភាព២.១៨. ស្លាកសញ្ញាធនាគារភ្នំពេញពាណិជ្ជ ភីភីស៊ីប៊ែង ម.ក ........ ៤២

រូបភាព២.១៩. អ អិម អេ (ខេមបូឌា) ភីអិលស៊ី ........ ៤៣

រូបភាព២.២០. ស្លាកសញ្ញាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ........ ៤៤

រូបភាព២.២១. ស្លាកសញ្ញាក្រុមហ៊ុន តែលកូថេក ........ ៤៥

# បញ្ជីក្រាហ្វិច

ទំព័រ

ក្រាបទី៣.១៖ ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ....................................................៧០

ក្រាបទី៣.២៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និង ចំនួនមូលបត្រ កម្មសិទ្ធិក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង...............................................................៧១

ក្រាបទី៣.៣៖ ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល.................................................... ៧២

ក្រាបទី៣.៤៖ ចំនួនមូលបត្របំណុលដែលបោះផ្សាយ, អត្រាគូប៉ុងប្រចាំឆ្នាំ និង រយៈពេលឥណប្រតិទាន ........................................................................................................................... ៧៣

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាយើងត្រូវបានគេចាត់ទុកថាជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដែលទើបតែបានឆ្លងកាត់នូវសង្គ្រាម ក៏ដូចជាបញ្ហាប្រឈមជាច្រើនទស្សវត្សរ៍រួចមក។ នៅក្នុងពេលបច្ចុប្បន្ននេះដែរ រាជរដ្ឋាភិបាលរបស់យើងបាននឹងកំពុងតែអនុវត្តន៍នូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសមានកំណើនទៅមុខជាលំដាប់រួមជាមួយស្ថេរភាពនៅគ្រប់វិស័យ ក៏ដូចជាមានទំនាក់ទំនងល្អជាមួយបណ្តាប្រទេសនានាទាំងនៅជិត និងឆ្ងាយនៅលើពិភពលោក។ លើសពីនេះទៅទៀត ប្រទេសយើងក៏នៅតែកំពុងខិតខំអភិវឌ្ឍន៍បន្តទៀត ដើម្បីទទួលបានការរីកចម្រើនឲ្យកាន់តែខ្លាំងនៅគ្រប់វិស័យទាំងអស់។ ស្របពេលជាមួយគ្នានេះដែរ យើងក៏សង្កេតឃើញថាមានវិស័យមួយដែលកំពុងមានការរីកចម្រើនគួរឲ្យកត់សម្គាល់នៅកម្ពុជាយើង នោះគឺវិស័យមូលបត្រ។

វិស័យមូលបត្រនៅកម្ពុជា បានដើរតួនាទីជាកម្លាំងចលករដ៏សំខាន់ ក្នុងការជំរុញឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច។ ទីផ្សារមូលបត្រនេះដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កភាពងាយស្រួល ដល់ក្រុមហ៊ុន សហគ្រាស ឬនីតិបុគ្គលទាំងឡាយដែលមានតម្រូវការមូលធន តាមរយៈការបោះផ្សាយលក់មូលបត្រនៅលើទីផ្សារមូលបត្រ។ នៅក្នុងទីផ្សារមូលបត្រនេះ មានឧបករណ៍ហិរញ្ញវត្ថុជាច្រើនត្រូវបានគេយកមកធ្វើការជួញដូរដូចជា មូលបត្របំណុល មូលបត្រកម្មសិទ្ធជាដើម។

សម្រាប់ប្រទេសកម្ពុជាយើង បើទោះបីជាវិស័យនេះមានការចាប់អារម្មណ៍យ៉ាងច្រើនពីបណ្តាមហាជន ឬក៏វិនិយោគិនក៏ដោយ ប៉ុន្តែយើងសង្កេតឃើញថា យើងនៅមានបទពិសោធន៍តិចទាក់ទងនឹងវិស័យមួយនេះ។ ហេតុដូចនេះហើយទើបបានជារដ្ឋាភិបាល បានបង្កើតឲ្យមាននិយ័តករមូលបត្រកម្ពុជាឡើង ដើម្បីដើរតួនាទីយ៉ាងសំខាន់ក្នុងការតាក់តែងច្បាប់ស្តីពីការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រ នីតិវិធីក្នុងការបោះផ្សាយ និងនីតិវិធីក្នុងការជួញដូរមូលបត្រជាដើម ដើម្បីជួយសម្រួលដល់ក្រុមហ៊ុន វិនិយោគិន ក៏ដូចជាធ្វើការផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងដល់សាធារណៈជន តាមរយៈសិក្ខាសាលា ឬតាមរយៈបណ្តាញសង្គមនានា។ តាមរយៈការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកន្លងមក យើងក៏បានសង្កេតឃើញថា វិស័យមូលបត្រនេះ កំពុងតែទទួលបានការចាប់អារម្មណ៍ជាច្រើន ហើយវាបានទាក់ទាញឲ្យមហាជន ចង់ដឹង ចង់ស្គាល់ ជាពិសេសពាក់ព័ន្ធទៅនឹងការបោះផ្សាយមូលបត្រ ក៏ដូចជាការជួញដូរមូលបត្រនៅលើទីផ្សារជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រត្រូវបានចាត់ទុកជាកាតាលីករ ឬជាកម្លាំងចលករមួយរបស់សេដ្ឋកិច្ច ព្រោះវាជាមធ្យោបាយមួយក្នុងការជួយជំរុញឲ្យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើងមានការរីកចម្រើន។ ហេតុនេះហើយការរីកលូតលាស់នៃវិស័យមូលបត្រ គឺជាកត្តាចាំបាច់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីពង្រឹងនូវការប្រកួតប្រជែងសេដ្ឋកិច្ចក្នុងតំបន់ ក៏ដូចជាពិភពលោកផងដែរ។ ដោយឡែកនៅប្រទេសកម្ពុជា ទោះបីជាមានការជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាល ក្នុងការ

ជំរុញនូវវិស័យមូលបត្រក៏ពិតមែន ក៏យើងសង្កេតឃើញថា ចំនួនក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល នៅមានចំនួនតិចតួច និងធនធានមនុស្សក្នុងវិស័យនេះនៅមានកម្រិតនៅឡើយ។ ជាក់ស្តែង ដើម្បីទទួលបានហិរញ្ញប្បទានពីទីផ្សារមូលបត្រ តាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ក្រុមហ៊ុន/សហគ្រាស ត្រូវត្រៀមខ្លួន និងបំពេញនូវលក្ខខណ្ឌមួយចំនួន តាមការតម្រូវរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា ហេតុនេះទាមទារឱ្យក្រុមហ៊ុន/សហគ្រាស និងស្ថាប័នពាក់ព័ន្ធ និងសាធារណៈជនទូទៅ មានចំណេះដឹងទាក់ទងនឹងដំណើរការនៃការបោះផ្សាយលក់មូលបត្រ ក៏ដូចជាផលប្រយោជន៍ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រ និងការជួញដូរមូលបត្រផងដែរ។

ដោយបានមើលឃើញនូវចំណុចខ្វះខាតទាំងនេះ ទើបយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទស្រាវជ្រាវទាក់ទងនឹងវិស័យមូលបត្រនៅប្រទេសកម្ពុជា ជាពិសេសដំណើរការបោះផ្សាយមូលបត្រនៅក្នុងទីផ្សារដំបូង ដើម្បីបកស្រាយឲ្យច្បាស់បន្ថែមទៀត និងដោះស្រាយនូវចម្ងល់របស់ក្រុមហ៊ុន/សហគ្រាស និងស្ថាប័នពាក់ព័ន្ធ និងសាធារណៈជនទូទៅ រួមទាំងវិនិយោគិនដែលមានបំណងចង់វិនិយោគនៅក្នុងវិស័យមូលបត្រនេះ។ ដើម្បីសម្រេចបាននូវគោលបំណងនៃការស្រាវជ្រាវនេះ របាយការណ៍របស់យើងខ្ញុំនឹងឆ្លើយតបនូវសំណួរដូចខាងក្រោម៖

- តើនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជាមានតួនាទីអ្វីខ្លះ?
- តើដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ និងមូលបត្របំណុលជាសាធារណៈលើកដំបូងនៅកម្ពុជា ធ្វើឡើងដោយមានលក្ខណៈដូចម្តេច?
- តើមានលក្ខខណ្ឌ នីតិវិធី និងឯកសារតម្រូវ និងអ្វីខ្លះ ដើម្បីក្រុមហ៊ុន/សហគ្រាស ធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង?
- តើចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធ តម្លៃបោះផ្សាយ និងចំនួនហ៊ុនបោះផ្សាយពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១ និងចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ទំហំបោះផ្សាយ អត្រាគូប៉ុង និងរយៈពេលឥណប្រតិទាន ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២១ យ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ គឺផ្តោតសំខាន់លើប្រធានបទ "ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ និងមូលបត្របំណុលជាសាធារណៈលើកដំបូង" ដែលគោលបំណងចំបងៗនៃការស្រាវជ្រាវនេះអាចសង្ខេបបានដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាពទូទៅ និងតួនាទីរបស់និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រនៅកម្ពុជា
- ស្វែងយល់ពីដំណើរការក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ និងមូលបត្របំណុលជាសាធារណៈលើកដំបូងនៅកម្ពុជា

- ស្វែងយល់ពីលក្ខខណ្ឌ នីតិវិធី ឯកសារតម្រូវ និងថ្លៃសេវា ដើម្បីក្រុមហ៊ុន/សហគ្រាស ធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង
- ស្វែងយល់ពីចំនួនក្រុមហ៊ុនបោះផ្សាយ តម្លៃបោះផ្សាយ និងចំនួនហ៊ុនបោះផ្សាយពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១ និងចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ទំហំបោះផ្សាយ អត្រាគូប៉ុង និងរយៈពេលឥណប្រតិទាន ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២១។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងទីផ្សារមូលបត្រកម្ពុជា មានការបោះផ្សាយ និងជួញដូរទាំងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ក៏ប៉ុន្តែនៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានផ្តោតទៅលើតែដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈលើកដំបូង មកបង្ហាញតែប៉ុណ្ណោះ។ ចំពោះទិន្នន័យដែលយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺចាប់ពីឆ្នាំ ២០១២ រហូតដល់ ឆ្នាំ ២០២១។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការសរសេរសារណាលើប្រធានបទ ស្តីអំពីដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងទីផ្សារដំបូងនៅកម្ពុជានេះ គឺធ្វើតាមវិធីសាស្ត្របែបពណ៌នា ដោយរៀបរាប់ពីលក្ខខណ្ឌ យន្តការ នីតិវិធី ឯកសារតម្រូវ ថ្លៃសេវានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ ចំពោះទិន្នន័យដែលយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ គឺទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យដែលមានស្រាប់ដែលមានប្រភពចេញពី៖

- ច្បាប់ អនុក្រឹត្យ ប្រកាស វិធាន គោលការណ៍ណែនាំ និងបទប្បញ្ញត្តិផ្សេងៗរបស់និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- ឯកសារបោះពុម្ពជាភាសាខ្មែរដែលទាក់ទងនឹងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈលើកដំបូងនៅកម្ពុជា។
- ទិន្នន័យផ្សេងៗដែលមាននៅក្នុងគេហទំព័រផ្លូវការរបស់និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

## ៦. សារៈសំខាន់ការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវអំពី ប្រធានបទដែលទាក់ទងទៅនឹងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ និងមូលបត្របំណុល ជាសាធារណៈលើកដំបូង គឺមានសារៈសំខាន់ និងបានផ្តល់ផលប្រយោជន៍ដូចជា៖

- ចំពោះយើងខ្ញុំផ្ទាល់
  - ➢ ទទួលបានចំណេះដឹងកាន់តែស៊ីជម្រៅទៅលើវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីដែលបានរៀនកន្លងមក។

- បង្កើនចំណេះដឹង ក៏ដូចជាទទួលបានពត៌មាន និងបទពិសោធន៍ថ្មីៗជាច្រើនក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវនេះ។
- អាចយកចំណេះដឹងដែលទទួលបានពីការធ្វើកិច្ចការស្រាវជ្រាវនេះ ទៅអនុវត្តផ្ទាល់ដោយចាប់ផ្តើមធ្វើការវិនិយោគលើវិស័យមូលបត្រនេះ។

- ចំពោះវិស័យមូលបត្រ
  - ផ្តល់ជាការផ្សព្វផ្សាយដល់សាធារណៈជនទូទៅឲ្យបានស្គាល់ និងយល់ដឹងពីដំណើរការបោះផ្សាយលក់មូលបត្រនៅកម្ពុជា។
  - ផ្តល់ជាពត៌មានបន្ថែមសម្រាប់វិនិយោគិនក្នុងការស្វែងយល់ពីវិស័យនេះ។
  - អាចទាក់ទាញវិនិយោគិន ឲ្យងាកមកធ្វើការវិនិយោគក្នុងវិស័យមូលបត្រនេះឲ្យកាន់តែច្រើនឡើង។
  - អាចជួយឲ្យមានការអភិវឌ្ឍន៏ក្នុងវិស័យមូលបត្រនេះជាងមុនបន្ថែមទៀត។
- ចំពោះអ្នកសិក្សាស្រាវជ្រាវ
  - ជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយ ក៏ដូចជាបុគ្គលទូទៅទាំងឡាយ ដែលមានបំណងចង់ស្វែងយល់បន្ថែមអំពីវិស័យមូលបត្រនៅកម្ពុជា។
  - ផ្តល់ជាឯកសារ និងចំណេះដឹងសម្រាប់សាធារណៈជន និងក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចង់ស្វែងយល់ឲ្យកាន់តែច្បាស់ពីដំណើរការ នីតិវិធី និងលក្ខខណ្ឌក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

របាយការណ៍នេះត្រូវបានចែកជា ៣ ជំពូកដូចខាងក្រោម៖

- **សេចក្តីផ្តើម៖** ក្នុងផ្នែកនេះ នឹងបង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ គោលបំណង ទំហំ និងដែនកំណត់ សារៈសំខាន់ និងវិធីសាស្ត្រនៃការស្រាវជ្រាវលើប្រធានបទនេះ។
- **ជំពូកទី១៖ ការរំលឹកទ្រឹស្តី**

  ក្នុងជំពូកនេះ នឹងធ្វើការបង្ហាញអំពីការលើកឡើងនូវទ្រឹស្តីផ្សេងៗ ដែលទាក់ទងនឹងប្រធានបទដូចជានិយមន័យមូលបត្រ ប្រភេទនៃមូលបត្រ ប្រវត្តិ និងប្រភេទនៃទីផ្សារមូលបត្រ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន ចំពោះក្រុមហ៊ុន បោះផ្សាយ និងចំពោះសេដ្ឋកិច្ច។
- **ជំពូកទី២៖ ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

  ក្នុងជំពូកនេះ នឹងធ្វើការបង្ហាញអំពីប្រវត្តិ ចក្ខុវិស័យ បេសកកម្ម នាមករណ៍ និងផ្លាកសញ្ញារបស់និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រ ព្រមទាំងតួអង្គពាក់ព័ន្ធក្នុងដំណើរការបោះផ្សាយ។

- **ជំពូកទី៣៖ ការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងទីផ្សារដំបូង**

  ក្នុងជំពូកនេះ នឹងធ្វើការបង្ហាញអំពីលក្ខខណ្ឌ នីតិវិធី ឯកសារតម្រូវ និងថ្លៃសេវា ទាក់ទងនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងទីផ្សារដំបូងនៅកម្ពុជា និងចំនួនក្រុមហ៊ុនបោះផ្សាយ តម្លៃបោះផ្សាយ និងចំនួនហ៊ុនបោះផ្សាយពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១ និងចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ទំហំបោះផ្សាយ អត្រាគូប៉ុង និងរយៈពេលឥណប្រតិទាន ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២១។

- **សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

## រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. មូលបត្រ

### ១.១.១. និយមន័យមូលបត្រ

មូលបត្រ គឺជាឧបករណ៍ហិរញ្ញវត្ថុមួយប្រភេទ តែមានលក្ខណៈប្លែកពីគេ និងតម្លៃរបស់វាមិនមានទំនាក់ទំនងទៅនឹងទ្រង់ទ្រាយ ឬរូបរាងរបស់វាឡើយ ប៉ុន្តែវាអាស្រ័យទៅនឹងសិទ្ធិកាន់កាប់នូវផលប្រយោជន៍នាពេលអនាគត និងមិនមានតម្លៃប្រើប្រាស់ ដូចជា ម៉ូតូ រថយន្ត ដី....នោះទេ។[1]

តែបើយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម "មូលបត្រ ជាគំរូបណ្ណដែលអាចដោះដូរបានជាសាធារណៈ ឬលើទីផ្សារមូលបត្រ"។ មូលបត្រ ជាភាគហ៊ុនដែលអាចជាចលនទ្រព្យរូបិយ ឬអរូបិយ។ សព្វថ្ងៃនេះនៅកម្ពុជា មូលបត្រមានទម្រង់ជាអរូបិយ ដែលបានរក្សាទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រ (CSD)។

❖ **ចំណុចពិសេសមូលបត្រនៅក្នុងទីផ្សារមូលបត្រ**

មូលបត្រ នៅក្នុងទីផ្សារមូលបត្រមានចំណុចពិសេសដូចជា[2]៖

- គឺជាបណ្ណាក្រដាសបញ្ជាក់ពីតម្លៃទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ
- គឺជាឧបករណ៍ហិរញ្ញវត្ថុរយៈពេលមធ្យម និងវែង
- ត្រូវបានការពារពីច្បាប់មូលបត្រ
- ត្រូវបានអនុញ្ញាតដោះដូរផ្ទេរកម្មសិទ្ធិនៅលើទីផ្សារមូលបត្រ មានន័យថា Liquidity ខ្ពស់។

### ១.១.២. ប្រភេទនៃមូលបត្រ

#### ១.១.២.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីកៀរគរមូលនិធិពីសាធារណៈជន ហើយមានសិទ្ធិក្នុងការទទួលបានភាគលាភនៅក្នុងអង្គភាពមួយ។[3] វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឲ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិកគឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួលនូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបាន តាមរយៈភាគលាភដែល

[1] សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ទំព័រ ៣៤-៣៥
[2] សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ទំព័រ ៣៥-៣៦
[3] បៀន សាំង (២០១១) មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ ទំព័រ ៣៥-៣៦

ភាគហ៊ុនិកបានទទួល និងតាមរយៈថ្លៃភាគហ៊ុនដែលបានដាក់ថ្លៃនៅលើទីផ្សារ។ មូលបត្រកម្មសិទ្ធិ ចែកចេញជា ២ប្រភេទគឺៈ[4]

**ក. ភាគហ៊ុនធម្មតា**

ភាគហ៊ុនធម្មតាគឺជាភាគហ៊ុនដែលមានការលើកទឹកចិត្ត ដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។

**ខ. ភាគហ៊ុនបុរិមា**

ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ ភាពខុសគ្នារវាងភាគហ៊ុនបុរិមា និងភាគហ៊ុនធម្មតា គឺ អ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា។

**១.១.២.២. មូលបត្របំណុល**

សញ្ញាបណ្ណ គឺជាប្រភេទមូលបត្របំណុល ដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានក្រុមហ៊ុនសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុល មានកាតព្វកិច្ចបង់ឱ្យវិនិយោគិន នូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើម នៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "ឥណប្រតិទាន"។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុនឬអង្គភាពមួយ អាចបោះផ្សាយសញ្ញាបណ្ណទៅឲ្យវិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ បន្តប្រតិបត្តិការក្រុមហ៊ុន ឬដើម្បីទូទាត់បំណុល។

លក្ខណៈខុសគ្នាចម្បងមួយរវាងភាគហ៊ុន និងសញ្ញាបណ្ណ គឺថាសញ្ញាបណ្ណតំណាងឱ្យភាពជាម្ចាស់បំណុល រីឯភាគហ៊ុនតំណាងឱ្យភាពជាម្ចាស់កម្មសិទ្ធិនៃក្រុមហ៊ុនមួយ។ ថ្លៃភាគហ៊ុនអាចកើនឡើងយ៉ាងឆាប់រហ័ស ប្រសិនបើក្រុមហ៊ុននោះមានការរីកចម្រើន និងមានប្រាក់ចំណេញច្រើន។ ផ្ទុយទៅវិញ សញ្ញាបណ្ណធ្វើការទូទាត់តែការប្រាក់ដែលបានកំណត់ជាមុន ហើយថ្លៃរបស់វាប្រែប្រួល នៅក្នុងដែនដែលកំណត់ដោយអត្រាការប្រាក់ពោល គឺមិនមែនកំណត់ដោយប្រាក់ចំណេញរបស់ក្រុមហ៊ុននោះឡើយ។

---

[4] http://www.csx.com.kh/kh/product/equities.jsp?MNCD=4020 (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

បច្ចុប្បន្នមានតែប្រភេទសញ្ញាបណ្ណសាជីវកម្មមួយប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនៅ ផ.ម.ក ដោយសារតែមិនទាន់មាន សញ្ញាបណ្ណរដ្ឋ។ សញ្ញាបណ្ណសាជីវកម្ម ជាប្រភេទមួយនៃមូលបត្របំណុល ដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈចេញដោយ គ.ម.ក. សញ្ញាបណ្ណសាជីវកម្មអាចចែកចេញជា៖

**១. សញ្ញាបណ្ណធម្មតា ( Plain Vanilla Bond)** សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុន នៅកាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រលប់ (Call Option) ឬ សិទ្ធិលក់ (Put Option) និងមិនមានការធានា។

**២. សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond)** សំដៅដល់សញ្ញាបណ្ណដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើម នឹងត្រូវបានទូទាត់សងដោយភាគីទីបី ដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជាអសាធនភាព ឬក្ស័យធន។

**៣. សញ្ញាបណ្ណមានវត្ថុធានា (Secured Bond)** សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែមូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។[5]

#### ១.១.២.៣. ឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឲ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើប្រាស់សិទ្ធិនេះក៏ដោយ។[6]

## ១.២. ទីផ្សារមូលបត្រ

### ១.២.១. និយមន័យទីផ្សារមូលបត្រ

ផ្សារមូលបត្រជាកន្លែងដែលមូលបត្រ ដូចជាភាគហ៊ុន និងសញ្ញាបណ្ណត្រូវបានទិញ និងលក់ដោយវិនិយោគិនផ្សេងៗ រួមទាំងជាតិ និង អន្តរជាតិ។[7] យើងក៏អាចនិយាយបានថា ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ។[8]

[5] http://www.csx.com.kh/kh/product/bond.jsp?MNCD=4040 (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

[6] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន សន្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ (២០០៧) ទំព័រ ៩

[7] http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

[8] ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា ទំព័រ ៣៤

### ១.២.២.ប្រវត្តិទីផ្សារមូលបត្រ

វាមានឯកសារជាច្រើនស្តីអំពី ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ ដែលជាក់ស្តែងទីផ្សារភាគហ៊ុនមានតាំងពីយូរយារណាស់មកហើយ ប៉ុន្តែមានប្រទេសជាច្រើននៅតែប្រើប្រាស់ពាក្យ "**ទីផ្សារភាគហ៊ុន**"។ ទស្សនៈសម័យទំនើប ស្តីពីការបង្កើតទីផ្សារមូលបត្រ បានចាប់ផ្តើមតាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុន បានផ្តើមនៅពេលបណ្តាប្រទេសនៅទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតមានដូចជា ហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុប មានបំណងចាប់ផ្តើមអាជីវកម្មទំហំធំ ដែលទាមទារឲ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់មានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់ សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំបានតែម្នាក់ឯងនោះទេ។ ជាលទ្ធផល វិនិយោគិនបានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងសហកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួន នៅក្នុងអាជីវកម្មមួយដែលមានទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុន ដែលមានដើមកំណើតនៅប្រទេសហូឡង់បានក្លាយជាគំរូអាជីវកម្មមួយ សម្រាប់អាជីវកម្មមួយដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ ។ នៅក្នុងឆ្នាំ ១៦០២ ក្រុមហ៊ុនឌឺ ឌាចហ៍ អីសឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុន មានភាពងាយស្រួលក្នុងការទិញលក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួនជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។

គំនិតនេះទទួលបានជោគជ័យ ដោយការលក់ភាគហ៊ុនបានរីករាលដាល ដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀតដូចជា ប្រទេសព័រទុយហ្គាល អេស្ប៉ាញ និងបារាំង។ នៅទីបំផុតការអនុវត្តគំនិតនេះ ក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដ៏ទៃទៀត ក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្តើមប្រើប្រាស់ការលក់ភាគហ៊ុនជាវិធីមួយ ដើម្បីប្រមូលមូលធនសម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនៃមូលធននេះបានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍន៍នៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឲ្យមានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផលពាណិជ្ជករភាគហ៊ុន បានសម្រេចចិត្តទៅជួបគ្នា នៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមកហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ ១៧៧៣។

ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្តើមនៅទីក្រុងភីឡាដែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០។[9]

[9] គណៈកម្មការមូលបត្រកម្ពុជា ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយលេខ២ ខែមករា ឆ្នាំ២០១៧ ទំព័រ ១២

### ១.២.៣. ប្រភេទទីផ្សារមូលបត្រ

ជាទូទៅ ទីផ្សារមូលបត្រត្រូវបានបែងចែកជាពីរ គឺទីផ្សារដំបូង និងទីផ្សារបន្ទាប់។

#### ១.២.៣.១. ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាទីផ្សារទ្រព្យសកម្ម ដែលនៅទីនោះមូលបត្រត្រូវបានបោះផ្សាយ និងលក់ជាលើកដំបូងតាម រយៈការធ្វើសំណើទិញ ឬដំណើរការដេញថ្លៃ។[10] ទីផ្សារដំបូង គឺជាទីផ្សារសម្រាប់ការជួញដូរមូលបត្ររវាងវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនអាចកៀរគរមូលធន ឬទទួលបានហិរញ្ញប្បទានបន្ថែម សម្រាប់បន្តការវិនិយោគ ឬពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈដល់វិនិយោគិន។ នៅក្នុងន័យនេះ ដើម្បីទិញមូលបត្រពីទីផ្សារដំបូង វិនិយោគិនត្រូវធ្វើការបញ្ជាទិញមូលបត្រដោយផ្ទាល់ ពីក្រុមហ៊ុនបោះផ្សាយនៅក្នុងដំណាក់កាលប៉ុកបៀលឌីង (Book building) ឬការស្នាបស្ទង់ថ្លៃ និង/ឬការធ្វើបរិវិសកម្ម (subscription) ឬការចុះឈ្មោះទិញ។ បន្ថែមពីនេះ លំហូរសាច់ប្រាក់នៅក្នុងទីផ្សារដំបូង គឺចេញពីវិនិយោគិន ទៅកាន់ក្រុមហ៊ុនបោះផ្សាយ ហើយវិនិយោគិនដែលបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយនឹងក្លាយជាភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយនោះ។[11]

#### ១.២.៣.២. ទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់ គឺជាទីផ្សារដែលធ្វើការទិញ-លក់មូលបត្រ ដែលបានបោះផ្សាយលក់ជាសាធារណៈរួចហើយ។ វិនិយោគិនដែលបានទិញមូលបត្រនៅក្នុងទីផ្សារដំបូង អាចលក់មូលបត្រនោះវិញបាននៅក្នុងទីផ្សារបន្ទាប់។ ទីផ្សារបន្ទាប់ គឺជាទីផ្សារសម្រាប់ជួញដូរមូលបត្ររវាងវិនិយោគិន និងវិនិយោគិន។ មានន័យថា រាល់សកម្មភាពទិញ-លក់មូលបត្រ ធ្វើឡើងតែរវាងវិនិយោគិន (អ្នកទិញដែលមានសាច់ប្រាក់) និងវិនិយោគិន (អ្នកលក់ដែលមានមូលបត្រ) តាមរយៈក្រុមហ៊ុនមូលបត្រប៉ុណ្ណោះ។ ចំពោះអ្នកទិញទទួលបានមូលបត្រនឹងក្លាយជាភាគហ៊ុនិកថ្មី ចំណែកឯអ្នកលក់ទទួលបានសាច់ប្រាក់ ហើយវាមិនជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយនោះទេ ឬមានន័យថា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ មិនទទួលបានផលប្រយោជន៍ដោយផ្ទាល់ ពីការជួញដូរលើទីផ្សារនេះទេ។[12]

---

[10] ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា ទំព័រ ១៧៧

[11] http://tinyurl.com/22n5veux (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

[12] http://tinyurl.com/22n5veux (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

នៅពេលបច្ចុប្បន្ននេះ ទីផ្សារបន្ទាប់ត្រូវបានបែងចែកជាពីរគឺ៖

- ទីផ្សារមូលបត្រ (Organized Exchange)៖ សំដៅលើការជួញដូរមូលបត្រ តាមរយៈទីផ្សារមូលបត្រ ដែលមានទីកន្លែងជួញដូរជាក់លាក់មួយ មានវិធានទីផ្សារ និងមានប្រព័ន្ធជួញដូរ ដើម្បីគ្រប់គ្រងដំណើរការជួញដូរ។
- ទីផ្សារមូលបត្រក្រៅប្រព័ន្ធ (Over-the-counter - OTC)៖ សំដៅលើការជួញដូរមូលបត្រក្រៅប្រព័ន្ធទីផ្សារមូលបត្រ ដែលពុំមានទីកន្លែងជួញដូរជាក់លាក់ និងមិនផ្លូវការនោះទេ។ វិនិយោគិនអាចជួញដូរមូលបត្រ ដោយការចរចារតាមរយៈទូរស័ព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ។ ភាគច្រើននៃទីផ្សារនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ជាអ្នកដាក់នូវការកំណត់ថ្លៃទិញ-លក់ជូនអតិថិជន និងក្រុមហ៊ុនពាណិជ្ជករដទៃទៀត។ បច្ចុប្បន្ននៅប្រទេសកម្ពុជាយើង មានតែទីផ្សារមូលបត្រ (Organized Exchange) ដែលដំណើរការពុំមានទីផ្សារមូលបត្រក្រៅប្រព័ន្ធ OTC នោះទេ។[13]

## ១.៣. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។[14]

## ១.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

### ១.៤.១.អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន

វិស័យមូលបត្រ ជាវិស័យមួយដែលទទួលបានការចាប់អារម្មណ៍ និងកំពុងទទួលបានភាពពេញនិយមពីប្រជាជនខ្មែរ ក៏ដូចជាវិនិយោគិនទូទៅនៅទូទាំងសកលលោក។ ហេតុផលដែលជំរុញឲ្យវិស័យមូលបត្រនេះ អាចទទួលបាននូវការគាំទ្រ និងការចាប់អារម្មណ៍ជាច្រើននៅក្នុងការវិនិយោគ ក៏ព្រោះតែវិស័យនេះបានផ្តល់ជាអត្ថប្រយោជន៍ផ្សេងៗ ជាច្រើនពីការជួញដូរមូលបត្រនេះ ដែលអត្ថប្រយោជន៍ទាំងនេះរួមមានដូចជា៖

**ក. ឱកាសវិនិយោគ និងប្រាក់ចំណេញ៖** ការកាន់កាប់ភាគហ៊ុនផ្តល់ឲ្យវិនិយោគិននូវឱកាសដើម្បីចូលរួមក្នុងអាជីវកម្មដោយមិនចាំបាច់មានជំនាញ និងបទពិសោធន៍ជាក់លាក់ ឬការគ្រប់គ្រងដោយផ្ទាល់នោះទេ។ ទន្ទឹមនឹងនេះ ការកាន់កាប់ភាគហ៊ុនអាចផ្តល់ផលចំណេញខ្ពស់ ដែលបានមកពីការបែងចែកភាគលាភ និងការចំណេញពីការជួញដូរភាគហ៊ុន។

[13] ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា ទំព័រ ៣-៥

[14] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ប្រការ ២

**ខ. ផ្តល់លទ្ធភាពសម្រាប់វិនិយោគិនតូចៗ៖** ទីផ្សារភាគហ៊ុនអនុញ្ញាតឲ្យនិយោគិន ដែលមានប្រាក់សមល្មម អាចវិនិយោគលើក្រុមហ៊ុនធំ ហើយទទួលបានផលចំណេញមកវិញដូចទៅនឹងបុគ្គល ឬស្ថាប័នដែលមានប្រាក់ច្រើន ដោយផ្អែកលើចំនួនភាគហ៊ុនដែលពួកគេកាន់កាប់។

**គ. ការធ្វើពិពិធកម្មការវិនិយោគ៖** ក្រៅពីប្រភពចំណូលសំខាន់ៗ របស់អ្នកដូចជាប្រាក់ខែ ឬប្រាក់ចំណេញពីអាជីវកម្ម និងប្រាក់ចំណូលបន្ថែមផ្សេងទៀត ដូចជា ការប្រាក់ពីប្រាក់បញ្ញើសន្សំនៅធនាគារ ការជួលផ្ទះ ឬការវិនិយោគលើអចលនទ្រព្យ អ្នកអាចវិនិយោគនៅក្នុងផ្សារហ៊ុនដើម្បីធ្វើពិពិធកម្មវិនិយោគ។

**ឃ. មានទីផ្សារដែលអាចទិញលក់ប្រចាំថ្ងៃ៖** ការវិនិយោគលើភាគហ៊ុនមានលក្ខណៈពិសេស ជាងការវិនិយោគលើទ្រព្យសកម្មដទៃ ដោយហេតុថាទីផ្សារភាគហ៊ុនមានរចនាសម្ព័ន្ធពេញលេញ ដែលអនុញ្ញាតឲ្យវិនិយោគិនទិញ លក់ បានប្រចាំថ្ងៃ។ ក្នុងន័យនេះ វិនិយោគិនអាចបង្វែរភាគហ៊ុន ទៅជាសាច់ប្រាក់បានយ៉ាងងាយតាមរយៈការជួញដូរ ដែលធ្វើឡើងជារៀងរាល់ថ្ងៃ។ ផ្ទុយទៅវិញការវិនិយោគដោយផ្ទាល់ទៅក្នុងអាជីវកម្ម ឬអចលនទ្រព្យ មិនបានផ្តល់លក្ខណៈងាយស្រួល ក្នុងការបង្វែរជាសាច់ប្រាក់ ដូចការវិនិយោគលើភាគហ៊ុនឡើយ។

**ង. ការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធន៖** អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់ និង/ឬភាគលាភដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធនចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុល សម្រាប់រយៈពេល៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០២២។[15]

### ១.៤.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ

**ក. ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង៖** នៅពេលគិតគូរអំពីគម្រោងពង្រីកអាជីវកម្មរបស់ខ្លួន សហគ្រាសខ្នាតតូច និងមធ្យម ជានិច្ចកាលតែងជួបប្រទះបញ្ហាខ្វះខាតទុនសម្រាប់វិនិយោគ និងសម្រាប់ប្រើប្រាស់ជាទុនបង្វិល។ សហគ្រាសជាទូទៅមានប្រភពហិរញ្ញប្បទានច្រើន ពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ប៉ុន្តែភាគច្រើននៃប្រភពហិរញ្ញប្បទានទាំងនោះ ជាហិរញ្ញប្បទានរយៈពេលខ្លី ដែលអាចជារនាំងនៃការអភិវឌ្ឍផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន។ ផ្ទុយទៅវិញ ជាមួយនឹងទីផ្សារមូលបត្រ សហគ្រាសទាំងនេះ អាចទទួលបានហិរញ្ញប្បទានរយៈពេលវែង តាមរយៈការបោះផ្សាយភាគហ៊ុន និងលក់ទៅឲ្យសាធារណៈជន ហើយទទួលបាននូវមូលនិធិសម្រាប់រួមចំណែក ក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែង របស់សហគ្រាសដោយសហគ្រាស គ្រាន់តែទូទាត់ត្រឡប់ទៅវិនិយោគិនវិញជាភាគលាភ ដែលអាស្រ័យទៅតាមផលចំណេញ ជាក់ស្តែងរបស់សហគ្រាស និងលទ្ធភាពក្នុងការដកសាច់ប្រាក់។

[15] http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

**ខ. ទទួលបានការលើកទឹកចិត្តពន្ធ៖** ក្រុមហ៊ុនទាំងអស់ដែលទទួលបានការអនុញ្ញាតពី ន.ម.ក. បោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ ផ.ម.ក. នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណូលតាមទំហំនៃការបោះផ្សាយមូលបត្រ ដូចមានចែងក្នុងអនុក្រឹត្រស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ លេខ៩៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងរយៈពេលបីឆ្នាំ។ ស្របពេលជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏ទទួលបានការអនុគ្រោះបំណុលពន្ធ ដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការបោះផ្សាយមូលបត្រកម្មសិទ្ធ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឲ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធ និង/ឬមូលបត្របំណុលលើកដំបូងជាសាធារណៈ ត្រូវផ្តល់ជូន ន.ម.ក. នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**គ. ទទួលបាននិរន្តរភាពអាជីវកម្ម ជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន៖** ការបង្កើតសហគ្រាសអាជីវកម្មមួយ គឺត្រូវប្រឈមនឹងបញ្ហាជាច្រើន ប៉ុន្តែការរក្សាអាជីវកម្មឲ្យមានចេរភាព គឺរឹតតែជាការងារដ៏លំបាកមួយ និងជាការប្រឈមដ៏ធំសម្រាប់ម្ចាស់អាជីវកម្ម។ សហគ្រាសខ្នាតតូច និងមធ្យម តែងតែជាកម្មវត្ថុនៃការបារម្ភនានា អំពីអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន។ យ៉ាងណាមិញ នៅពេលដែលសហគ្រាសទាំងនោះ បានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឲ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀត ម្ចាស់អាជីវកម្ម អាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬការកែបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផលអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុង នឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឲ្យមានការរីកចម្រើន ប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម និងអាចជួយដល់ការត្រៀមខ្លួន របស់សហគ្រាសខ្នាតតូច និងមធ្យមក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ាន។

**ឃ. ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងសក្តានុពលរបស់ក្រុមហ៊ុន៖** ក្រុមហ៊ុនចុះបញ្ជីមួយ ជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងសាធារណជន ហើយកិច្ចប្រតិបត្តិការអាជីវកម្ម ឬហិរញ្ញវត្ថុ តែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត ទូរទស្សន៍ និងគេហទំព័រផ្សេងៗ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះ អាចជួយកែលម្អ

នូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ដែលអាចឲ្យសាធារណជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែងដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅក្នុងបរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្ម ដែលពោពេញទៅដោយការប្រកួតប្រជែងនេះ។

**ង. ការត្រៀមខ្លួនជាមុនចំពោះបទបញ្ញត្តិរបស់រាជរដ្ឋាភិបាល៖** ក្រុមហ៊ុនទាំងអស់ កំពុងតែត្រូវបានឃ្លាំមើលដោយរាជរដ្ឋាភិបាល អំពីការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់របស់ពួកគេ ដែលរួមទាំងការអនុវត្តពន្ធ ការកាន់បញ្ជីគណនី និងការធ្វើសវនកម្មជាដើម។ សេរីភាពដែលកំពុងថមថយនេះ នឹងជម្រុញឲ្យចាប់ផ្តើមអនុវត្តឲ្យបានឆាប់នូវកាតព្វកិច្ចច្បាប់នានា និងការក្លាយខ្លួនជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រ។[16]

### ១.៤.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ

ទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ។ គេតែងតែនិយាយថាទីផ្សារមូលបត្រគឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់បម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ច-សង្គម និងនយោបាយ) វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាម ដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ចយ៉ាងណា ពីព្រោះសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះ ស្ទើរតែគ្រប់បណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍទាំងអស់ មានទីផ្សារមូលបត្រនេះ ហើយវាបានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ៖

ក. ទីផ្សារមូលបត្រជួយជំរុញឲ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់ យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។

ខ. ទីផ្សារមូលបត្រគឺជាមធ្យោបាយមួយ ដែលប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។

គ. ទីផ្សារមូលបត្រគឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។

ឃ. ទីផ្សារមូលបត្រគឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។

ង. ទីផ្សារមូលបត្រជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។

ច. ទីផ្សារមូលបត្រជួយបង្កើតនូវទំលាប់នៃការវិនិយោគ។[17]

---

[16] http://csx.com.kh/kh/product/blisting.jsp?MNCD=3010 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

[17] http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

# ជំពូកទី២

# ស្ថានភាពទូទៅនៃ

# និយ័តករមូលបត្រកម្ពុជា

# និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ២.១. ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា

### ២.១.១.ប្រវត្តិរបស់និយ័តករមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន បានចូលជាធរមានកាលពីថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។[18] គណៈកម្មការមូលបត្រកម្ពុជា បានសម្ពោធជាផ្លូវការ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩។[19] ប៉ុន្តែនៅដើមឆ្នាំ២០២១ គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានប្តូរឈ្មោះជានិយ័តករមូលបត្រកម្ពុជាវិញ ដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។ និយ័តករមូលបត្រកម្ពុជាតម្រូវឲ្យអនុវត្តមុខងារទាំងស្រុងរបស់គណៈកម្មការមូលបត្រកម្ពុជា ដែលបានចែងក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរ មូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។[20] និយ័តករមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រងត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឱ្យមានការជួញដូរមូលបត្រប្រកបទៅដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។[21]

---

[18] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

[19] https://www.serc.gov.kh/khmer/m10.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

[20] https://www.serc.gov.kh/khmer/m77.php?pn=8 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

[21] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

### ២.១.២. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា




រូបភាពទី ២.១៖ ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលប័ត្រកម្ពុជាមានទីតាំងនៅ អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ និយ័តករមូលបត្រកម្ពុជាមានព័ត៌មានសម្រាប់ទំនាក់ទំនងដូចខាងក្រោម៖

- ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៨៨ ៥៦ ១១ / (៨៥៥) ១៦ ៨១៩ ៩៩១ (វិចិត្រ-admin) / (៨៥៥)០១ ៧៧៦ ៧៨៥ (តី-webmaster)
- ទូរសារៈ (៨៥៥) ២៣ ៨៨ ៥៦ ២២
- អ៊ីម៉ែលៈ INFO@SERC.GOV.KH ។[22]

[22] https://www.serc.gov.kh/khmer/m19.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

### ២.១.៣. រូបសញ្ញា អត្ថន័យនៃរូបសញ្ញា និងត្រារបស់និយ័តករមូលបត្រកម្ពុជា

#### ក. រូបសញ្ញា




រូបភាពទី២.២៖ រូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា

- រូបហង្សពណ៌មាស
- រូបស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចពណ៌ប្រផេះ
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "និយ័តករមូលបត្រកម្ពុជា" ព័ទ្ធជុំវិញនៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា **"SECURITIES AND EXCHANGE REGULATOR OF CAMBODIA"**។[23]

#### ខ. អត្ថន័យនៃរូបសញ្ញា

រូបសញ្ញារបស់ ន.ម.ក មានអត្ថន័យដូចតទៅ៖[24]

- រូបហង្សពណ៌មាស តំណាងឲ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឲ្យមានដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធិភាព ភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ តំណាងឲ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។

[23] https://www.serc.gov.kh/khmer/m17.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

[24] https://www.serc.gov.kh/khmer/m17.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

- រូបហង្សពណ៌មាសដែលឈរលើរង្វង់ថាស ដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ ចង់បង្ហាញពីភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងដោយអាជ្ញាធរជានិយ័តករមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធិភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**គ. ត្រារបស់និយ័តករមូលបត្រកម្ពុជា**

រូបភាពទី២.៣៖ ត្រារបស់និយ័តករមូលបត្រកម្ពុជា

ត្រារបស់និយ័តករមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា "និយ័តករមូលបត្រកម្ពុជា"។[25]

## ២.១.៤. ចក្ខុវិស័យ និងបេសកកម្ម

### ២.១.៤.១. ចក្ខុវិស័យ

និយ័តករមូលបត្រកម្ពុជាហៅកាត់ថា ន.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ ន.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

[25] https://www.serc.gov.kh/khmer/m17.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

### ២.១.៤.២. បេសកកម្ម

និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបំពេញនូវបេសកកម្មដូចខាងក្រោម៖[26]

- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- លើកកម្ពស់ទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព និងជំរុញឲ្យមានការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ច័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.១.៥. មុខងារនិយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជាមានមុខងារដូចខាងក្រោម៖[27]

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ
- ដាក់ឲ្យអនុវត្តនូវគោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់
- ដើរតួនាទីជាស្ថាប័នពិនិត្យ និង ដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណដែលប៉ះពាល់ដល់ប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ
- ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

[26] https://www.serc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)
[27] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ តុលា ២០០៧ មាត្រា ៧

### ២.១.៦. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា

សមាជិករបស់ ន.ម.ក មានអាណត្តិ ៥ ឆ្នាំ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ច។ សមាជិក ន.ម.ក អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន ន.ម.ក នៅពេលផុតអាណត្តិ។[28] និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលមានប្រធាន ១ រូប ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានសមាជិក ៨ រូប ដែលតែងតាំងដោយអនុក្រឹត្យ ដែលមានដូចខាងក្រោម៖[29]

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប
- តំណាងធនាគារជាតិនៃកម្ពុជា ១ រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១ រូប
- តំណាងក្រសួងយុត្តិធម៌ ១ រូប
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប
- អគ្គនាយកនៃ ន.ម.ក ១ រូប
- អ្នកជំនាញដែលមានបទពិសោធន៍ក្នុងវិស័យមូលបត្រ ២ រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២.១.៧. គោលដៅ និងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) មានគោលដៅ និងគោលបំណងដូចខាងក្រោម៖[30]

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគ ដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ

[28] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ១៩ តុលា ២០០៧ មាត្រា ៥
[29] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ១៩ តុលា ២០០៧ មាត្រា ៦
[30] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

## ២.១.៨. អង្គភាពចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា

### ២.១.៨.១. រចនាសម្ព័ន្ធចាត់តាំង

និយ័តករមូលបត្រកម្ពុជាមានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម៖[31]




រូបភាពទី២.៤៖ រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា

### ២.១.៨.២. នាយកដ្ឋានរបស់និយ័តករមូលបត្រកម្ពុជា

ន.ម.ក. មាននាយកដ្ឋានចំណុះចំនួន ០៦ ដូចខាងក្រោម៖[32]

១. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

២. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

៣. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

៥. នាយកដ្ឋានកិច្ចការគតិយុត្ត

៦. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

[31] https://www.serc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

[32] https://www.serc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២)

#### ២.១.៨.៣. អង្គភាពសវនកម្មផ្ទៃក្នុងនៃនិយ័តករមូលបត្រកម្ពុជា

ន.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងដែលស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ ន.ម.ក។

## ២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសបើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ " ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានចុះក្នុងបញ្ជីពាណិជ្ជកម្ម នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ គឺជាថ្ងៃប្រវត្តិសាស្ត្រដ៏សំខាន់មួយនៃវិស័យហិរញ្ញវត្ថុ និងជាមោទនភាពជាតិមួយសម្រាប់កម្ពុជា ដែលនៅទីបំផុត ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange)

ឈានដល់ដំណាក់កាលចុងក្រោយ ដែលត្រូវបានសម្ពោធដាក់ឲ្យដំណើរ និងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានអនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិជាលើកដំបូង។[33]

### ២.២.២. ចក្ខុវិស័យ

វិស័យមូលបត្រ គឺជាផ្នែកមួយក្នុងការធ្វើឲ្យវិស័យហិរញ្ញវត្ថុកាន់តែមានសន្ទុះកើនឡើងជាលំដាប់។ ហេតុនេះដើម្បីឲ្យដំណើរការនៃវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា កាន់តែរីកចម្រើនប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានកំណត់នូវចក្ខុវិស័យរបស់ខ្លួនយ៉ាងច្បាស់លាស់ក្នុងការជួយគាំទ្រនូវវិស័យហិរញ្ញវត្ថុកម្ពុជានោះគឺ ដើម្បីកសាងនូវ "**មហាវិថី**" ហិរញ្ញវត្ថុសម្រាប់កម្ពុជា។

### ២.២.៣. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រុមហ៊ុនផ្សារមូលបត្រ បានដាក់ចេញនូវបេសកកម្មមួយចំនួនដូចខាងក្រោម៖

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើននូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយ ដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៏ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ២.២.៤. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា

#### ក. នាមករណ៍

នាមករណ៍ក្រុមហ៊ុនមាននាមជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដែលហៅកាត់ថា (ផ.ម.ក.) និងជាភាសាអង់គ្លេសថា Cambodia Securities Exchange ហៅកាត់ថា (CSX)។

[33] http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនា ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២)

ខ. ផ្លាកសញ្ញា

**រូបភាពទី ២.៥ ៖ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្ថសញ្ញាណដូចខាងក្រោម៖

- ផ្នែកខាងលើមានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ក្រោមអក្សរផ្នែកខាងស្តាំ មានរូបបាងព្រណ៌មាសមួយ ដែលឈរបែរមុខទៅខាងស្តាំ
- ក្រោមអក្សរផ្នែកខាងឆ្វេង មានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាអក្សរកាត់ភាសាអង់គ្លេស ដែលមានពណ៌ខៀវ (CSX)។

### ២.២.៥.ព័ត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

**អាសយដ្ឋាន៖** អាគារ ផ.ម.ក. វិថីព្រះមហាក្សត្រយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

**ទូរស័ព្ទ** ៖ (៨៥៥) ២៣ ៩៥៨ ៨៨៨

**ទូរសារ៖** (៨៥៥) ២៣ ៩៥៥ ៥៥៨

**គេហទំព័រ៖** www.csx.com.kh

**ហ្វេសបុក៖** https://www.facebook.com/cambodia.csx/

**ក្រសួង និងស្ថាប័នពាក់ព័ន្ធ៖** info@csx.com.kh

### ២.២.៦. រចនាសម្ព័ន្ធនៃការគ្រប់គ្រង

រូបភាពទី២.៦ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា




## ២.៣. តួអង្គពាក់ព័ន្ធក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈដំបូង

### ២.៣.១.និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា ជានិយ័តករមូលបត្រតែមួយគត់ ដែលគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណៈជន ឬវិនិយោគិនមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

### ២.៣.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ត្រូវបានបង្កើតឡើង ដើម្បីដាក់ឲ្យដំណើរការប្រព័ន្ធជួញដូរមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រព័ន្ធរក្សាទុកមូលបត្រ ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ **ផ.ម.ក.** ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសល្អប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសការជំរុញ និងការលើកទឹកចិត្តដល់វិនិយោគិន និងក្រុមហ៊ុនក្នុងស្រុក តាមរយៈការបង្កើតឲ្យមានសន្ទនីយភាពទីផ្សារ និងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។

### ២.៣.៣. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការទិញលក់មូលបត្រ ក្នុងទីផ្សារមូលបត្រកម្ពុជាតាមរយៈការដើរតួជាអន្តរការី។ ជាទូទៅក្រុមហ៊ុននេះដើរតួនាទីជាអន្តរការី ឬជាអ្នកសម្របសម្រួលប្រតិបត្តិការមូលបត្រនៅក្នុងទីផ្សារ។ ក្រុមហ៊ុនមូលបត្រ គឺជាតួអង្គសំខាន់មួយនៅក្នុងដំណើរការទីផ្សារ ព្រោះក្រុមហ៊ុនមូលបត្រត្រូវបានចាត់ទុកជាអ្នកជំនាញក្នុងវិស័យមូលបត្រ ដែលមានតួនាទីយ៉ាងសំខាន់ ដើម្បីជួយក្រុមហ៊ុនបោះផ្សាយក្នុងដំណើរការលក់មូលបត្រ នៅលើទីផ្សារទទួលបានជោគជ័យ។ លើសពីនេះទៀត ក្រុមហ៊ុនមូលបត្រក៏មានតួនាទីជួយដល់វិនិយោគិនមូលបត្រនៅក្នុងដំណើរការជួញដូរមូលបត្រ (ការទិញ លក់មូលបត្រ) នៅក្នុងទីផ្សារផងដែរ ព្រោះវិនិយោគិនមិនអាចធ្វើការជួញដូរមូលបត្រ ដោយផ្ទាល់នៅលើទីផ្សារមូលបត្រដោយខ្លួនឯងបាននោះទេ។ រាល់ការជួញដូរមូលបត្ររបស់វិនិយោគិន ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលជាឈ្មួញជើងសារ។ ជារួមក្រុមហ៊ុនមូលបត្រត្រូវបានចាត់ទុកជាអន្តរការីមូលបត្រ ដែលមិនអាចខ្វះបាននៅក្នុងទីផ្សារ ទាំងក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ និងក្នុងដំណើរនៃការជួញដូរមូលបត្ររបស់វិនិយោគិន។ បច្ចុប្បន្ននៅកម្ពុជាមានក្រុមហ៊ុនមូលបត្រចំនួន ១២(ដប់ពីរ) ដែលមានសកម្មភាពអាជីវកម្មយ៉ាងសំខាន់ៗ៖[34]

- ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriters)
- ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers)
- ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ (Securities Brokers)

#### ក. ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រដើរតួយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួល និងសហការជាមួយសមាជិកក្រុមការងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការចុះបញ្ជីទាំងស្រុង រួមទាំងដំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ ក្រុមហ៊ុនដែលធានាទិញមូលបត្រមានដូចជា[35]៖

[34] ប្រកាសស្តីពីការផ្តល់ប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ លេខ ០០៩ គ.ម.ក ១៩ វិច្ឆកា ២០០៩

[35] https://www.serc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនា ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២២)

| ក្រុមហ៊ុនធានាទិញមូលបត្រ | |
|---|---|
| ១. យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី<br>Yuanta Securities (Cambodia) Plc. | អគារ Emerald ជាន់ទី៤ លេខ៦៤ (កែងផ្លូវ ១៧៨) មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ<br>ទូរសព្ទ : ០២៣ ៨៦០ ៨០០<br>ទូរសព្ទដៃ : ០៩២ ៧៧៧ ៣០៩<br>ទូរសារ : ០២៣ ២២៤ ១២៦<br>អ៊ីម៉ែល : yuanta@yuantacambodia.com<br>គេហទំព័រ : www.yuantacambodia.com |
| ២. អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ម.ក<br>RHB Securities (Cambodia) PLC. | ដីឡូត៍លេខ២១ ជាន់M កាច់ជ្រុងផ្លូវ១១០ និង៩៣ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៦៩ ១៦១<br>ទូរសារ : ០២៣ ៩៦៩ ១៧១ |
| ៣. កាណា ស៊ីឃ្យួរីធី អិលធីឌី<br>Cana Securities Ltd. | វិមានកាណាឌីយ៉ា ជាន់ទី ១៥ លេខ ៣១៥ ផ្លូវព្រះអង្គឌួង កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៩ ៨៨៧<br>០២៣ ៨៦៨ ២២២<br>ទូរសារ : ០២៣ ៩៩០ ៦៨៦<br>អ៊ីម៉ែល : info@canasecurities.com.kh<br>គេហទំព័រ : www.canasecurities.com.kh |
| ៤. កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី<br>Campu Securities Plc. | អគារកម្ពុប៉ែង លេខ ២៣ ជាន់ទី ៦ ផ្លូវលេខ ១១៤ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ២២២ ៨៨០<br>០២៣ ២២២ ៨៨១<br>០២៣ ២២២ ៨៨២<br>ទូរសារ : ០២៣ ២២២ ៨៨៧<br>អ៊ីម៉ែល : campusec@campusecurities.com.kh<br>gohklye@campusecurities.com.kh |

| | |
|---|---|
| ៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី<br>SBI Royal Securities Plc. | អាគារភ្នំពេញថៅវ័រ លេខ ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៦ ៩៧០<br>០២៣ ៩៩៦ ៩៧១<br>អ៊ីម៉ែល : info@sbiroyal.com |
| ៦. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | អគារ GT Tower ជាន់ទី២ មហាវិថីសាធារណរដ្ឋឆែក (១៦៩) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៤២៦ ៩៩៩<br>អ៊ីម៉ែល : info@pps.com.kh<br>គេហទំព័រ : www.pps.com.kh |
| ៧. ខេមបូឌា ស៊ីឃ្យូរីធី ម.ក<br>Cambodia Securities Plc. | អគារលេខ ៣៤២ ជាន់ទី១៧ មហាវិថីព្រះមុនីវង្ស កែងនឹងផ្លូវ ២៨៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៧ ៨៨៨<br>អ៊ីម៉ែល : services@cambodiasecurities.com<br>គេហទំព័រ : www.cambodiasecurities.com |

## ខ. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចធ្វើការជួញដូរមូលបត្រ (ទិញ-លក់) ក្នុងទីផ្សារមូលបត្រ។ ដូចនេះ តម្រូវឲ្យក្រុមហ៊ុនពាណិជ្ជករមូលបត្រ មានគណនីផ្ទាល់ខ្លួនសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្នុងការជួញដូរនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចទទួលបានផលចំណេញពីមូលបត្រ ហើយក៏ត្រូវប្រឈមមុខនឹងហានិភ័យក្នុងការជួញដូរមូលបត្រផងដែរ។[36] បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រមានតែក្រុមហ៊ុន ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី តែប៉ុណ្ណោះ ។

| ក្រុមហ៊ុនពាណិជ្ជករមូលបត្រ | |
|---|---|
| ១. ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី<br>Golden Fortune (Cambodia) Securities Plc. | អគារលេខ ១៧៤ ABCD មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ: ០២៣ ២១៨ ២៨៨<br>០២៣ ២១៨ ៣៨៨<br>ទូរសារ: ០២៣ ២១០ ១១១ |

[36] http://www.secc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនា ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២)

### គ. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ

ក្រុមហ៊ុនមូលបត្រដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ មានតួនាទីជាអ្នកទទួលទិញ ឬលក់មូលបត្រតាមបញ្ជារបស់អតិថិជនរបស់ខ្លួន។[37] ក្នុងន័យនេះ សាធារណៈជនមិនអាចធ្វើការទិញលក់មូលបត្រដោយផ្ទាល់នៅលើទីផ្សារមូលបត្របានទេ ប្រតិបត្តិការទាមទារឲ្យឆ្លងកាត់អន្តរការីដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ទទួលបានកម្រៃជើងសារពីការទទួលបញ្ជាទិញ ឬលក់ពីអតិថិជនរបស់ខ្លួន។ ក្រុមហ៊ុនទាំងនេះរួមមានដូចជា[38] ៖

| ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ | |
|---|---|
| ១. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី<br>ACLEDA Securities Plc. | នៅជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។<br>ទូរសព្ទ : ០២៣ ៧២៣ ៣៨៨<br>ទូរសារ : ០២៣ ៧២៣ ៣៧៧<br>អ៊ីម៉ែល : info@acledasecurities.com.kh<br>acs.admin@acledasecurities.com.kh<br>គេហទំព័រ : www.acledasecurities.com.kh |
| ២. ខេប ស៊ីឃ្យូរីធី លីមីធីត<br>CAB Securities Limited. | អគារលេខ ៩២ D ក្រុម ៦៧ វិថី ២៨៩ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។<br>ទូរសព្ទ : ០២៣ ២២០ ០០០<br>០២៣ ២២២ ០១៨<br>ទូរសារ : ០២៣ ៤២៦ ៦២៨ |
| ៣. ខេមបូឌាវៀតណាម ស៊ីឃ្យូរីធី ឯ.ក<br>Cambodia-Vietnam Securities Co., Ltd. | អគារលេខ ៣៧០ ជាន់ទី៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៧២៣ ៨៩៩<br>ទូរសារ : ០២៣ ៧២៣ ៨៩០ |

[37] http://www.secc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនា ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២)

[38] https://www.serc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនា ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២)

| | |
|---|---|
| | អ៊ីម៉ែល : info@cvs.com.kh<br>គេហទំព័រ : www.cvs.com.kh |
| ៤. ភីភី លីង ស៊ីឃ្យូរីធី ឯ.ក<br>PP Link Securities Co., Ltd | អគារលេខ១៥៨-១៦៦ ជាន់ទី៥ (បន្ទប់លេខ ៥០១) ផ្លូវលេខ ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរសព្ទ : ០៧៧ ៦៤៦ ៨៩០ / ០១៥ ៣០៨ ៦៦៦<br>អ៊ីម៉ែល : info@pplinksecurities.com<br>គេហទំព័រ : www.pplinksecurities.com |
| ៥. ហ្គោលដេន ហ្វ៊រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី<br>Golden Fortune (Cambodia) Securities Plc. | អគារលេខ ១៧៤ ABCD មហាវិថីម៉ៅសេងទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។<br>ទូរសព្ទ : ០២៣ ២១៨ ២៨៨<br>០២៣ ២១៨ ៣៨៨<br>ទូរសារ : ០២៣ ២១០ ១១១ |

## ២.៣.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ

### ២.៣.៤.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ **រ.ទ.ស.ភ.** បានចុះបញ្ជីជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង ១៥% នៃចំនួនភាគហ៊ុនធម្មតាសរុប។[39]

*រូបភាព ២.៧៖ ស្លាកសញ្ញា PWSA*

[39] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនធម្មតា |
| **ភាគហ៊ុនបោះផ្សាយ** | ១៣.០៤៥.៩៧៥ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ពី៤.០៥០រៀល ដល់៦.៣៥០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៦.៣០០រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | គុងយ៉ាង ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

*តារាង ២.១. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPWSA*

**២.៣.៤.២. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល** (GTI)

*រូបភាព ២.៨៖ ស្លាកសញ្ញា GTI*

ក្រុមហ៊ុន ហ្គ្រេនធ្វីនអ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ក្រុមហ៊ុន ហ្គ្រេនធ្វីន បានទិញយកក្រុមហ៊ុន QMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយ ក្នុងចំណោមរោងចក្រកាត់ដេរធំៗ ដំបូងបង្អស់ដែលបានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃផលិតផលរបស់ក្រុមហ៊ុនហ្គ្រេនធ្វីន រួមមានម៉ាក សម្លៀកបំពាក់កីឡាល្បីៗ ដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohls, Nautica, North Face, Russell Athletic។ល។[40]

[40] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000020003 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនធម្មតា |
| **ភាគហ៊ុនបោះផ្សាយ** | ៨.០០០.០០០ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៧ ដល់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៤ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៧.៤០០ រៀល ដល់ ១៤.០០០ រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២ ដល់ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៩.៦៤០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី |

*តារាង ២.២ តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង GTI*

**២.៣.៤.៣. កំពង់ផែស្វយ័តក្រុងភ្នំពេញ**( PPAP )

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) គឺប្រតិបត្តិករកំពង់ផែទន្លេធំជាងគេ និងជាកំពង់ផែអន្តរជាតិមួយ ក្នុងចំណោមប្រតិបត្តិករកំពង់ផែអន្តរជាតិទាំងពីរនៅព្រះរាជាណាចក្រកម្ពុជា ហើយជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ ក្នុងនាមជាប្រតិបត្តិករផែ ក. ស. ភ. ផ្តល់សេវាកម្មលើកដាក់ក្រោមដងយោង លើកដាក់លើទីលាន ឃ្លាំងស្តុកទុកទំនិញ កណ្ណដាកិច្ច ទីលានស្តុកទុកសំបកកុងតឺន័រ ពីរៀបទំនិញ ទូកុងតឺន័រ ត្រជាក់ វាស់ស្ទង់និងបូមស្តារ ជួសជុល និងថែទាំកុងតឺន័រ ប្រមូលផ្តុំចែកចាយទំនិញ និងសេវារថយន្តដឹកជញ្ជូនក្រៅចំណតផែ។ ក្នុងនាមជាអាជ្ញាធរផែ ក. ស. ភ. ទទួលបានសិទ្ធិគ្រប់គ្រងមណ្ឌលអាជីវកម្មផែ ដែលមានចំងាយ ១៦៦គ.ម។ ក្នុងមណ្ឌលអាជីវកម្មផែនេះ ក. ស. ភ. បាននិងកំពុងប្រតិបត្តិការនៅទីតាំងនៃចំណតផែចំនួន ៥ គឺ ១-ចំណតផែកុងតឺន័រ LM១៧ ២-ចំណតផែពហុបំណង TS៣ ៣-ចំណតផែពហុបំណង KM៦ ៤-ចំណតផែទន្លេបិទ UM២ និង ៥-ចំណតផែអ្នកដំណើរ និងទេសចរ TS១ ។[41]

*រូបភាព ២.៩៖ ស្លាកសញ្ញា PPAP*

[41] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000040001 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

*តារាង ២.៣ តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPAP*

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | កំពង់ផែស្វយ័តភ្នំពេញ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៤.១៣៦.៨៧៣ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៩ ដល់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៤.៤០៥ រៀល ដល់ ៦.៣២០ រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី១២ ដល់ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៥.១២០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

**២.៣.៤.៤. ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** (PPSEZ)

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (“PPSEZ”) និងប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត (“Poipet PPSEZ”)។ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ។ បច្ចុប្បន្ននេះ តំបន់សេដ្ឋកិច្ចពិសេសកំពុងធ្វើប្រតិបត្តិការ នៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ ក្រុមហ៊ុនក៏មានផ្គត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធព្រមជាមួយបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមាន ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកសំអុយ និងសេវាកម្មដទៃទៀត។ PPSEZ ជាតំបន់សេដ្ឋកិច្ចពិសេសឈរមុខគេ ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសដែលទទួលបានការអនុញ្ញាតផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា បើគិតតាមចំនួនវិនិយោគិនក្នុងតំបន់ ចំនួន

PPSEZ
Phnom Penh Special Economic Zone

*រូបភាព ២.១០៖ ស្លាកសញ្ញា PPSEZ*

ដើមទុនវិនិយោគ និងចំនួនកម្មករ កម្មការនី ជាមួយនឹងផ្ទៃដីធំជាងគេរបស់ PPSEZ ដែលមានទំហំប្រមាណ ៣៥៧,៣២ ហិកតា។[42]

*តារាង ២.៤ តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPSP*

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ១១.៥៧៥.០០០ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៨ ដល់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ២.៨០០រៀល ដល់ ៤.០០០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ២.៨៦០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី កម្ពុ ស៊ីឃ្យូរីធី និងកាណា ស៊ីឃ្យូរីធី |

### ២.៣.៤.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ជាក្រុមហ៊ុនរដ្ឋដែលបានបង្កើតឡើងដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារៈ កណ្ដាលធារកិច្ចនាំនាវាចេញ-ចូល និងផ្ដល់ភស្ដុភារដល់នាវា លើកដាក់ ផ្ទេរ ផ្ទុក ទំនិញ ស្ដុកទំនិញនៅឃ្លាំង និងទីលាន ព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្ដល់សេវាកម្មផ្សេងទៀតៈ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចជាជួលឃ្លាំងនិងថែរក្សាទំនិញ លើកដាក់ និងដឹកជញ្ជូនទំនិញ រួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ ក.ស.ស ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅ កម្ពុជាដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយ បណ្ដាញដឹកជញ្ជូនចំរុះរួមមាន បណ្ដាញផ្លូវគោក (ផ្លូវជាតិលេខ

*រូបភាព ២.១១៖ ស្លាកសញ្ញា PAS*

[42] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

៣ និងលេខ ៤) បណ្តាញផ្លូវរថភ្លើង (តភ្ជាប់ទៅរាជធានីភ្នំពេញ និងខេត្តកំពត) និងបណ្តាញផ្លូវអាកាស (តភ្ជាប់ទៅខេត្តសៀមរាម និងរាជធានីភ្នំពេញ)។[43]

| តារាងសង្ខេបលទ្ធនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ២១.៤៤២.៩៩២ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី២៥ មេសា ដល់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៣.៥២០រៀល ដល់ ៥.១៨០រៀល |
| **កាលបរិច្ឆេទធ្វើបរិសកម្ម** | ថ្ងៃទី១៧ ដល់ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៥.០៤០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី |

*តារាង ២.៥ តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PAS*

### ២.៣.៤.៦. ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC)

ធនាគារអេស៊ីលីដាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ដែលស្ថិតក្រោមគម្រោងអង្គការពលកម្មអន្តរជាតិក្នុងយុគសម័យក្រោយសង្គ្រាមនៅកម្ពុជា។ ជាច្រើនឆ្នាំមកនេះ ធនាគារអេស៊ីលីដា ត្រូវឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន។

*រូបភាព ២.១២៖ ស្លាកសញ្ញា ABC*

បច្ចុប្បន្ន ធនាគារអេស៊ីលីដា មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ហើយគឺជាធនាគារឈានមុខ និងធំជាងគេផ្នែកឥណទានបំណុល និងបណ្តាញចែកចាយគ្រប់ខេត្តក្រុង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអេស៊ីលីដា ក៏ជាធនាគារដំបូងដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួននៅក្រៅប្រទេសដែលរួមមានប្រទេសឡាវ និងមីយ៉ាន់ម៉ា ។ ធនាគារ អេស៊ីលីដា បានផ្តល់សេវាកម្មរបស់ខ្លួនតាមរយៈបណ្តាសាខាចំនួន ២៦៣ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ៣៨ ការិយាល័យក្នុងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ១៥ ការិយាល័យក្នុងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។អតិថិជនរបស់ធនាគារអេស៊ីលីដា រួមមានរូបវន្តបុគ្គល អាជីវ

[43] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

កម្មតូច និងមធ្យម និងនីតិបុគ្គល។ ធនាគារ អេស៊ីលីដា ទទួលប្រាក់បញ្ញើពីអតិថិជន និងផ្តល់ដល់អតិថិជននូវផលិតផល ឥណទានច្រើនប្រភេទ ព្រមទាំងសេវាហិរញ្ញវត្ថុផ្សេងទៀត ដូចជាការផ្ទេរប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្មភតិសន្យាហិរញ្ញវត្ថុ សេវាណែនាំពីផលិតផលធានារ៉ាប់រង និងសេវាធនាគារអេឡិចត្រូនិច។[44]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះ ក្រុមហ៊ុន | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៤.៣៨៤.៨៦៥ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី ០៣ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០២០ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ១៥.០០០ រៀល ដល់ ១៧.០០០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី ២៤ ខែមីនា ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ១៦.២០០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

*តារាង ២.៦ តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ABC*

### ២.៣.៤.៧. ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក.(PEPC)

*រូបភាព ២.១៣៖ ស្លាកសញ្ញា PEPC*

ផេសថិក (ខេមបូឌា) បានចុះបញ្ជីនៅឆ្នាំ ២០១០ ជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី ដែលផ្តល់សេវាសំខាន់លើការផ្តល់ជូនវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសសម្រាប់៖ ការគូសប្លង់ លទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ប្រើប្រាស់នូវអនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធថាមពលខ្សែកាបក្រោមដី សម្រាប់ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី និងការជួញដូរបង្គុំ និងបរិក្ខារប្រព័ន្ធថាមពល ដែលជាកម្មសិទ្ធិ និងមិនមែនកម្មសិទ្ធិ។ ផេសថិក (ខេមបូឌា) ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលត្រូវបានកាន់ទាំងស្រុងដោយក្រុមហ៊ុន PIB ដែលបានចុះបញ្ជី និងមានអាសយដ្ឋាននៅប្រទេសម៉ាឡេស៊ី ហើយបានចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោលនៃផ្សារមូលបត្រប្រទេសម៉ាឡេស៊ី។ ផេសថិក (ខេមបូឌា) ក៏មានក្រុមហ៊ុនបុត្រសម្ព័ន្ធ PESTECH (Myanmar) Limited បង្កើត

[44] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

ឡើងនៅឆ្នាំ២០១៧ និងផ្គត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលចម្រុះ និងដំណោះស្រាយប្រព័ន្ធបច្ចេកទេសចម្រុះ សម្រាប់រចនាលទ្ធកម្ម ការសាងសង់ និងសេវាពាក់ព័ន្ធនឹងឧស្សាហកម្មអគ្គិសនី។ [45]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះ ក្រុមហ៊ុន | ផេសចិក (ខេមបូឌា) ម.ក |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៣.៩៤៥.000 |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៧ ខែកក្កដា ដល់ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៣.១២០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អ អេច ប៊ីស៊ីយូរីធី (ខេមបូឌា) ម.ក |

*តារាង ២.៧ តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PEPC*

#### ២.៣.៤.៨. ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (DBDE)

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារផ្នែកវិស្វកម្ម និងសំណង់ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ផ្ដល់សេវាកម្មដូចជា សេវាកម្មគូរប្លង់ សាងសង់ តំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឲ្យក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ក្រៅពីកេរ្តិ៍ឈ្មោះក្នុងផ្នែកសំណង់ ការបំពាក់ឧបករណ៍ និងសេវាកម្មថែទាំ ឌីប៊ីឌី បានឈានមុខគេក្នុងការផ្គត់ផ្គង់ផលិតផលម៉ាកល្បីៗជាច្រើន សម្រាប់គម្រោងនានាកន្លងមកដែលរួមមានផលិតផលម៉ាក Scheneider, Franklin France, Daikin, Ginde, LG, Mitsubishi, Kumwell, EVT, Tsurumi Pump និងខ្សែកាបម៉ាក Yazaki។

*រូបភាពទី ២.១៤៖ ស្លាកសញ្ញា DBDE*

ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានធ្វើការចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១។[46]

---

[45] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009 (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

[46] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000150008 (ចូលទស្សនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះ ក្រុមហ៊ុន | ឌី បី ឌី អ៊ិនជីនារីង ម.ក |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៦.៤៦១.៥៣៨ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៦ ខែកក្កដា ដល់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ២.៣៨០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី |

*តារាងទី២.៨៖ ការសង្ខេបលទ្ធផលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ DBDE*[47]

## ២.៣.៥ ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុល

### ២.៣.៥.១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត

*រូបភាព ២.១៥៖ ស្លាកសញ្ញាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត*

ហត្ថាកសិករ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំពីសារណៈជនធំមួយ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ជាង ២៥ឆ្នាំ មកហើយ។ ហត្ថាកសិករ បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាភ្នាក់លក់សេវាធានារ៉ាប់រងផងដែរ។ តាមរយៈសាខា ចំនួន១៧៧ និង ម៉ាស៊ីនអេធីអឹម ចំនួន១២៩ គ្រឿង នៅទូទាំងប្រទេស។

បច្ចុប្បន្ន ហត្ថាកសិករ លីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃឡង់ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលើសកលលោក។[48]

47 http://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=91 (ចូលទស្សនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២)

48 https://hkl.com.kh/kh/detail/view/253/34?ctype=article (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត |
| និមិត្តសញ្ញាមូលបត្របំណុល | HKL21A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ១.២០០.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៨,៥%ក្នុងមួយឆ្នាំ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| កាលបរិច្ឆេទចុះបញ្ជី | ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ |
| កាលប្រតិទាន | ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ |

*តារាងទី២.៩ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ ហត្ថាកសិករ*

### ២.៣.៥.២ គ្រឹះស្ថានហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

*រូបភាព ២.១៦៖ ស្លាកសញ្ញាអិល អូ អិល ស៊ី (ខេមបូឌា) ភីអិលស៊ី*

អិល អូ អិល ស៊ី (ខេមបូឌា) ភីអិលស៊ី៖ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំមួយនៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើប្រតិបត្តិការជាង២៦ឆ្នាំមកហើយ។ អិល អូ អិល ស៊ី ផ្ដល់សេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនរបស់ខ្លួនរួមមាន សេវាឥណទាន សេវាប្រាក់បញ្ញើសំចៃ ភតិសន្យាហិរញ្ញវត្ថុ សេវាផ្ទេរប្រាក់ សេវាធនាគារចល័ត និងសេវាទូទាត់វិក្កយបត្រ។ អិលអូអិលស៊ី បាននឹងកំពុងផ្ដល់សេវាហិរញ្ញវត្ថុឌីជីថល ដើម្បីពង្រីកបណ្ដាញចែកចាយបន្ថែមទៀត ដូចជា កម្មវិធីធនាគារចល័ត iPay Mobile Application សេវាធនាគារតាមអ៊ីនធើណែតបាគង សេវាទូទាត់រហ័ស (FAST) CSS និងសេវាទូទាត់សងប្រាក់តម្លៃរាយ (RFT)។[49] អិលអូអិលស៊ីបានបោះផ្សាយមូលបំណុលចំនួនពីរប្រភេទគឺ៖[50]

---

[49] https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/ (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

[50] http://www.csx.com.kh/data/dbond/listPosts.do?lang=kh&MNCD=50203&issueCode=KH2000081953 (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | អិល អូ អិល ស៊ី (ខេមបូឌា) ភីអិលស៊ី |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី មានការការពារហានិភ័យអត្រាប្តូរប្រាក់ ២០១៩-២០២២ (LOLC FX-Indexed Bond) |
| និមិត្តសញ្ញាមូលបត្របំណុល | LOLC22A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៥៣៦.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៨,០០%ក្នុងមួយឆ្នាំ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| កាលបរិច្ឆេទចុះបញ្ជី | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ |
| ឥណប្រតិទាន | ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ |

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល | |
|---|---|
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណអិលអូអិលស៊ីមិនបានការការពារហានិភ័យអត្រាប្តូរប្រាក់(LOLC Plain Bond)[51] |
| និមិត្តសញ្ញាមូលបត្របំណុល | LOLC22B |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ២៦៤,០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៩,០០%ក្នុងមួយឆ្នាំ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| ឥណប្រតិទាន | ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ |

*តារាងទី២.១០ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (ខេមបូឌា) ភីអិលស៊ី*

[51] http://www.csx.com.kh/company/announce/viewPost.do?MNCD=50104&postId=686#.YjwKe-hBztQ (ចូលទស្សនា ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២២)

### ២.៣.៥.៣ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់

ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (Advanced Bank of Asia Limited) ហៅកាត់ថា ABA ជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជននាំមុខមួយរបស់កម្ពុជា ដែលបង្កើតឡើងនៅឆ្នាំ១៩៩៦។ ឆ្លងកាត់ការអភិវឌ្ឍ និងកំណើនជាង២៥ឆ្នាំកន្លងមកនេះ ABA បានពង្រឹងជំហររបស់ខ្លួនយ៉ាងរឹងមាំក្នុងទីផ្សារកម្ពុជា និងក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជកំពូលទាំង៣នៅក្នុងប្រទេស។ សព្វថ្ងៃនេះ ABA មានបម្រើសេវាជូនដល់បណ្ដាអតិថិជនជាច្រើន ដូចជា សហគ្រាសធុនតូច និងមធ្យម អាជីវកម្មខ្នាតតូច និងរូបវន្តបុគ្គល។[52]

រូបភាព ២.១៧៖ ស្លាកសញ្ញាធនាគារ វឌ្ឍនៈអាស៊ី ចំកាត់

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណសាជីកម្ម អេប៊ីអេ[53] |
| និមិត្តសញ្ញាមូលបត្របំណុល | ABAA22A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៨៤៨.២១០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៧,៧៥%ក្នុងមួយឆ្នាំ |
| ចំណាត់ថ្នាក់លទ្ធភាពសង | B (វាយតម្លៃដោយ S&P Global Ratings) |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| រយៈពេលឥណប្រតិទាន | ៣ឆ្នាំ |
| ឥណប្រតិទាន | ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២ |

*តារាងទី២.១១ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់*

[52] https://www.ababank.com/km/about-us/ (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

[53] http://www.csx.com.kh/data/dbond/listPosts.do?lang=kh&MNCD=50203&issueCode=KH2000091986 (ចូលទស្សនា ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២២)

### ២.៣.៥.៤ ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក

ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក (Phnom Penh Commercial Bank Plc.) ៖ ធនាគារភ្នំពេញពាណិជ្ជ ម.ក (PPCBank) បានចាប់ផ្តើមប្រតិបត្តិការនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។ កាលពីខែកញ្ញា ឆ្នាំ២០១៦ PPCBank ទទួលបានភាគទុនិកដ៏រឹងមាំពី JB Financial Group Co., Ltd. ដែលមានមូលដ្ឋាននៅប្រទេសកូរ៉េខាងត្បូង។

*រូបភាព ២.១៨៖ ស្លាកសញ្ញាធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ី ប៊ែង" ម.ក*

គិតត្រឹមបំណាច់ខែមីនា ឆ្នាំ២០២១ PPCBank មានទ្រព្យសកម្មសរុប 1,047 លានដុល្លារអាមេរិក និងមានអតិថិជនច្រើនជាង 122,000 នាក់ ជាមួយនឹងសាខាចំនួន 23 ទូទាំងប្រទេស និងម៉ាស៊ីន ATMs ចំនួន 66។[54]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី១ | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណធនាគារភ្នំពេញពាណិជ្ជ ម.ក មានការការពារហានិភ័យ អត្រាប្តូរប្រាក់២០២០-២០២៣ លេខ១[55] |
| និមិត្តសញ្ញាមូលបត្របំណុល | PPCB23A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៤០០.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៦,៥០%ក្នុងមួយឆ្នាំ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| រយៈពេលឥណប្រតិទាន | ៣ឆ្នាំ |
| ឥណប្រតិទាន | ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ |

*តារាងទី២.១២ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី១របស់ ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក*

---

[54] https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/ (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

[55] http://www.csx.com.kh/data/dbond/listPosts.do?lang=kh&MNCD=50203&issueCode=KH2000111A46 (ចូលទស្សនា ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២ | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណធនាគារភ្នំពេញពាណិជ្ជ ម.ក មានការការពារហានិភ័យ អត្រាប្តូរប្រាក់២០២០-២០២៣ លេខ២ |
| និមិត្តសញ្ញាមូលបត្របំណុល | PPCB23B |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៤០០.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៦,៥០%ក្នុងមួយឆ្នាំ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| រយៈពេលឥណប្រតិទាន | ៣ឆ្នាំ |
| ឥណប្រតិទាន | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ |

*តារាងទី២.១៣ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២របស់ ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក*

### ២.៣.៥.៥ អ អិម អេ (ខេមបូឌា) ម.ក

*រូបភាព ២.១៩៖ ស្លាកសញ្ញាក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក*

ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (RMA (CAMBODIA) PLC) ៖ ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធុនធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមាន Ford Jaguar Land Rover John Deere TCM JCB FUSO និង Piaggio។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និងដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងការតម្លើងដំបូងគេបង្អស់។ ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។[56]

[56] https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/ (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក[57] |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា |
| និមិត្តសញ្ញាមូលបត្របំណុល | RMAC25A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៨០០.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| ប្រភេទមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្ម |
| អត្រាគូប៉ុង | ៥,៥០%ក្នុងមួយឆ្នាំ |
| បុគ្គលធានា | Credit Guarantee and Investment Facility (CGIF) |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| រយៈពេលឥណប្រតិទាន | ៥ឆ្នាំ |
| ឥណប្រតិទាន | ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៥ |

*តារាងទី២.១៤ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក*

**២.៣.៥.៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក (PRASAC Microfinance Institution Plc) បានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ធ្វើជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន និងធ្វើប្រតិបត្តិការ

*រូបភាព ២.២០៖ ស្លាកសញ្ញាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក*

[57] http://www.csx.com.kh/data/dbond/listPosts.do?lang=kh&MNCD=50203&issueCode=KH2000121A44 (ចូលទស្សនា ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២២)

ជាង២៥ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារឯកជននៅកម្ពុជា។ បច្ចុប្បន្ននេះ ប្រាសាក់ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេ បើគិតពីទ្រព្យសកម្ម សម្ចៀតឥណទាន ប្រាក់ចំណេញ ប្រាក់បញ្ញើពីអតិថិជន និងឈរឈ្មោះលំដាប់កំពូល ក្នុងចំណោមគ្រឹះស្ថានធនាគារធំៗ ចំនួន៥ នៅក្នុងប្រទេសកម្ពុជា។[58]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល[59] | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្មប្រាសាក់ |
| និមិត្តសញ្ញាមូលបត្របំណុល | PRA23A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ១.២៧២.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៧,៥០%ក្នុងមួយឆ្នាំ |
| បុគ្គលធានា | Credit Guarantee and Investment Facility (CGIF) |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| រយៈពេលឥណប្រតិទាន | ៣ឆ្នាំ |
| ឥណប្រតិទាន | ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ |

*តារាងទី២.១៥ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលលើកទី២របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក*

### ២.៣.៥.៧ ក្រុមហ៊ុន តែលកូថេក

*រូបភាព ២.២១៖ ស្លាកសញ្ញាក្រុមហ៊ុនតែលកូថេក*

ក្រុមហ៊ុន តែលកូថេក គឺជាក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណែតលំដាប់ខ្ពស់ ដែលបម្រើតម្រូវការទីផ្សារសេវាអ៊ិនធឺណែត សម្រាប់ក្រុមហ៊ុន សហគ្រាស និងតាមលំនៅដ្ឋានក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន Ezecom ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៨ ដោយក្រុមហ៊ុន Royal Group ហើយជាក្រុមហ៊ុនតែមួយគត់នៅកម្ពុជា ដែលមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធខ្សែហ្វាយបើរអុបទិកធំបំផុត និង

---

[58] https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/ (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

[59] http://www.csx.com.kh/company/announce/viewPost.do?MNCD=50104&postId=846#.Yjw72edBztQ (ចូលទស្សនា ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២២)

កាន់កាប់ភាគហ៊ុន ក្នុងបណ្តាញខ្សែកាបបាតសមុទ្រ Asian American Gateway (AAG) និងបណ្តាញខ្សែកាបបាតសមុទ្រ ម៉ាឡេស៊ី កម្ពុជា ថៃ (MCT)។[60] តារាងខាងក្រោមនេះជាព័ត៌មានពីសញ្ញាបណ្ណ តែលកូថេក៖[61]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល | |
|---|---|
| ក្រុមហ៊ុនបោះផ្សាយ | ក្រុមហ៊ុន តែលកូថេក |
| ឈ្មោះមូលបត្របំណុល | សញ្ញាបណ្ណ តែលកូថេក |
| និមិត្តសញ្ញាមូលបត្របំណុល | TCT26A |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៨០០.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០រៀល |
| អត្រាគូប៉ុង | ៧,៥០%ក្នុងមួយឆ្នាំ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ប្រចាំឆមាស |
| រយៈពេលឥណប្រតិទាន | ៥ឆ្នាំ |
| ឥណប្រតិទាន | ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៦ |

*តារាងទី២.១៦ - តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលរបស់ ក្រុមហ៊ុន តែលកូថេក*

### ២.៣.៦. ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ

ជាភ្នាក់ងារដែលបានទទួលស្គាល់ពី **ន.ម.ក** ដែលគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ព័ន្ធនឹងមូលបត្រ មានចំនួន ៦ គឺ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
- ធនាគារ កាណាឌីយ៉ា ក.អ (Canadia Bank Plc.)
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (Bank for Investment and Development of Cambodia Plc.)
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី (Cambodian Public Bank Plc.)

[60] https://cnc.com.kh/detail/news/23342 (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

[61] http://www.csx.com.kh/company/announce/viewPost.do?MNCD=50104&postId=1176#.Yjw_aedBztQ (ចូលទស្សនា ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២២)

- ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក (B.I.C (Cambodia) Bank Plc.)
- ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (Advanced Bank of Asia Limited)[62]

**២.៣.៧. ភ្នាក់ងារបញ្ជិកាមូលបត្រ**

ជាភ្នាក់ងារដែលទទួលស្គាល់ពី ន.ម.ក. ដែលគ្រប់គ្រងនូវដំណើរការផ្ទើបរីសកម្ម និងការបែងចែកមូលបត្រកត់ត្រាបញ្ជីកម្មសិទ្ធករមូលបត្រ និងធ្វើរបាយកាណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។ ភ្នាក់ងារបញ្ជិកាមូលបត្រ មានចំនួន៣ គឺៈ

- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
- ក្រុមហ៊ុន ត្រាយខ័រស៊ីយ្យូរីធី សឺវីស ភីអិលស៊ី (Tricor Securities Services PLC.)
- ក្រុមហ៊ុន ភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី (Phnom Penh Securities PLC.)[63]

**២.៣.៨. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ**

ជាភ្នាក់ងារដែលទទួលស្គាល់ពី **ន.ម.ក.** ដែលគ្រប់គ្រងបញ្ជីកម្មសិទ្ធករមូលបត្រឲ្យមានសង្គតិភាព ការផ្លាស់ប្តូរកម្មសិទ្ធករ ការធ្វើរបាយការណ៍ ស្ថិតិ និងការរៀបចំពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធករមូលបត្រ ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ និងការបង់ការប្រាក់ជាដើម។ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រមានចំនួន ៣គឺៈ

- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
- ក្រុមហ៊ុន ត្រាយខ័រស៊ីយ្យូរីធី សឺវីស ភីអិលស៊ី (Tricor Securities Services PLC.)
- ក្រុមហ៊ុន ភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី (Phnom Penh Securities PLC.)[64]

**២.៣.៩. ភ្នាក់ងារទូទាត់**

ជាភ្នាក់ងារដែលទទួលស្គាល់ពី **ន.ម.ក.** ដែលមានតួនាទីជាអ្នកគណនាភាគលាភ ការប្រាក់ ប្រាក់ដើមទូទាត់ជូនកម្មសិទ្ធករ ឬភាគីដែលមានការពាក់ព័ន្ធក្នុងនាមជាក្រុមហ៊ុនបោះផ្សាយ និងបញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ដល់កម្មសិទ្ធករមូលបត្រ និងទៅក្រុមហ៊ុនបោះផ្សាយ និង **ន.ម.ក.** តាមការចាំបាច់។ ភ្នាក់ងារទូទាត់មានចំនួន ២គឺៈ

- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
- ក្រុមហ៊ុន ភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី (Phnom Penh Securities PLC.)

---

62 https://www.serc.gov.kh/khmer/m59.php?pn=6 (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

63 https://www.serc.gov.kh/khmer/m65.php?pn=6 (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

64 https://www.serc.gov.kh/khmer/m65.php?pn=6 (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

- ក្រុមហ៊ុន ត្រាយខ័រ ស៊ុយរីធី សឺវីស ភីអិលស៊ី (Tricor Securities Services PLC)[65]

**២.៣.១០. ក្រុមហ៊ុន និងការិយាល័យមេធាវីផ្តល់សេវាផ្នែកច្បាប់នៅក្នុងវិស័យមូលបត្រ**

ជាក្រុមហ៊ុនដែលផ្តល់សេវាផ្នែកច្បាប់ ដែលបានទទួលស្គាល់ដោយនិយ័តករមូលបត្រកម្ពុជា។ ក្រុមហ៊ុនទាំងនោះរួមមានដូចជា៖

- ក្រុមហ៊ុនមេធាវី អេច ប៊ី អេស
- ការិយាល័យមេធាវី អ អេស ធី សុខអេន ហេង
- ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការី
- ការិយាល័យមេធាវី សិទ្ធិសក្តិ
- ការិយាល័យមេធាវីអាស៊ី កម្ពុជា
- ការិយាល័យមេធាវី ប៊ុន និងសហការី
- ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី
- ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាគា
- ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន
- ការិយាល័យមេធាវី ស៊ិន & ផាតនើ
- ក្រុមមេធាវី កម្ពុជាបាយ័ន (ស៊ី ប៊ី អិល)
- ក្រុមមេធាវី មេគង្គ
- ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ
- ក្រុមមេធាវី ស៊ី អេស ភី និង សហការី
- ការិយាល័យមេធាវី សិដ្ឋាល័យ[66]

**២.៣.១១ ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ**

ជាក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលស្គាល់ពី **ន.ម.ក.** ដើម្បីធ្វើសវនកម្មនូវរបាយការណ៍ហិរញ្ញវត្ថុដោយអនុវត្តតាមស្តង់ដារដែលបានកំណត់។ ក្រុមហ៊ុនផ្តល់សេវាម្មនៅក្នុងវិស័យមូលបត្រមានចំនួនប្រាំបីដូចខាងក្រោម៖

- ក្រុមហ៊ុន ប្រាយវ៉តផ៌រ ហាវខូភើស៍ (ខាមបូឌា)
- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា

[65] http://csx.com.kh/kh/member/participants.jsp (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

[66] https://www.serc.gov.kh/khmer/m58.php?pn=6 (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

- ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត
- ក្រុមហ៊ុន អឺនស៍្ទ អ៊ែន យ៉ាំង (ខេមបូឌា)
- ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
- ក្រុមហ៊ុន ក្រូវ (ខេមអេច) ឯ.ក
- ក្រុមហ៊ុន ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី
- ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក[67]

### ២.៣.១២. ក្រុមហ៊ុនផ្តល់សេវាកម្មវាយតម្លៃនៅក្នុងវិស័យមូលបត្រ

ជាក្រុមហ៊ុនដែលទទួលស្គាល់ដោយ **ន.ម.ក** ដើម្បីវាយតម្លៃលើទ្រព្យសកម្ម ដោយអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។ បញ្ជីឈ្មោះក្រុមហ៊ុនដែលផ្តល់សេវាកម្មវាយតម្លៃនៅក្នុងវិស័យមូលបត្រមានដូចជា៖

- ក្រុមហ៊ុន វីត្រាល់ អឺព្រេហ្សល
- ក្រុមហ៊ុន ស៊ីងឈ័រ ប្រូធីធី ឯ.ក
- ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា)[68]

### ២.៣.១៣. ក្រុមហ៊ុនផ្តល់សេវាបកប្រែ

ក្រុមហ៊ុនផ្តល់សេវាបកប្រែ មានតួនាទី បកប្រែឯកសារពាក់ព័ន្ធនឹង IPO ឱ្យបានត្រឹមត្រូវតាមអត្ថន័យដើម។ ក្រុមហ៊ុនបកប្រែដែលទទួលបានការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា គឺមានចំនួន ០១ ក្រុមហ៊ុនគឺ មន្ទីរ សារការី អេច ប៊ី អេស។

### ២.៣.១៤. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល មានតួនាទី និងភារកិច្ច ដូចការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល តាមដានទ្រព្យធានា តាមដានការអនុវត្តលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់ (Terms and Conditions) និងកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ដោះស្រាយការទាមទាររបស់ម្ចាស់មូលបត្របំណុល ធានាថាមូលបត្របំណុលដែលបានធ្វើបដិវត្ត ឬទូទាត់សងត្រូវធ្វើឡើងដោយអនុលោមតាម លក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់។ ភ្នាក់ងារនេះ រួមមានដូចជា៖

---

[67] https://www.serc.gov.kh/khmer/m53.php?pn=6 (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

[68] https://www.serc.gov.kh/khmer/m54.php?pn=6 (ចូលទស្សនា ថ្ងៃទី ១៦ មិថុនា ២០២២)

- អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី

- កាណា ស៊ីយូរីធី អិលធីឌី

**២.៣.១៥. ភ្នាក់ងារវាយតម្លៃលទ្ធភាពសង**

ភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ដោយ **ន.ម.ក** គឺក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ។[69]

[69] https://www.serc.gov.kh/khmer/m69.php?pn=6 (ចូលទស្សនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២)

# ជំពូកទី៣
# ការបោះផ្សាយលក់
# មូលបត្រលើកដំបូង
# នៅកម្ពុជា

# ជំពូកទី៣

# ការបោះផ្សាយលក់មូលបត្រលើកដំបូងនៅកម្ពុជា

## ៣.១. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង

ការធ្វើហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈជាមធ្យោបាយមួយ ដែលអនុញ្ញាតក្រុមហ៊ុនសំដៅធានាដល់និរន្តរភាពអាជីវកម្មរបស់ខ្លួន។ ដើម្បីឲ្យដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈមានភាពរលូន ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាបុគ្គលពាក់ព័ន្ធគប្បីស្វែងយល់ពីដំណើរការនេះឲ្យបានច្បាស់លាស់។ ខាងក្រោមនេះជាយន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈដែលក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តតាមៈ

១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រជាសាធារណៈជូន ន.ម.ក.

២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

៣. ការបង្កើតក្រុមការងារ IPO

៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពី **ផ.ម.ក.**

៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី **គ.ម.ក.**

៧. ការកំណត់ថ្លៃលក់មូលបត្រ

៨. ការស្នើសុំបញ្ជាក់ការដាក់ថ្លៃមូលបត្រពី **ផ.ម.ក.**

៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **ន.ម.ក.**

១០.ការធ្វើបរិវិសកម្មមូលបត្រ

១១.ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ

១២.ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ **ផ.ម.ក.**[70]

[70] គណៈកម្មការមូលបត្រកម្ពុជា ពុទ្ធិមូលបត្រ លេខ៣៨ ចេញផ្សាយ ឆ្នាំ២០១៩ ទំព័រ ១-២

## ៣.២. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

### ៣.២.១. លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ

បច្ចុប្បន្ន ទីផ្សារមូលបត្រនៅកម្ពុជាបែងចែកជា២គឺ ទីផ្សារគោល និង ទីផ្សារកំណើន។

**១. ទីផ្សារគោល៖** គឺជាផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ការចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដែលមានស្តង់ដារ និងទំហំធំ។[71]

**២. ទីផ្សារកំណើន៖** គឺជាទីផ្សារថ្មីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀត សម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះ ដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី ១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានផងដែរ។[72]

ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ក្រុមហ៊ុនត្រូវគោរពតាមលក្ខខណ្ឌដូចជា៖[73]

*តារាងទី៣.១៖ លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ១- អភិបាលកិច្ចសាជីវកម្ម | |
| ២- សកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច | |
| ៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរយៈពេល ២ឆ្នាំចុងក្រោយ និងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា (ប្រសិនមាន) | ៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរយៈពេល ១ឆ្នាំចុងក្រោយ និងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា (ប្រសិនមាន) |
| ៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ | |
| ៥- ត្រូវមានឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ ន.ម.ក | |

[71] http://csx.com.kh/kh/product/mainboard.jsp?MNCD=30102 ((ចូលទស្សនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២)

[72] http://csx.com.kh/kh/product/growthboard.jsp?MNCD=30103 (ចូលទស្សនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២)

[73] និយ័តករមូលបត្រកម្ពុជា មគ្គុទេសក៍ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២០១៧ ទំព័រទី ១០-១១

*តារាងទី ៣.២៖ លក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

<table>
<tr><th>លក្ខខណ្ឌតម្រូវ</th><th>ទីផ្សារគោល</th><th>ទីផ្សារកំណើន</th></tr>
<tr><td>មូលធនភាគហ៊ុនិក</td><td>យ៉ាងតិច ៣០ពាន់លានរៀល</td><td>យ៉ាងតិច ២ពាន់លានរៀល</td></tr>
<tr><td>ចំណេញសុទ្ធ</td><td>យ៉ាងតិច២ពាន់លានរៀលនៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និង៣ពាន់លានរៀលសម្រាប់រយៈពេល២ឆ្នាំចុងក្រោយ</td><td>ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬមានលំហូរសាច់ប្រាក់ពីប្រតិបត្តិការអាជីវកម្មវិជ្ជមាន ជាមួយនឹងអត្រាប្រាក់ចំណេញដុលយ៉ាងតិច ១០%</td></tr>
<tr><td>ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី១០ភាគហ៊ុនឡើងទៅ</td><td>ត្រូវមានចំនួនយ៉ាងតិច ២០០នាក់</td><td>ត្រូវមានចំនួនយ៉ាងតិច ១០០នាក់</td></tr>
<tr><td>ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១%</td><td>ត្រូវមានចំនួនសរុបយ៉ាងតិច ៧% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប</td><td>ត្រូវមានចំនួនសរុបយ៉ាងតិច ១០%នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប</td></tr>
<tr><td>របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម</td><td>២ឆ្នាំចុងក្រោយ</td><td>១ឆ្នាំចុងក្រោយ</td></tr>
<tr><td colspan="3">មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះផ្សាយច្រើនជាងគេក្នុងរយៈពេល ១ឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ</td></tr>
<tr><td colspan="3">មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើរនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពីន.ម.ក</td></tr>
</table>

### ៣.២.២. ការរៀបចំរបស់ក្រុមហ៊ុន ដើម្បីទទួលបានហិរញ្ញប្បទានពីទីផ្សារមូលបត្រ

ដើម្បីអាចបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង បានក្រុមហ៊ុនត្រូវ៖[74]

- **ជំហានទី១៖ ការរៀបចំខ្លួន**

- រៀបចំកិច្ចប្រជុំ និងព្រមព្រៀងផ្ទៃក្នុងជាមួយក្រុមប្រឹក្សាភិបាលអំពីគម្រោងស្វែងរកដើមទុនបន្ថែមតាមរយៈទីផ្សារមូលបត្រ។
- ត្រូវជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។
- រៀបចំអភិបាលកិច្ចសាជីវកម្ម ដូចជាសមាសភាពក្រុមប្រឹក្សាភិបាល ជាពិសេសអភិបាលឯករាជ្យ និងគណៈកម្មាធិការសវនកម្មជាដើម។
- ពង្រឹងប្រព័ន្ធគណនេយ្យស្របតាមស្តង់ដារគណនេយ្យដែលមានជាធរមាន និងការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុមុននឹងដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រ។
- រៀបចំផែនការសម្រាប់ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដើម្បីធានាកំណើនរយៈពេលវែង។
- រៀបចំឯកសារចាំបាច់នានា សម្រាប់ក្រុមហ៊ុនធានាទិញមូលបត្រធ្វើការសិក្សា និងរៀបចំត្រួតពិនិត្យកាតព្វកិច្ចតាមច្បាប់ និងរៀបចំឯកសារចាំបាច់ផ្សេងៗទៀតសម្រាប់ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រ។

- **ជំហានទី២៖ ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ និងការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង**

ពាក់ព័ន្ធនឹងការរៀបចំខ្លួនខាងលើនេះ ក្រុមហ៊ុនមិនចាំបាច់បារម្ភពីការរៀបចំ និងបំពេញនីតិវិធីនៃការបោះផ្សាយលក់មូលបត្រដោយខ្លួនឯងនោះទេ ដោយសារក្រុមហ៊ុនត្រូវតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) ដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក. និងជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្ម មេធាវី ដែលទទួលបានការទទួលស្គាល់ពី ន.ម.ក. ជាដើម ដើម្បីបង្កើតជាក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)។ ក្រុមការងារនេះ នឹងជួយសម្រួលការងារដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ជាពិសេស ការរៀបចំរបាយការណ៍ត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ (Due Diligence Report) និង រៀបចំឯកសារផ្តល់ព័ត៌មាន (Disclosure Document) ជាដើម។

---

[74] និយ័តករមូលបត្រកម្ពុជា មគ្គុទេសក៏ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ២០១៧ ទំព័រទី ១២

### ក. ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រ ជាបុគ្គលសំខាន់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនធានាទិញមូលបត្រមានតួនាទីដូចខាងក្រោម៖

- ផ្តល់ប្រឹក្សាសំខាន់ៗដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដូចជាការកំណត់ថ្លៃ ការកំណត់ទំហំបោះផ្សាយ និងកំណត់គម្រោងពេលបោះផ្សាយ
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដោយចូលរួមផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- រៀបចំឯកសារផ្តល់ព័ត៌មាន និងធ្វើរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់
- ធានាទិញមូលបត្រដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង។

លើសពីនេះ ក្រុមហ៊ុនធានាទិញមូលបត្រអាចណែនាំក្រុមហ៊ុនបោះផ្សាយលក់មូលបត្រពីការរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្ម គោលនយោបាយ និងយន្តការដែលអនុញ្ញាតឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រធ្វើប្រតិបត្តិការធុរកិច្ចប្រកបដោយប្រសិទ្ធភាព និងអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធក្រោយការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ខ. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ក្រុមហ៊ុនផ្តល់សេវាសវនកម្មមានតួនាទីដូចខាងក្រោម៖

- ផ្តល់សេវាសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ
- រៀបចំរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ
- ត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុក្នុងឯកសារផ្តល់ព័ត៌មានតាមការព្រមព្រៀង។

### គ. មេធាវី

មេធាវីមានតួនាទី៖

- ត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចតាមច្បាប់ និងរៀបចំរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ផ្នែកដែលពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ
- ផ្តល់យោបល់ជូនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនូវរាល់បញ្ហាពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់
- ផ្តល់យោបល់ផ្នែកច្បាប់ក្នុងការរៀបចំកិច្ចសន្យាធានាទិញ
- ផ្តល់យោបល់ជូនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រអំពីអភិបាលកិច្ចសាជីវកម្ម និងលក្ខខណ្ឌតម្រូវផ្នែកច្បាប់ផ្សេងទៀត។

➢ **ជំហានទី៣៖ ការពិនិត្យលទ្ធភាពអាចចុះបញ្ជី**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

➢ **ជំហានទី៤៖ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូន ន.ម.ក.។ ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក. ក្រុមហ៊ុនត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រ និងស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក.។ បន្ទាប់មកទៀតក្រុមហ៊ុនបោះផ្សាយលក់មូលបត្រត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ និងរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រជូន ន.ម.ក.។

➢ **ជំហានទី៥៖ ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ។

### ៣.២.៣. ការរៀបចំឯកសារផ្តល់ព័ត៌មាន

ឯកសារផ្តល់ព័ត៌មាន សំដៅដល់លិខិតជូនដំណឹង ឬសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ ឬជាការអញ្ជើញឲ្យទិញ ឬសំណើឲ្យគេដាក់ពាក្យសុំទិញ ឬទិញមូលបត្រ ឬប្រកាសអំពីការដាក់លក់ ឬការលក់មូលបត្រ។ ឯកសារផ្តល់ព័ត៌មានរួមមានព័ត៌មានដូចខាងក្រោម៖

១. ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២. ព័ត៌មានស្តីពីកត្តាហានិភ័យ

៣. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤. ផែនការវិនិយោគ

៥. ការពិពណ៌នាអំពីធុរកិច្ច

៦. ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧. ការពិពណ៌នាអំពីអចលកម្មរូបីរបស់ក្រុមហ៊ុនបោះផ្សាយ

៨. ការវាយតម្លៃទ្រព្យសកម្ម និង/ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០. ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១. ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២. ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣. សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឲ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥. ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦. កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧. ការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់

១៨. សិទ្ធិរបស់កម្មសិទ្ធករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩. ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬ ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

### ៣.២.៤.ឯកសារភ្ជាប់ដើម្បីដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា

#### ៣.២.៤.១. ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម៖

១. លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤. លិខិតប្រគល់សិទ្ធិឲ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយដែលចុះហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥. កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦. កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនបើមាន។

៧. ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលតិចជាង១ឆ្នាំ។

៨. លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹង មូលបត្រស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩. កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤. កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនបើមាន។

១៥. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធ នឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យជំនាញ ដែលទទួលបានការទទួលស្គាល់ពី ន.ម.ក. ករណីរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងចំណុចទី៣ នៃប្រការ៤នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យ ដែលមិនមានការទទួលស្គាល់ពី ន.ម.ក.។

១៦. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ ន.ម.ក.។

១៧. ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**៣.២.៤.២. ពាក្យស្នើចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា**

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារដូចខាងក្រោម៖[75]

១- ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ ន.ម.ក.។

២- ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣- ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤- ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥- របាយការណ៍បែងចែកមូលបត្រ។

៦- លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

[75] ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ លេខ ០០៦/១៥ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ប្រការ ១០

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលដែលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ ទៅតាមគំរូដែលទទួលបានការអនុញ្ញាតពី ន.ម.ក.។ កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រនេះមានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

### ៣.២.៥. **ការកំណត់ថ្លៃលក់មូលបត្រតាមរយៈការធ្វើប៊ុកបៀលឌីង** (Book Building)

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការកំណត់ថ្លៃលក់មូលបត្រ ដែលអាចធ្វើឡើងតាមរយៈការធ្វើប៊ុកបៀលឌីង ឬតាមការសម្រេចផ្សេងពីនេះ ដោយអគ្គនាយកនៃ ន.ម.ក. តាមការស្នើសុំរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ការធ្វើប៊ុកបៀលឌីង ជាដំណាក់កាលស្ទាបស្ទង់ថ្លៃ ដែលធ្វើឡើងរវាងក្រុមហ៊ុនបោះផ្សាយមូលបត្រ និងវិនិយោគិនដែលស្ថិតក្រោមជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ គោលបំណងសំខាន់នៃការធ្វើប៊ុកបៀលឌីងគឺដើម្បីធានាបាននូវថ្លៃមួយដែលមានតម្លាភាព និងដើម្បីធានាថា ថ្លៃមូលបត្រកម្មសិទ្ធិបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ។ មូលបត្រដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីង មានចំនួន ៧០ % នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបម្រុងទុកសម្រាប់បុគ្គលិក (ក្នុងករណីក្រុមហ៊ុនមានគោលនយោបាយលើកទឹកចិត្តតាមរយៈការលក់ជូនបុគ្គលិក) និង៣០%ទៀត ត្រូវលៃបម្រុងទុកសម្រាប់ការធ្វើបរិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

វិនិយោគិនដែលមានបំណងចូលរួមក្នុងដំណាក់កាលប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីងដែលកំណត់ដោយ ន.ម.ក. និងត្រូវតម្កល់ប្រាក់កក់យ៉ាងតិចស្មើនឹង ១០% នៃថ្លៃមូលបត្រកម្មសិទ្ធិសរុប។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយ ក្នុងចន្លោះថ្លៃនៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតពី ន.ម.ក. ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិ ដែលមានបំណងចង់ធ្វើបរិសកម្ម។

បន្ទាប់ពីការធ្វើប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ហើយថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់នេះ ត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ ដើម្បីស្នើសុំការសម្រេចពី ន.ម.ក. ដោយភ្ជាប់មកជាមួយបញ្ជីឈ្មោះវិនិយោគិនដែលបានចូលរួម។ វិនិយោគិនដែលទទួលជោគជ័យក្នុង ប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់។

ជាចុងក្រោយ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យ និងមិនទទួលបានជោគជ័យ បន្ទាប់ពី ន.ម.ក. បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវផ្ទេរប្រាក់កក់ ១០% ជូនវិនិយោគិនដែលមិនទទួល បានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោគិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីងមានបំណងបន្តធ្វើបរិវិសកម្ម។

**៣.២.៦. ការធ្វើបរិវិសកកម្មមូលបត្រ** (Subscription)

បន្ទាប់ពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ។ ការធ្វើបរិវិសកម្មមូលបត្រ សំដៅដល់ដំណើរការនៃការស្នើសុំទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ សម្រាប់វិនិយោគិនដែលទទួលបានជោគជ័យ និងមិនទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីងត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ដោយត្រូវតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិ។ ចំណែកវិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្របានដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០% នៃទំហំមូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើបរិវិសកម្ម។

ក្នុងនោះដែរ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិការមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិ ជូនវិនិយោគិនដែលដាក់ពាក្យធ្វើ បរិវិសកម្មតាមវិធានប្រូរ៉ាតា (Pro Rata) ក្នុងករណីដែលមានការធ្វើបរិវិសកម្មលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីដែលមានវិនិយោគិនទទួលបានជោគជ័យមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ឬអាចដកប្រាក់កក់ ១០% វិញបាន។ ចំណែកវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ឬវិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្របាន ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០% នៃទំហំមូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើបរិវិសកម្ម។ ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះ មានចំនួនតិចជាងចំនួននៃមូលបត្រដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង វិនិយោគិនទាំងអស់ដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០%។ ករណីចំនួនមូលបត្រសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម មានចំនួនលើសពីចំនួននៃមូលបត្រដែលត្រូវបានលៃបម្រុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិការមូលបត្រត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិតាមវិធានប្រូរ៉ាតា (Pro Rata)។ បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុង

ករណីមានវិនិយោគិនមិនទទួលបានមូលបត្រកម្មសិទ្ធិ តាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការផ្ទេរសាច់ប្រាក់ ដែលនៅសល់ពីការធ្វើបរិវិសកម្ម ជូនវិនិយោគិនវិញ។ ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្ម នោះក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង។[76]

**៣.២.៧. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ**

**៣.២.៧.១. ថ្លៃសេវាលើក្រុមការងារ IPO**

**ក-** ថ្លៃសេវាលើក្រុមហ៊ុនធានាទិញមូលបត្រ៖ ថ្លៃសេវាប្រែប្រួលអាស្រ័យលើភាពស្មុគស្មាញនៃករណីនីមួយៗ។ វិធីសាស្ត្រដែលពេញនិយមប្រើ ដើម្បីទូទាត់កម្រៃសេវាដោយក្រុមហ៊ុនធានាទិញមូលបត្ររួមមាន៖

- ចំនួនទឹកប្រាក់សរុបឬ
- ភាគរយនៃសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយឬ
- ភាគរយទៅតាមការងារដែលសម្រេចបាន។

**ខ-** ថ្លៃសេវាលើក្រុមហ៊ុនផ្តល់សេវាសវនកម្ម

**គ-** ថ្លៃសេវាលើមេធាវី

**ឃ-** ថ្លៃសេវាលើក្រុមហ៊ុនវាយតម្លៃ។

**៣.២.៧.២. ថ្លៃសេវាលើការដាក់ពាក្យស្នើសុំ**

ក- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក.

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ១២.០០០.០០០ រៀល | ៦.០០០.០០០ រៀល |

*តារាងទី ៣.៣៖ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក.*

[76] និយ័តករមូលបត្រកម្ពុជា ពុទ្ធិមូលបត្រលេខ ១៧៖ ការធ្វើបរិវិសកម្មមូលបត្រ (Subscription) ២០១៦ ទំព័រទី១

**ខ- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក.**

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ៤.០០០.០០០ រៀល | ២.០០០.០០០ រៀល |

*តារាងទី ៣.៤៖ ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក.*

**គ- ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.**

**សម្រាប់ទីផ្សារគោល៖** ផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ០៛ ដល់ ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ១២.០០០.០០០.០០១៛ ដល់ ៤០.០០០.០០០.០០០៛ | ០,០៣០% |
| ៤០.០០០.០០០.០០១៛ ដល់ ២០០.០០០.០០០.០០០៛ | ០,០២៥% |
| ២០០.០០០.០០០.០០១៛ ដល់ ៤០០.០០០.០០០.០០០៛ | ០,០១៥% |
| លើសពី ៤០០.០០០.០០០.០០០៛ | ០,០១០% |

*តារាងទី ៣.៥៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.*

**សម្រាប់ទីផ្សារកំណើន៖** ៤.០០០.០០០ រៀល ឬ០,០២៥% នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដោយយកចំនួនណាមួយដែលធំជាងគេ។

**ឃ- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

**សម្រាប់ទីផ្សារគោល៖** ផ្អែកលើមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
| --- | --- |
| ០៛ ដល់ ១២.០០០.០០០.០០០៛ | ៣.០០០.០០០៛ |
| ១២.០០០.០០០.០០១៛ ដល់ ៤០.០០០.០០០.០០០៛ | ០,០២០% |
| ៤០.០០០.០០០.០០១៛ ដល់ ២០០.០០០.០០០.០០០៛ | ០,០១៥% |
| លើសពី ២០០.០០០.០០០.០០០៛ | ០,០០៥% |

*តារាងទី ៣.៦៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ*

**សម្រាប់ទីផ្សារកំណើន៖** ៤.០០០.០០០ រៀល ឬ០,០១៥% នៃមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយដែលធំជាង។

### ៣.២.៧.៣. ថ្លៃសេវាផ្សេងៗ

- ថ្លៃសេវារក្សាទុកមូលបត្រកម្មសិទ្ធ
- ថ្លៃសេវាភ្នាក់ងារបញ្ជិកាមូលបត្រ
- ចំណាយលើការបោះពុម្ពឯកសារផ្ដល់ព័ត៌មាន
- ថ្លៃសេវាលើអ្នកជំនាញ
- ចំណាយលើទំនាក់ទំនងសាធារណៈ។

## ៣.៣. ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈលើកដំបូង

### ៣.៣.១. ប្រភេទមូលបត្របំណុលដែលធ្វើសំណើលក់

មូលបត្របំណុលដែលត្រូវធ្វើសំណើលក់ សំដៅដល់សញ្ញាបណ្ណសាជីវកម្ម ដែលរួមមាន៖

១. សញ្ញាបណ្ណធម្មតា ( Plain Bond) សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុន នៅកាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រលប់ (Call Option) ឬ សិទ្ធិលក់ (Put Option) និងមិនមានការធានា។

២. សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond) សំដៅដល់សញ្ញាបណ្ណដែលផ្ដល់ការធានាថាការប្រាក់ និងប្រាក់ដើម នឹងត្រូវបានទូទាត់សងដោយភាគីទីបី ដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជាអសាធនភាព ឬក្ស័យធន។

៣. សញ្ញាបណ្ណមានវត្ថុធានា (Secured Bond) សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែមូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។[77]

### ៣.៣.២. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

#### ៣.៣.២.១. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណធម្មតា

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១. ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

២. មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុល ជាសាធារណៈ ទៅតាមការសម្រេចចិត្តរបស់មហាសន្និបាតភាគហ៊ុនិក។

៣. មានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញប្រវត្តិសាស្ត្ររួម រយៈពេល២ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ នៅក្រោយរយៈពេល៤៥ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤. មានកម្រិតអភិបាលកិច្ចសាជីវកម្មរឹងមាំ ដោយមានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់

៥. ទទួលបានការធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក។

៦. ទទួលបានការបញ្ជាក់ជាមុនអំពីការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល និងការដាក់តម្លៃមូលបត្របំណុលពីទីផ្សារមូលបត្រប្រតិស្រុត។

#### ៣.៣.២.២. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា

ករណីការបោះផ្សាយលក់សញ្ញាប័ណ្ណមានវត្ថុធានា បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១. បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៣.២.២.១.។

២. មានវត្ថុធានា ដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានវិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

---

[77] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ លេខ០០៩/១៧ គ.ម.ក. /ប្រ.ក. ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧

- ករណីវត្ថុធានាជាអចលនវត្ថុ ឬសិទ្ធិជួលអចិន្ត្រៃយ៍ តម្លៃនៃវត្ថុធានានោះត្រូវវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី គ.ម.ក។

៣. ចំនួនទឹកប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវមានតម្លៃអតិបរមាស្មើនឹង ៧០ភាគរយ នៃតម្លៃវត្ថុធានា គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

**៣.៣.២.៣. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១. បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៣.២.២.១. លើកលែងតែចំណុចទី៥។

២. ត្រូវមានបុគ្គលធានាដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ហើយបុគ្គលធានានោះត្រូវធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក។

**៣.៣.៣. ឯកសារប្រើសម្រាប់ស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវមាន៖

១-ពាក្យស្នើសុំបំពេញតាមទម្រង់កំណត់ដោយ គ.ម.ក. ។

២-ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ គ.ម.ក. ។

៣-ឯកសារភ្ជាប់ដូចខាងក្រោម៖

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ខ-លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

គ-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ឃ-លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃបុគ្គលបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

ង-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជា ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រស្តីពីការបើកគណនីដាច់ដោយឡែក សម្រាប់គោលបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ច-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹង កិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ក្នុងករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៦ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈត្រូវបានធ្វើសវនកម្ម ដោយក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលមិនមានការទទួលស្គាល់ពី គ.ម.ក។

ឆ-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

ជ-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវី ដែលមានគុណវុឌ្ឍិទទួលស្គាល់ពី គ.ម.ក. ។

ឈ-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ។

ញ-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ ដែលមាន។

ដ- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនមាន។

ឋ-កិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញជាមួយក្រុមហ៊ុនធានាទិញមូលបត្រ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឌ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឍ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ណ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ត-ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

ថ- ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលនោះត្រូវ ភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម៖

ថ.១-ភ័ស្តុតាងអំពីវត្ថុធានា។

ថ.២-វិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

ថ.៣-របាយការណ៍ស្តីពីការវាយតម្លៃទ្រព្យសកម្ម ដែលចេញដោយក្រុមហ៊ុនវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក.។

ទ- ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម៖

ទ.១-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

ទ. ២- កិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

ធ- ឯកសារផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ គ.ម.ក. ។

**៣.៣.៤. ឯកសារផ្តល់ព័ត៌មាន**

ឯកសារផ្តល់ព័ត៌មានត្រូវមានមាតិកាអប្បបរមាដូចខាងក្រោម៖

១. សេចក្តីជូនដំណឹងចំពោះវិនិយោគិន។

២. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយ។

៣. អត្តសញ្ញាណនៃបុគ្គលពាក់ព័ន្ធនឹងការរៀបចំឯកសារផ្តល់ព័ត៌មាន។

៤. និយមន័យ អក្សរកាត់ និងពាក្យបច្ចេកទេស។

៥. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន។

៦. ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧.ព័ត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៨. ព័ត៌មានទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩. ព័ត៌មានស្តីពីប្រតិបត្តិការ ដោយរួមបញ្ចូលទាំងយុទ្ធសាស្ត្រ និងផែនការធុរកិច្ច។

១០. ព័ត៌មានស្តីពីកត្តាហានិភ័យ។

១១. ព័ត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម។

១២. ព័ត៌មានស្តីពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

១៣. ព័ត៌មានហិរញ្ញវត្ថុ និង/ឬព័ត៌មានហិរញ្ញវត្ថុរួម។

១៤. ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ។

១៥. ព័ត៌មានផ្សេងៗ។

១៦. ឧបសម្ព័ន្ធ។

ឯកសារផ្តល់ព័ត៌មានត្រូវមានសេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បុគ្គលដាក់ពាក្យស្នើសុំ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

### ៣.៣.៥. ការធ្វើបរិវិសកម្ម

បុគ្គលដាក់ពាក្យស្នើសុំ បន្ទាប់ពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ គ.ម.ក. ការធ្វើបរិវិសកម្មមូលបត្របំណុល ត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព។ នៅពេលការធ្វើបរិវិសកម្មមូលបត្របំណុល ត្រូវបានបញ្ចប់ពេញលេញ បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មមូលបត្របំណុលនោះភ្លាមមក គ.ម.ក.។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្ម ក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជ។ បញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មមូលបត្របំណុលត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មនឹងត្រូវកំណត់ដោយ គ.ម.ក។ ការធ្វើបរិវិសកម្មនីមួយៗ ត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។

### ៣.៣.៦. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ

ក- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ **ន.ម.ក.**៖ ជាប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល។

ខ- សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬ ឯកសារផ្តល់ព័ត៌មានជំនួសនៅ **ន.ម.ក.**៖ ជាប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល។

គ- សោហ៊ុយសិក្សាចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព នៅ **ន.ម.ក.**៖ ជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

ឃ- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុល នៅ ផ.ម.ក.៖ ជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ឬ 0,0១% (សូន្យក្បៀសសូន្យមួយភាគរយ) នៃតម្លៃមូលបត្របំណុលសរុបដែលបានបោះផ្សាយ ដោយយកចំនួនណាមួយដែលធំជាង និងថ្លៃអតិបរមាមិនលើសពី ១០.០០០.០០០ (ដប់លាន) រៀល។ ថ្លៃសេវានេះត្រូវបង់មុនពេលចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ។

ង- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំ នៅ ផ.ម.ក.៖ ជាប្រាក់ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល។[78]

[78] ប្រកាសស្តីពីការដាក់អោយអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ០១៦/១៧ គ.ម.ក. / ប្រ.ក.ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧

## ៣.៤. និន្នាការទូទៅនៃការបោះផ្សាយលក់មូលបត្រ

### ៣.៤.១. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ

#### ៣.៤.១.១. ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ

យោងទៅតាមគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចាប់តាំងពីឆ្នាំ ២០១២ រហូតមកដល់ត្រឹមឆ្នាំ២០២១ មានក្រុមហ៊ុនចំនួន ៨ ដែលបានបោះផ្សាយ និងចុះញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ដែលរួមមានដូចខាងក្រោម៖[79]

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)៖ ចុះបញ្ជីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI) ៖ ចុះបញ្ជីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤
- កំពង់ផែស្វយ័តភ្នំពេញ (PPAP)៖ ចុះបញ្ជីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥
- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSEZ)៖ ចុះបញ្ជីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)៖ ចុះបញ្ជីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧
- ធនាគារ អេស៊ីលីដា ភីអិលស៊ី (ABC)៖ ចុះបញ្ជីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០
- ផេសចិក (ខេមបូឌា) ម.ក (PEPC)៖ ចុះបញ្ជីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០
- ក្រុមហ៊ុន ឌីប៊ីឌី អ៊ីនជីនារីង ម.ក (DBDE)៖ ចុះបញ្ជីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១

| ឆ្នាំ | ចំនួនក្រុមហ៊ុនបោះផ្សាយ |
|---|---|
| ២០១២ | ១ |
| ២០១៣ | 0 |
| ២០១៤ | ១ |
| ២០១៥ | ១ |
| ២០១៦ | ១ |
| ២០១៧ | ១ |
| ២០១៨ | 0 |
| ២០១៩ | 0 |
| ២០២០ | ២ |
| ២០២១ | ១ |

*តារាង៣.៧៖ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធ*

[79] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២)




*ក្រាបទី៣.១៖ ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ*

**បកស្រាយ៖** តាមក្រាបខាងលើ យើងសង្កេតឃើញថា នៅឆ្នាំ២០១២ ២០១៤ ២០១៥ ២០១៦ ២០១៧ និងឆ្នាំ២០២១ គឺមានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិតែមួយប៉ុណ្ណោះក្នុងឆ្នាំនីមួយៗ ដោយឡែកក្នុងឆ្នាំ ២០២០ វិញគឺមានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីចំនួនពីរក្រុមហ៊ុន។ ប៉ុន្តែនៅក្នុងឆ្នាំ ២០១៣ ២០១៨ និងឆ្នាំ ២០១៩ វិញ គឺមិនមានក្រុមហ៊ុនណាមួយបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិទេ។

### ៣.៤.១.២. តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង និងចំនួនហ៊ុនដែលបានបោះផ្សាយ

| ឈ្មោះក្រុមហ៊ុន | និមិត្តសញ្ញា | តម្លៃបោះផ្សាយលក់ភាគហ៊ុន | ចំនួនហ៊ុនដែលបោះផ្សាយ |
|---|---|---|---|
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | PWSA | ៦.៣០០រៀល | ១៣.០៤៥.៩៧៥ |
| ក្រុមហ៊ុន ហ្គ្រេនធ្វីនអ៊ិនធើណេសិនណល | GTI | ៩.៦៥០ រៀល | ៨.០០០.០០០ |
| កំពង់ផែស្វយ័តក្រុងភ្នំពេញ | PPAP | ៥.១២០ រៀល | ៤.១៣៦.៨៧៣ |
| ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ី | PPSP | ២.៨៦០ រៀល | ១១.៥៧៥.០០០ |
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ | PAS | ៥.០៤០ រៀល | ២១.៤៤២.៩៩២ |
| ធនាគារអេស៊ីលីដា | ABC | ១៦.២០០ រៀល | ៤.៣៤៤.៨៦៥ |
| ផេសចិក (ខេមបូឌា) ម.ក | PEPC | ៣.១២០ រៀល | ៣.៩៤៥.០០០ |
| ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ីនជីនារីង ម.ក | DBDE | ២.៣៨០ រៀល | ៦.៤៦១.៥៣៨ |

*តារាង៣.៨៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈដំបូង និងចំនួនហ៊ុនដែលបានបោះផ្សាយ*




*ក្រាបទី៣.២៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និង ចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង*

**បកស្រាយ៖** តាមក្រាបខាងលើ យើងសង្កេតឃើញថា ធនាគារ អេស៊ីលីដា ភីអិលស៊ី មានតម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងខ្ពស់ជាងគេ គឺមានតម្លៃ ១៦.២០០រៀល ក្នុងមួយហ៊ុន ហើយក្រុមហ៊ុនដែលមានតម្លៃបោះផ្សាយលក់ទាបជាងគេវិញនោះគឺក្រុមហ៊ុន ឌីប៊ីឌី អ៊ីនជីនារីង ម.ក (DBDE) ដែលមានតម្លៃត្រឹមតែ ២.៣៨០រៀល។ ដោយឡែក ចំពោះក្រុមហ៊ុនដែលបានធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងច្រើនហ៊ុនជាងគេគឺ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលបានធ្វើការបោះផ្សាយចំនួន ២១.៤៤២.៩៩២ ហ៊ុន នៅពេលដែលក្រុមហ៊ុនដែលបានបោះលក់តិចជាងគេគឺ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ដែលបានបោះផ្សាយ ចំនួន ៣.៩៤៥.០០០ ហ៊ុន។

### ៣.៤.២. ការបោះផ្សាយលក់មូលបត្របំណុល

#### ៣.៤.២.១. ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល

យោងទៅតាមគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចាប់តាំងពីឆ្នាំ ២០១៨ រហូតមកដល់ត្រឹមឆ្នាំ២០២១ មានក្រុមហ៊ុនចំនួន ៧ ដែលបានបោះផ្សាយ និងចុះញ្ជីលក់មូលបត្របំណុលនៅ ផ.ម.ក. ដែលរួមមានដូចខាងក្រោម៖[80]

– គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត៖ ចុះបញ្ជីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨
– គ្រឹះស្ថានហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី៖ ចុះបញ្ជីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩
– ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ ៖ ចុះបញ្ជីថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១៩

[80] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២)

- ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.កៈ ចុះបញ្ជីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០
- អ អិម អេ (ខេមបូឌា) ម.កៈ ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០២០
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.កៈ ថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០២០
- ក្រុមហ៊ុន តែលកូថេកៈ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០២១

| ឆ្នាំ | ចំនួនក្រុមហ៊ុនបោះផ្សាយមូលបត្របំណុល |
|---|---|
| ២០១៨ | ១ |
| ២០១៩ | ២ |
| ២០២០ | ៣ |
| ២០២១ | ១ |

*តារាង៣.៩៖ ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល*




*ក្រាបទី៣.៣៖ ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល*

**បកស្រាយ៖** តាមក្រាបខាងលើ យើងសង្កេតឃើញថានៅក្នុងឆ្នាំ ២០១៨ មានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុល ចំនួន មួយក្រុមហ៊ុន ហើយឆ្នាំ ២០១៩ មានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុលចំនួន ពីរក្រុមហ៊ុន ចំណែកនៅឆ្នាំ២០២០ មានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុល ដល់ទៅបីក្រុមហ៊ុន ដែលជាឆ្នាំដែលក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុលច្រើនជាងឆ្នាំផ្សេង ចំណែកឯនៅក្នុងឆ្នាំ ២០២១ វិញនោះគឺមានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុលតែមួយប៉ុណ្ណោះ។

### ៣.៤.២.២. ចំនួនបោះផ្សាយលក់មូលបត្របំណុលជា (ឯកតា) អត្រាគូប៉ុងប្រចាំឆ្នាំ និងរយៈពេលឥណប្រតិទាន

*តារាង៣.១០. ចំនួនបោះផ្សាយលក់មូលបត្របំណុលជា (ឯកតា) អត្រាគូប៉ុងប្រចាំឆ្នាំ និងរយៈពេលឥណប្រតិទាន*

| ឈ្មោះក្រុមហ៊ុន | និមិត្តសញ្ញា | ចំនួនឯកតា | អត្រាគូប៉ុងប្រចាំឆ្នាំ | រយៈពេលឥណប្រតិទាន |
|---|---|---|---|---|
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត | HKL21A | ១០០.០០០ | ៨,៥%ក្នុងមួយឆ្នាំ | ៣ឆ្នាំ |
| គ្រឹះស្ថានហិរញ្ញវត្ថុ អិលអូ អិលស៊ី ភីអិលស៊ី | LOLC22A<br>LOLC22B | ៥៣៦.០០០<br>២៦៤.០០០ | ៨,០០%ក្នុងមួយឆ្នាំ<br>៩,០០%ក្នុងមួយឆ្នាំ | ៣ឆ្នាំ<br>៣ឆ្នាំ |
| ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | ABAA22A | ៨៤៨.២១០ | ៧,៧៥%ក្នុងមួយឆ្នាំ | ៣ឆ្នាំ |
| ធនាគារភ្នំពេញពាណិជ្ជ ម.ក | PPCB23A<br>PPCB23B | ៤០០.០០០<br>៤០០.០០០ | ៦,៥០%ក្នុងមួយឆ្នាំ<br>៦,៥០%ក្នុងមួយឆ្នាំ | ៣ឆ្នាំ<br>៣ឆ្នាំ |
| ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក | RMAC25A | ៨០០.០០០ | ៥,៥០%ក្នុងមួយឆ្នាំ | ៥ឆ្នាំ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | PRA23A | ១.២៧២.០០០ | ៧,៥០%ក្នុងមួយឆ្នាំ | ៣ឆ្នាំ |
| ក្រុមហ៊ុនតេលេកូថេក | TCT26A | ៨០០.០០០ | ៧,៥០%ក្នុងមួយឆ្នាំ | ៥ឆ្នាំ |




*ក្រាបទី៣.៤៖ ចំនួនមូលបត្របំណុលដែលបោះផ្សាយ, អត្រាគូប៉ុងប្រចាំឆ្នាំ និង រយៈពេលឥណប្រតិទាន*

**បកស្រាយ៖** យោងតាមទិន្នន័យចំនួនបោះផ្សាយលក់មូលបត្របំណុល អត្រាគូប៉ុងប្រចាំឆ្នាំ និងរយៈពេលឥណប្រតិទានពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២១ យើងសង្កេតឃើញថា ចំនួនឯកតានៃមូលបត្របំណុលដែលបានបោះលក់គឺនៅចន្លោះពី ១០០.០០០ ឯកតា ទៅ ១.២៧២.០០ ឯកតា ពោលគឺ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ បានបោះលក់មូលបត្របំណុលតិចជាងគេ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ បានបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈលើកដំបូងច្រើនជាងគេ គឺមានចំនួនដល់ទៅ ១.២៧២.០០០ឯកតា។ បើក្រឡេកមើលទៅលើអត្រាគូប៉ុងវិញ គឺត្រូវបានផ្តល់ឲ្យនៅចន្លោះពី ៥,៥០% ទៅ ៩,០០% ក្នុងមួយឆ្នាំ។ ក្រុមហ៊ុន RMA បានផ្តល់ឲ្យនូវអត្រាទាបជាងគេត្រឹមតែ ៥,៥០% ហើយគ្រឹះស្ថានហិរញ្ញវត្ថុ អិលអូអិលស៊ី ជាគ្រឹះស្ថានមួយដែលបានផ្តល់នូវអត្រាគូប៉ុងខ្ពស់ជាងគេ។ ដោយឡែក ចំពោះរយៈពេលឥណប្រតិទានភាគច្រើនមានរយៈពេល៣ឆ្នាំ លើកលែងតែក្រុមហ៊ុន RMA និងក្រុមហ៊ុនតេលកូថេក ដែលបានខ្ចីរយៈពេលវែងជាងគេរហូតទៅដល់ ៥ ឆ្នាំ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានបញ្ចប់ការធ្វើការស្រាវជ្រាវក្រោមប្រធានបទស្តីពី "ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅកម្ពុជារួចមក" យើងខ្ញុំបានសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាពិតជាមានការយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជាច្រើនឆ្នាំមកនេះ ក្នុងការបង្កើត និងអភិវឌ្ឍវិស័យមូលបត្រកម្ពុជា ឲ្យមានការរីកចម្រើនមកដល់សព្វថ្ងៃនេះ។ ដោយគិតមកដល់បច្ចុប្បន្ន វិស័យមូលបត្រនៅកម្ពុជា ទើបតែមានរយៈពេលជាង ១០ឆ្នាំ តែប៉ុណ្ណោះ។ ក្នុងនោះដែររាជរដ្ឋាភិបាល បានបង្កើតឲ្យមាននូវនិយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងតួអង្គពាក់ព័ន្ធដ៏ទៃទៀត ដែលបានជួយសម្រួលក្នុងដំណើរការបោះផ្សាយ និងជួញដូរមូលបត្រនៅលើទីផ្សារ។

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងត្រូវត្រៀមរៀបចំខ្លួនជាមុន ដើម្បីបំពេញតាមកាតព្វកិច្ចតាមផ្លូវច្បាប់ ពង្រឹងប្រព័ន្ធគណនេយ្យស្របតាមស្តង់ដាគណនេយ្យ រៀបចំអភិបាលកិច្ចសាជីវកម្ម រៀបចំផែនការសម្រាប់ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយ រៀបចំឯកសារផ្តល់ព័ត៌មានដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងលក្ខខណ្ឌតម្រូវ និងឯកសារមួយចំនួនតាមការតម្រូវរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា ក្នុងនោះដែរក៏ត្រូវបង្កើតក្រុមការងារបោះផ្សាយ ដើម្បីជួយសម្រួលក្នុងដំណើរការបោះផ្សាយផងដែរ។ ដើម្បីឲ្យដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈមានភាពរលូន ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាបុគ្គលពាក់ព័ន្ធគប្បីស្វែងយល់ពីដំណើរការនេះឲ្យបានច្បាស់លាស់ និងអនុវត្តតាមយន្តការនៃការបោះផ្សាយលក់មូលបត្រ ចំនួន១២ដំណាក់កាល។

សរុបសេចក្តីមកដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង មានលក្ខខណ្ឌតម្រូវ និងឯកសារដែលត្រូវបំពេញច្រើន ប៉ុន្តែមិនសូវជាស្មុគស្មាញប៉ុន្មានទេ សម្រាប់ក្រុមហ៊ុនដែលមានតម្លាភាព និងស្តង់ដាត្រឹមត្រូវ។ ផ្ទុយមកវិញក្រុមហ៊ុន/សហគ្រាស អាចទទួលបានមកវិញនូវអត្ថប្រយោជន៍ជាច្រើន ដូចជាទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង ការលើកទឹកចិត្តផ្នែកពន្ធ និរន្តរភាពអាជីវកម្មជាមួយអភិបាលកិច្ចសាជីវកម្ម ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងសក្តានុពលរបស់ក្រុមហ៊ុន ការបំពេញនូវកាតព្វកិច្ចច្បាប់បានត្រឹមត្រូវ។ ដោយឡែក វិស័យមូលបត្រនេះ ក៏កំពុងតែមានការរីចម្រើនទៅមុខជាលំដាប់ ដោយមានការចាប់អារម្មណ៍ និងចូលរួមពីក្រុមហ៊ុន/សហគ្រាស ដែលមានបំណងទទួលបានហិរញ្ញប្បទានរយៈពេលវែងតាមរយៈទីផ្សារមូលបត្រ ដែលគិតត្រឹមឆ្នាំ២០២១ គឺមានក្រុមហ៊ុនដែលបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធមានចំនួន ៨ក្រុមហ៊ុន និងក្រុមហ៊ុនដែលបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុល មានចំនួន ៧ក្រុមហ៊ុន។

## ២. ការផ្តល់អនុសាសន៍

ជាចុងក្រោយ បន្ទាប់ពីបានសិក្សានូវប្រធានបទខាងលើ យើងខ្ញុំពិតជាឃើញថា ការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារដំបូងនៅកម្ពុជា កំពុងអភិវឌ្ឍបានយ៉ាងល្អប្រសើរ ក៏ប៉ុន្តែទន្ទឹមនឹងនេះ យើងក៏បានឃើញថានៅមានចំណុចខ្វះខាតមួយចំនួន ដែលនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គប្បីគួរធ្វើការពិចារណាផងដែរ។ យើងខ្ញុំសូមធ្វើការអនុញ្ញាត ក្នុងការផ្តល់ជាគំនិតយោបល់ខ្លះៗ ដើម្បីជាជំនួយជួយឲ្យវិស័យមូលបត្រនៅកម្ពុជា ក៏ដូចជាដំណើរការបោះផ្សាយលក់មូលបត្រនៅកម្ពុជា ឲ្យរឹតតែមានការរីកចម្រើនទៅមុខ៖

- និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បន្តរិះរកយុទ្ធសាស្ត្រល្អៗ ដូចជាផ្តល់រង្វាន់លើកទឹកចិត្ត កាត់បន្ថយឯកសារមិនចាំបាច់មួយចំនួន និងកាត់បន្ថយថ្លៃសេវាលើការដាក់ពាក្យស្នើសុំ និងចុះបញ្ជីលក់មូលបត្រ ដើម្បីទាក់ទាញក្រុមហ៊ុន/សហគ្រាស ឲ្យមកចូលរួមក្នុងទីផ្សារ តាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ ក៏ដូចជាមូលបត្របំណុល។
- បន្តធ្វើការផ្សព្វផ្សាយបន្ថែមទៀត រៀបចំកម្មវិធីសិក្ខាសាលា ឬកម្មវិធីផ្សេងៗ ដែលស្តីអំពីការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារដំបូងនៅកម្ពុជា ជាពិសេសក្នុងដំណាក់កាលធ្វើប៊ុកបៀលឌីង និងដំណាក់កាលធ្វើបរិសកម្ម ដើម្បីឲ្យវិនិយោគិន ឬក្រុមហ៊ុនបានយល់ឲ្យកាន់តែច្បាស់ពីដំណើរការនេះ។

# ឯកសារយោង

# ឯកសារយោង

- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ០០៥/១៥ គ.ម.ក. /ប្រ.ក.ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ លេខ០០៩/១៧ គ.ម.ក. /ប្រ.ក.ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧
- ប្រកាសស្តីពីការដាក់អោយអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ ០១៦/១៧ គ.ម.ក. /ប្រ.ក.ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧
- បៀន សាំង (២០១១) មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ប្រភេទសញ្ញាបណ្ណសាជីវកម្ម (http://www.csx.com.kh/kh/product/bond.jsp?MNCD=4040)
- ប្រភេទនៃមូលបត្រកម្មសិទ្ធិ (http://www.csx.com.kh/kh/product/equities.jsp?MNCD=4020)
- និយមន័យទីផ្សារមូលបត្រ (http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1)
- ទីផ្សារដំបូង (http://tinyurl.com/22n5veux)
- ទីផ្សារបន្ទាប់ (http://tinyurl.com/22n5veux)
- និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m13.php?pn=1)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (http://csx.com.kh/news/faq/listPosts.do?MNCD=7060)
- អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន (http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 )
- អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ (http://csx.com.kh/kh/product/blisting.jsp?MNCD=3010)
- អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ (http://www.secc.gov.kh/khmer/faq.php?pn=2
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា bond_listing_rules.pdf
- ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (http://csx.com.kh/kh/about/profile.jsp?MNCD=10301)
- ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក. (http://csx.com.kh/kh/about/director.jsp?MNCD=1030 )
- ក្រុមហ៊ុនធានាទិញមូលបត្រ (https://www.serc.gov.kh/khmer/m52.php?pn=6)

- ក្រុមហ៊ុនពាណិជ្ជកម្មូលបត្រ (http://www.secc.gov.kh/khmer/m52.php?pn=6)
- ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ (http://www.secc.gov.kh/khmer/m52.php?pn=6)
- ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ (https://www.serc.gov.kh/khmer/m52.php?pn=6)
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004)
- ក្រុមហ៊ុនហ្គ្រេនធ្វីនអ៊ិនធើណេសិនណល (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000020003)
- កំពង់ផែស្វយ័តភ្នំពេញ (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000040001)
- ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតអ៊ីអិលស៊ី (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009)
- ធនាគារអេស៊ីលីដា (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003)
- ក្រុមហ៊ុនផេសចិក(ខេមបូឌា) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009)
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត https://hkl.com.kh/kh/detail/view/253/34?ctype=article
- គ្រឹះស្ថានហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី http://www.csx.com.kh/data/dbond/listPosts.do?lang=kh&MNCD=50203&issueCode=KH2000081953
- ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ https://www.ababank.com/km/about-us/
- ធនាគារភ្នំពេញពាណិជ្ជ "ភីភីស៊ីប៊ែង" ម.ក https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/
- អ អិម អេ (ខេមបូឌា) ម.ក

https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក https://economy.ams.com.kh/find-out-about-the-6-companies-that-sell-bonds-on-the-cambodia-securities-exchange/
- ក្រុមហ៊ុន តែលកូថេក http://www.csx.com.kh/company/announce/viewPost.do?MNCD=50104&postId=1176#.Yjw_aedBztQ
- តួអង្គចូលរួមដទៃទៀត (http://www.secc.gov.kh/khmer/m59.php?pn=6)
- ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកកម្មមូលបត្រ (https://tinyurl.com/nz6mchk6)
- ទីផ្សារគោល (http://csx.com.kh/kh/product/mainboard.jsp?MNCD=30102)
- ទីផ្សារកំណើន(http://csx.com.kh/kh/product/growthboard.jsp?MNCD=30103)
- ភាគីពាក់ព័ន្ធក្នុងដំណើរការចុះបញ្ជី (http://csx.com.kh/kh/product/mainboard.jsp?MNCD=30102)
- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រក្នុងទីផ្សារគោល (http://csx.com.kh/kh/product/mainboard.jsp)
- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រក្នុងទីផ្សារកំណើន (http://csx.com.kh/kh/product/growthboard.jsp?MNCD=30103)
- និយ័តករមូលបត្រកម្ពុជា មគ្គុទេសក៏ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២០១៧
- និយ័តករមូលបត្រកម្ពុជា ពុទ្ធិមូលបត្រលេខ ១៧៖ ការធ្វើបរិវិសកម្មមូលបត្រ (Subscription) ២០១៦
- ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (http://csx.com.kh/data/lstcom/listPosts.do?MNCD=50101)
- ចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល (http://csx.com.kh/data/lstcom/listPosts.do?MNCD=50101)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ០០៥/១៥ គ.ម.ក. /ប្រ.ក. ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥

ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ លេខ០០៩/១៧ គ.ម.ក. /ប្រ.ក. ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧

ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពីការដាក់អោយអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ០១៦/១៧ គ.ម.ក. /ប្រ.ក.ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧

ឧបសម្ព័ន្ធទី៤៖ ប្រកាសស្តីពីការដាក់អោយអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ០០៦/១៥ គ.ម.ក. /ប្រ.ក. ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥

# ឧបសម្ព័ន្ធទី១៖ ប្រកាសស្តីពីការ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ......០០៥/១៥..........គ.ម.ក/ប.ក.

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh,
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh,

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១- ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២- អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ÷

ក- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤- ក្រុមហ៊ុនសក្តានុពល សំដៅដល់ក្រុមហ៊ុនដែលមានលទ្ធភាពអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនដែលមានកំណើនខ្ពស់ ឬអាចមានកំណើនខ្ពស់។

៥- ក្រុមហ៊ុនហូលឌីង (Holding Company) សំដៅដល់ក្រុមហ៊ុនដែលកាន់កាប់បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ឬក្រុមហ៊ុនសម្ព័ន្ធ ដោយមានភាពជាម្ចាស់កម្មសិទ្ធិដោយកាន់កាប់ភាគហ៊ុនចំនួនច្រើន

ឬចំនួនតិចដែលមានសិទ្ធិបោះឆ្នោតគ្រប់គ្រាន់លើក្រុមហ៊ុនដែលកាន់កាប់។

៦-ភាគហ៊ុនបុរិមា (Preference share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៧-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៨-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

១០-ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១១-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១២-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូល-បត្រកម្មសិទ្ធិជាឯកជន÷

១-សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផល

ឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ **គ.ម.ក.**។

២- ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥- ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

### ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ÷

១- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ក្រុមហ៊ុនបោះផ្សាយត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៦ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម÷

១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២- ព័ត៌មានស្តីពីកត្តាហានិភ័យ

៣- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤- ផែនការវិនិយោគ

៥- ការពិពណ៌នាអំពីធុរកិច្ច

៦- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧- ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៨- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**ប្រការ ៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ រួមទាំងព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម÷

១- ឈ្មោះក្រុមហ៊ុនបោះផ្សាយ

២- ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣- តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤- ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៥- ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៦- កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧- សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម÷

១- ហានិភ័យហិរញ្ញវត្ថុ

២- ហានិភ័យសេដ្ឋកិច្ច

៣- ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៤- ហានិភ័យផ្សេងៗតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុនបោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

**ប្រការ ១១.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ១២.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា÷

១-កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

២-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៤-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៥-វិធីសាស្ត្រចែកចាយផលិតផល។

៦-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៧-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៨-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៩-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើរួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬសេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃចំនួនទឹកប្រាក់សរុបលើផលិតផល ឬសេវាទាំងអស់ដែលបានទិញដោយក្រុមហ៊ុនបោះផ្សាយ ដោយ

បញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១១- ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១២- ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១៣- សក្តានុពលនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៤- ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១- លទ្ធផលប្រតិបត្តិការ។

២- សន្ទនីយភាព និងប្រភពទុន។

៣- ការស្រាវជ្រាវ និងការអភិវឌ្ឍ។

៤- ព័ត៌មាននិន្នាការ និងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ ១៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម÷

១- ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មវត្ថុទាំងនោះ។

២- សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មវត្ថុទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មវត្ថុ។

៣- ការវាយតម្លៃលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលទទួល

បានការទទួលស្គាល់ពី **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ ប្រសិនមាន។

៤-ប្រសិនបើអចលកម្មរូបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៥.-**

ករណីមានការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ដោយបង្ហាញនូវ÷

១-ព័ត៌មានសង្ខេបពីការវាយតម្លៃ ឬការវាយតម្លៃឡើងវិញរួមមានតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ដោយត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

២-ហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។

៣-អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដូចខាងក្រោម÷

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអាណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៦-សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុន ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

ឯកសារផ្តល់ព័ត៌មានត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម÷

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ដែលបានកើតឡើងនៅក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំចុងក្រោយ ដូចខាងក្រោម÷

១-បណ្តឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដោយពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗ ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់ព័ន្ធ ដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ រួមទាំងអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីក្រុមហ៊ុនបោះផ្សាយ និងអភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

២-បុគ្គលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣- សមាជិកគ្រួសារផ្ទាល់របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤- បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥- បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះ-ផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម÷

១- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣- ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤- ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥- ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដោយត្រូវបញ្ជាក់នូវ÷

១- កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២- ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣- ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤- ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាននូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទ និងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោលក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីកម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើ

លក់ ដូចខាងក្រោម÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Information) និង/ ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Information) ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៧.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្ដល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្ដីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្ដល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្ដីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្ដល់ឱ្យនោះ។

**ប្រការ ២៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្ដល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្ដល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្ដល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ២៩ .-**

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម÷

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤-លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦-កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនមាន។

៧-ផែនការចុះកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ។

៨-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩-កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤-កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន។

១៥-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៤ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.** ។

១៦-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.** ។

១៧-ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ

**គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីក្រុមហ៊ុនបោះផ្សាយមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១-ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-ក្រុមហ៊ុនបោះផ្សាយស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។

៥-ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រប់គ្រាន់

ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្នុងរយៈពេល ២(ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៣.-**

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី÷

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី **គ.ម.ក.**។

**ប្រការ ៣៤.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៨ និងប្រការ ៣៩ នៃប្រកាសនេះ។

**ប្រការ ៣៥.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៦.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៧.-**

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់-

ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៨.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើចំពោះសំណើលក់មូលបត្រជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-លេខសេរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ។

**ប្រការ ៤១.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារ-

ណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៤.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្ញូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ព័ត៌មានសម្រាប់ផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៥.-**

រយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២-ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤-កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី **គ.ម.ក.** រួចហើយ។

៦-សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧-កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនឹងចាប់ផ្តើម។

៨-សេចក្តីថ្លែងដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមពីនេះក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិចឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៦.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២.០០០.០០០

(ដប់ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៧.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៩.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាដូចមានចែងក្នុងប្រការ ៤៦ ប្រការ ៤៧ និងប្រការ ៤៨ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនបោះផ្សាយវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**ប្រការ ៥០.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម÷

១- ការស្នើឱ្យដាក់អនុស្សារណៈ។

២- ការព្រមាន ឬដាស់តឿន។

៣- ការកត់សម្គាល់ជាសាធារណៈហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥១.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀលដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ ៥២.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួល

ដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូល-បត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៥៣.-**

ប្រកាសនេះត្រូវជំនួសប្រកាសលេខ ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៥៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយក-ដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់-ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្ចីជាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខៈ ០០៥/១៧........គ.ម.ក./ប្រ.ក

# ប្រកាស
# ស្តីពី
# ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

### សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ យន្តការ បែបបទ នីតិវិធី និងការអនុញ្ញាត ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១- ខ្ទង់ក្រៅតារាងតុល្យការ (Off-Balance Sheet Items) សំដៅដល់ខ្ទង់ទាំងឡាយណាដែលមិនបានបង្ហាញក្នុងតារាងតុល្យការ ប៉ុន្តែអាចនាំឱ្យមានហានិភ័យលំហូរសាច់ប្រាក់អនាគត។

២- គូប៉ុង (Coupon) សំដៅដល់ការប្រាក់ដែលបុគ្គលបោះផ្សាយសន្យាធ្វើការទូទាត់តាមលក្ខខណ្ឌនៃមូលបត្របំណុល។

៣- ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៤- បុគ្គលបោះផ្សាយ សំដៅដល់បុគ្គលដែលស្នើសុំ ឬបានបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៥- បុគ្គលធានា(Guarantor) សំដៅដល់នីតិបុគ្គល ឬស្ថាប័ន ដែលផ្តល់ការធានាលើមូលបត្របំណុល ដោយអនុលោមទៅតាមលក្ខខណ្ឌនៃការធានា។

៦- ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល (Bondholders Representative) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីធ្វើជាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ស្របទៅតាមបទប្បញ្ញត្តិដែលមានជាធរមាន។

៧- ភ្នាក់ងារវាយតម្លៃលទ្ធភាពសង (Credit Rating Agency) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីផ្តល់សេវាធ្វើចំណាត់ថ្នាក់លើបុគ្គលរងការធ្វើចំណាត់ថ្នាក់ ឬមូលបត្របំណុលដែលត្រូវបោះផ្សាយលក់។

៨- សញ្ញាបណ្ណធម្មតា (Plain Bond) សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុននៅកាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រឡប់ (Call Option) ឬសិទ្ធិលក់ (Put Option) និងមិនមានការធានា។

៩- សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond) សំដៅដល់មូលបត្របំណុលដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើមនឹងត្រូវបានទូទាត់សងដោយភាគីទីបីដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជា អសាធនភាព ឬក្ស័យធន។

១០- សញ្ញាបណ្ណមានវត្ថុធានា (Secured Bond) សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែមូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

១១- សញ្ញាបណ្ណសាជីវកម្ម(Corporate Bond) សំដៅដល់ប្រភេទមួយនៃមូលបត្របំណុលដែលបោះ-ផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានកាតព្វកិច្ចក្នុងការបង់ប្រាក់ដើម ការប្រាក់ និងកាតព្វកិច្ចផ្សេងទៀតចំពោះម្ចាស់មូលបត្របំណុល។

១២-អត្រាគូប៉ុង (Coupon Rate) សំដៅដល់អត្រាការប្រាក់ដែលបុគ្គលបោះផ្សាយសន្យាធ្វើការទូទាត់ក្នុងរយៈពេលនៃមូលបត្របំណុល។

១៣-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

## ប្រការ ៣.- ប្រភេទមូលបត្របំណុលដែលធ្វើសំណើលក់

មូលបត្របំណុលដែលត្រូវធ្វើសំណើលក់អនុលោមតាមប្រកាសនេះ សំដៅដល់សញ្ញាបណ្ណសាជីវកម្មដែលរួមមានសញ្ញាបណ្ណធម្មតា សញ្ញាបណ្ណមានវត្ថុធានា និងសញ្ញាបណ្ណមានបុគ្គលធានា។

សំណើលក់សញ្ញាបណ្ណសាជីវកម្មប្រភេទផ្សេងទៀត ដូចជា សញ្ញាបណ្ណបរិវត្ត និងសញ្ញាបណ្ណដទៃទៀតជាដើម ត្រូវអនុវត្តតាមលក្ខខណ្ឌផ្សេងទៀតក្នុងបទប្បញ្ញត្តិដោយឡែក និងត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

មូលបត្របំណុលផ្សេងទៀតត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

## ប្រការ ៤.- លក្ខណៈនៃមូលបត្របំណុល

មូលបត្របំណុលដែលត្រូវធ្វើសំណើលក់អនុលោមតាមប្រកាសនេះត្រូវមាន÷

១-អត្តសញ្ញាណរបស់បុគ្គលបោះផ្សាយ។

២-តម្លៃចារឹក។

៣-អត្រាគូប៉ុង ឬមិនមានអត្រាគូប៉ុងក្នុងករណីមូលបត្របំណុលបោះផ្សាយលក់ក្នុងតម្លៃអប្បហារ។

៤- កាលបរិច្ឆេទនៃការបោះផ្សាយលក់មូលបត្របំណុល។

៥- ឥណប្រតិទាន។

**ប្រការ ៥.- សំណើលក់មូលបត្របំណុលជាឯកជន**

សំណើលក់មូលបត្របំណុលដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូលបត្របំណុលជាឯកជន÷

១- សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប ហើយសំណើលក់មូលបត្រនេះមិនត្រូវធ្វើលើសពីរយៈពេល ១២ (ដប់ពីរ) ខែ ឡើយ និង

២- សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមទម្រង់ ឬមធ្យោបាយណាក៏ដោយរួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្របំណុល។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្របំណុលជាឯកជន និងបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានបំណងធ្វើសំណើលក់មូលបត្របំណុលជាឯកជន ត្រូវផ្ដល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះជាមុនមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលទាំងនោះត្រូវរាយការណ៍ពីលទ្ធផលឱ្យបានឆាប់ជូន **គ.ម.ក.**។

សំណើលក់មូលបត្របំណុលទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្របំណុលជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២

## លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

**ប្រការ ៦.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

២- មានសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៣- មានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំ

នោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤-មានកម្រិតអភិបាលកិច្ចសាជីវកម្មរឹងមាំ ដោយមានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់។

៥-ទទួលបានការធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៦-ទទួលបានការបញ្ជាក់ជាមុនអំពីការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល និងការដាក់តម្លៃមូលបត្របំណុលពីទីផ្សារមូលបត្រប្រតិស្រុត ស្របតាមមាត្រា ៧ នៃអនុក្រឹត្យ។

**ប្រការ ៧.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-បំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។

២-មានវត្ថុធានា ដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

-មានវិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

-ករណីវត្ថុធានាជាអចលនវត្ថុ ឬសិទ្ធិជួលអចិន្ត្រៃយ៍ តម្លៃនៃវត្ថុធានានោះត្រូវវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៣-ចំនួនទឹកប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវមានតម្លៃអតិបរមាស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃតម្លៃវត្ថុធានា គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

**ប្រការ ៨.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-បំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ លើកលែងចំណុចទី ៥។

២-ត្រូវមានបុគ្គលធានាដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ហើយបុគ្គលធានានោះត្រូវធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

**ប្រការ ៩.-ការបោះផ្សាយលក់មូលបត្របំណុលរបស់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ**

បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយមានបំណងស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៦ ឬប្រការ ៧ ឬប្រការ ៨ នៃប្រកាសនេះលើកលែងលក្ខខណ្ឌរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃ

ប្រការ ៦ ខាងលើ តម្រូវឱ្យមានសម្រាប់រយៈពេលតែ ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងមានរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ប្រសិនមាន។

**ប្រការ ១០.- ឯកសារប្រើសម្រាប់ស្នើសុំបោះផ្សាយលក់មូលបត្រប៊ីណុលជាសាធារណៈ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវមាន÷

១- ពាក្យស្នើសុំបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ខ- លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

គ- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រប៊ីណុលជាសាធារណៈ។

ឃ- លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃបុគ្គលបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

ង- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រប៊ីណុលជាសាធារណៈ។

ច- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ក្នុងករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៦ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.**។

ឆ- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

ជ- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ពី **គ.ម.ក.**។

ឈ- របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

ញ- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ ដែលមាន។

ដ- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនមាន។

ឋ- កិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញជាមួយក្រុមហ៊ុនធានាទិញមូលបត្រថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឆ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឈ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ញ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ដ-ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

ថ-ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម÷

ថ.១-ភ័ស្តុតាងអំពីវត្ថុធានា។

ថ.២-វិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

ថ.៣-របាយការណ៍ស្តីពីការវាយតម្លៃទ្រព្យសកម្មដែលចេញដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

ទ-ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម÷

ទ.១-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

ទ.២-កិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

ធ-ឯកសារផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៣
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

**ប្រការ ១១.- ការដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវដាក់ពាក្យស្នើសុំដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ ដើម្បីស្នើសុំការអនុញ្ញាតលើសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដោយអនុលោមតាមមាត្រា ១២ និងមាត្រា ១៧ នៃច្បាប់

មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៣ នៃអនុក្រឹត្យ និងប្រកាសនេះ។

ឯកសារផ្តល់ព័ត៌មានត្រូវមានយ៉ាងហោចណាស់នូវព័ត៌មានពីប្រការ ១២ ដល់ប្រការ ២២ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិ និងនាយកហិរញ្ញវត្ថុរបស់បុគ្គលដាក់ពាក្យស្នើសុំ។

**ប្រការ ១២.- ឯកសារផ្តល់ព័ត៌មាន**

ឯកសារផ្តល់ព័ត៌មានត្រូវមានមាតិកាអប្បបរមាដូចខាងក្រោម÷

១-សេចក្តីជូនដំណឹងចំពោះវិនិយោគិន។

២-គម្រោងពេលវេលាកំណត់ទុកនៃការបោះផ្សាយ។

៣-អត្តសញ្ញាណនៃបុគ្គលពាក់ព័ន្ធនឹងការរៀបចំឯកសារផ្តល់ព័ត៌មាន។

៤-និយមន័យ អក្សរកាត់ និងពាក្យបច្ចេកទេស។

៥-សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន។

៦-ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧-ព័ត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៨-ព័ត៌មានទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-ព័ត៌មានស្តីពីប្រតិបត្តិការ ដោយរួមបញ្ចូលទាំងយុទ្ធសាស្ត្រ និងផែនការធុរកិច្ច។

១០-ព័ត៌មានស្តីពីកត្តាហានិភ័យ។

១១-ព័ត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម។

១២-ព័ត៌មានស្តីពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ។

១៣-ព័ត៌មានហិរញ្ញវត្ថុ និង/ឬព័ត៌មានហិរញ្ញវត្ថុរួម។

១៤-ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ។

១៥-ព័ត៌មានផ្សេងៗ។

១៦-ឧបសម្ព័ន្ធ។

ឯកសារផ្តល់ព័ត៌មានត្រូវមានសេចក្តីបញ្ជាក់ថា *"ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បុគ្គលដាក់ពាក្យស្នើសុំ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"* ។

**ប្រការ ១៣.- សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសង្ខេបដូចជា÷

១-ទិដ្ឋភាពទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ។

២-ព័ត៌មានស្តីពីយុទ្ធសាស្ត្រ និងផែនការធុរកិច្ច។

៣-ព័ត៌មានស្តីពីអភិបាល និងភាគហ៊ុនិក។

៤-ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ។

៥-ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៦-ព័ត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧-ព័ត៌មានស្តីពីកត្តាហានិភ័យ។

**ប្រការ ១៤.- ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈដូចខាងក្រោម៖

១-ការពិពណ៌នាអំពីមូលបត្របំណុលដែលធ្វើសំណើលក់ ដោយបញ្ជាក់អំពីសិទ្ធិ និងលក្ខខណ្ឌដែលភ្ជាប់នឹងមូលបត្របំណុលដែលបោះផ្សាយលក់។

២-លក្ខខណ្ឌនៃមូលបត្របំណុល (Terms and Conditions)។

៣-ថ្លៃ និងអត្រាគូប៉ុង នៃមូលបត្របំណុលដែលធ្វើសំណើលក់។

៤-វិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលបត្របំណុល។

៥-ផែនការបែងចែកមូលបត្របំណុល។

៦-ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៧-ការតែងតាំង សិទ្ធិអំណាច និងកាតព្វកិច្ច របស់ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

៨-លក្ខខណ្ឌក្នុងការដកភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

៩-កិច្ចប្រជុំម្ចាស់មូលបត្របំណុល។

១០-នីតិវិធី កាលបរិច្ឆេទ និងទីកន្លែង សម្រាប់ការទូទាត់គូប៉ុង និងប្រាក់ដើមនៃមូលបត្របំណុល។

១១-ព្រឹត្តិការណ៍ដែលនាំឱ្យមានការខកខានមិនបានទូទាត់សងមូលបត្របំណុល។

១២-ព័ត៌មានសំខាន់ពាក់ព័ន្ធនឹងកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញ ជាមួយក្រុមហ៊ុនធានាទិញមូលបត្រ។

១៣-ការធ្វើចំណាត់ថ្នាក់លទ្ធភាពសង។

១៤-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា ត្រូវមានព័ត៌មានបន្ថែមដូចខាងក្រោម៖

១-ទ្រព្យដែលប្រើសម្រាប់ដាក់ជាវត្ថុធានា។

២-ព័ត៌មានស្តីពីការធានា ដែលរួមមាន លក្ខណៈ និងលក្ខខណ្ឌនៃការធានា។

ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា ត្រូវមានព័ត៌មានបន្ថែមដូចខាងក្រោម÷

១- ព័ត៌មានស្ដីពីបុគ្គលធានា។

២- ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

៣- ការធ្វើចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា។

**ប្រការ ១៥.- ព័ត៌មានស្ដីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូល-បត្របំណុលជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។ ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវប្រើប្រាស់សម្រាប់ការធានាការចំណាយពាក់ព័ន្ធនឹងសកម្មភាពតាមកិច្ចសន្យាណាមួយរបស់បុគ្គលដាក់ពាក្យស្នើសុំ ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញពីរយៈ-ពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

ករណីសំណើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញពីផែនការវិនិយោគនោះ។ ករណីមានផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នា ជាទម្រង់ពេញលេញក្នុងឯកសារផ្ដល់ព័ត៌មាន។

**ប្រការ ១៦.- ព័ត៌មានស្ដីពីបុគ្គលដាក់ពាក្យស្នើសុំ**

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញព័ត៌មានស្ដីពីបុគ្គលដាក់ពាក្យស្នើសុំដូចជា÷

១- ប្រវត្តិ និងការវិវត្តន៍។

២- យុទ្ធសាស្ត្រ និងផែនការអាជីវកម្ម។

៣- ព័ត៌មានស្ដីពីធុរកិច្ច។

៤- ទិដ្ឋភាពទូទៅក្នុងវិស័យ។

៥- សម្ព័ន្ធភាពបុគ្គលបោះផ្សាយ។

៦- ព័ត៌មានពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែងរបស់បុគ្គលបោះផ្សាយ។

៧- ព័ត៌មានស្ដីពីកាតព្វកិច្ចពន្ធ។

**ប្រការ ១៧.- ព័ត៌មានស្ដីពីកត្តាហានិភ័យ**

ឯកសារផ្ដល់ព័ត៌មាន ត្រូវបង្ហាញព័ត៌មានស្ដីពីកត្តាហានិភ័យទាំងឡាយណាដែលពាក់ព័ន្ធនឹងធុរកិច្ច

របស់បុគ្គលដាក់ពាក្យស្នើសុំ ដោយរាប់បញ្ចូលទាំងហានិភ័យដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ ហា-និភ័យនៃវិស័យរបស់ធុរកិច្ច ព្រមទាំងឥទ្ធិពលដោយផ្ទាល់ ឬប្រយោលនៃហានិភ័យទាំងនេះទៅលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការធុរកិច្ច និងការវិនិយោគរបស់បុគ្គលដាក់ពាក្យស្នើសុំ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការវិភាគកត្តាហានិភ័យ និងទស្សនៈរបស់អ្នកគ្រប់គ្រង ព្រមទាំងវិធានការទប់ទល់ទៅនឹងកត្តាហានិភ័យទាំងនោះ។

**ប្រការ ១៨.- ព័ត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្មដូចខាងក្រោម÷

១-ព័ត៌មានស្តីពីភាគហ៊ុនិក។

២-ព័ត៌មានស្តីពីអភិបាល បុគ្គលិកជាន់ខ្ពស់ លេខាធិការក្រុមហ៊ុន និងបុគ្គលិកជាន់ខ្ពស់ទទួលបន្ទុកផ្តល់ព័ត៌មាន។

៣-ព័ត៌មានស្តីពីក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល។

៤-ព័ត៌មានស្តីពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់។

៥-ព័ត៌មានស្តីពីលាភការ ឬប្រាក់បំណាច់ របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

៦-ព័ត៌មានស្តីពីភាគីពាក់ព័ន្ធរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៧-ព័ត៌មានស្តីពីលក្ខខណ្ឌអភិបាលកិច្ចផ្សេងទៀតដូចមានកំណត់ក្នុងច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ១៩.- ព័ត៌មានស្តីពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីប្រតិបត្តិការសំខាន់ៗក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទ នៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងបុគ្គលដាក់ពាក្យស្នើសុំជាមួយនឹងភាគីពាក់ព័ន្ធដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ។

២-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

៣-សមាជិកគ្រួសារផ្ទាល់ (រួមមាន ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬបងប្អូនស្រី) របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលដាក់ពាក្យស្នើសុំ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុម-ហ៊ុនហ្វូលឌីងរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលដាក់ពាក្យស្នើសុំ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៦-អភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលដាក់ពាក្យស្នើសុំ។

៧-អភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលដាក់ពាក្យស្នើសុំ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

ករណីបុគ្គលដាក់ពាក្យស្នើសុំមានប្រតិបត្តិការជាមួយអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះរបស់អភិបាល ឬភាគហ៊ុនិក។

២-ប្រភេទ និងតម្លៃ នៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំដោយផ្ទាល់ ឬដោយប្រយោល។

៣-ការពិពណ៌នាពីប្រតិបត្តិការ ដោយបញ្ជាក់ពីទំហំ លក្ខណៈ និងទំនាស់ផលប្រយោជន៍ ដែលអាចកើតមាន។

ប្រសិនបើបុគ្គលដាក់ពាក្យស្នើសុំបានទិញ ឬនឹងទិញចលនវត្ថុ និង/ឬអចលនវត្ថុពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២០.- ព័ត៌មានហិរញ្ញវត្ថុ**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួមដែលបំពេញតាមទម្រង់ដែលកំណត់ដោយ **គ.ម.គ.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២១.- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១-លទ្ធផលប្រតិបត្តិការ។

២-សន្ទនីយភាព និងប្រភពទុន។

៣-ព័ត៌មាននិន្នាការនិងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

៤-ការចាត់ចែងខ្ទង់ក្រៅតារាងតុល្យការ ប្រសិនមាន។

**ប្រការ ២២.- ឧបសម្ព័ន្ធនៃឯកសារផ្តល់ព័ត៌មាន**

ឯកសារផ្តល់ព័ត៌មានត្រូវមានភ្ជាប់មកជាមួយនូវឯកសារជាឧបសម្ព័ន្ធដូចខាងក្រោម÷

១-លក្ខខណ្ឌនៃមូលបត្របំណុល។

២-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

៣-របាយការណ៍សង្ខេបស្តីពីការវាយតម្លៃទ្រព្យសកម្ម ប្រសិនមាន។

៤-របាយការណ៍សវនកម្ម ឬរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.មូ.ក.**។

៥-របាយការណ៍សវនកម្ម របស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលមិនទទួលបានការទទួលស្គាល់ពី **គ.មូ.ក.**។

៦-របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ដែលត្រូវធ្វើការពិនិត្យឡើងវិញដោយសវនករឯករាជ្យ ប្រសិនមាន។

៧-របាយការណ៍សង្ខេបនៃចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលបោះផ្សាយ ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.មូ.ក.**។

៨-របាយការណ៍សង្ខេបនៃចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.មូ.ក.** ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា។

៩-សេចក្តីថ្លែងរបស់បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈដែលបញ្ជាក់ពីភាពត្រឹមត្រូវ និងពីការគោរពតាមច្បាប់បទប្បញ្ញត្តិជាធរមាននៃឯកសារនិងព័ត៌មានដែលបានផ្តល់ជូន **គ.មូ.ក.**។

១០-លិខិតយល់ព្រមឱ្យធ្វើការផ្សព្វផ្សាយសេចក្តីថ្លែង ឬរបាយការណ៍របស់អ្នកជំនាញក្នុងឯកសារផ្តល់ព័ត៌មាន ប្រសិនមាន។

### ប្រការ ២៣.- ការទទួលខុសត្រូវរបស់អ្នកជំនាញ

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ និងភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

### ប្រការ ២៤.- ការទទួលខុសត្រូវរបស់បុគ្គលបោះផ្សាយ និងភាគីពាក់ព័ន្ធចំពោះព័ត៌មានដែលមានក្នុងឯកសារផ្តល់ព័ត៌មាន

បុគ្គលដាក់ពាក្យស្នើសុំត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ ភាពពេញលេញ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

### ប្រការ ២៥.- ការផ្តល់ព័ត៌មានបន្ថែម ព័ត៌មានជំនួស សេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ

អគ្គនាយកនៃ **គ.មូ.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់ព័ត៌មានបន្ថែម ព័ត៌មានជំនួស

សេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមសំណើនេះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីបុគ្គលដាក់ពាក្យស្នើសុំមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចសម្រេចទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២៦.- ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានជាគោលការណ៍**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ ពីការអនុញ្ញាត ឬមិនអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានជាគោលការណ៍ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

**ប្រការ ២៧.- ការបដិសេធលើសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈរបស់បុគ្គលដាក់ពាក្យស្នើសុំ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១- បុគ្គលដាក់ពាក្យស្នើសុំមិនបំពេញលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ ឬប្រកាសនេះ។

២- ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈមិនពេញលេញ ក្លែងបន្លំ ឬនាំឱ្យយល់ខុស ឬមានវិលងព័ត៌មានសំខាន់ផ្សេងទៀត។

៣- បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤- ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល។

៥- បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ÷

ក- មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមមាត្រា ៤២ នៃអនុក្រឹត្យ។

ខ- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង- ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបានក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំនឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

## ជំពូកទី ៤

## ការដាក់លក់មូលបត្របំណុលជាសាធារណៈ

### ប្រការ ២៨.- ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាគោលការណ៍លើឯកសារផ្តល់ព័ត៌មាន អាចទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.** បន្ទាប់ពី÷

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្របំណុលដែលការកំណត់ថ្លៃលក់មូលបត្របំណុលនេះទទួលបានការបញ្ជាក់ពីទីផ្សារមូលបត្រប្រតិស្រុត និង

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្របំណុលជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើ ពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

### ប្រការ ២៩.- ការធ្វើបរិវិសកម្ម

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មមូលបត្របំណុល ត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាពសម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មមូលបត្របំណុលត្រូវបាន

បញ្ចប់ពេញលេញ បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មមូលបត្របំណុលនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជ ដោយអនុលោមតាមមាត្រា ១៨ នៃអនុក្រឹត្យ។ បញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មមូលបត្របំណុលត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មនឹងត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ “ខ” នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣២ ប្រការ ៣៣ និងប្រការ ៣៤ នៃប្រកាសនេះ។

**ប្រការ ៣០.- ការធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្មមូលបត្របំណុល ករណីមូលបត្របំណុលធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់បុគ្គលបោះផ្សាយ ត្រូវធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ទៅឱ្យបុគ្គលបោះផ្សាយក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣១.- ការបែងចែកមូលបត្របំណុល**

ក្រុមហ៊ុនមូលបត្រ ត្រូវចែកចាយមូលបត្របំណុលក្នុងថ្ងៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជី។

បុគ្គលបោះផ្សាយ ភ្នាក់ងារបញ្ជិកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបែងចែក និងបញ្ជូនមូលបត្របំណុលទៅឱ្យអ្នកដែលបានធ្វើបរិវិសកម្មដោយជោគជ័យក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្មមូលបត្របំណុល។

**ប្រការ ៣២.- ការព្យួរឯកសារផ្តល់ព័ត៌មានដែលចុះបញ្ជីរួច**

ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមមាត្រា ២១ នៃច្បាប់។ ករណីនេះ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួល

ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុល និងត្រូវជូនដំណឹងភ្លាមអំពីការព្យួរនេះទៅដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មមូលបត្របំណុលថាមានសិទ្ធិអាចដកស្ទីការដែលបានធ្វើឡើងចំពោះសំណើលក់មូលបត្របំណុលជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលឡើងវិញបន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរឯកសារផ្តល់ព័ត៌-មានត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៣.- ការផ្សព្វផ្សាយជាសាធារណៈអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន**

បុគ្គលបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១- មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២- កាលបរិច្ឆេទនៃការសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣- ពេលវេលា ទីកន្លែង និងរបៀប នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ប្រាក់រួច ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះ ត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤- ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៤.- ការធ្វើបរិវិសកម្មមូលបត្របំណុលមិនបានជោគជ័យ**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន អាចត្រូវបានលុបចោលផងដែរក្នុងករណីដែលការធ្វើបរិវិសកម្មមូលបត្របំណុលមិនបានជោគជ័យ។

**ប្រការ ៣៥.- ការរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្របំណុលជាសាធា-រណៈទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជអំពីចំនួនទឹកប្រាក់នៅក្នុងគណនីដាច់ដោយឡែកដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះនៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់-ព័ន្ធនឹងមូលបត្រ។

**ប្រការ ៣៦.- ការបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត**

បុគ្គលបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៥
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៣៧.- ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្ដីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងសំណើបោះផ្សាយ និងការលក់មូលបត្របំណុលជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើការចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន បុគ្គលបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្ដានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើការចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន បុគ្គលបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្ហូ និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

បុគ្គលបោះផ្សាយត្រូវត្រៀមឯកសារផ្ដល់ព័ត៌មានសម្រាប់ផ្ដល់ឱ្យសាធារណជន នៅបុគ្គលបោះផ្សាយ ក្រុមហ៊ុនមូលបត្រ និងប្រតិបត្តិករទីផ្សារមូលបត្រ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៨.- ការជូនដំណឹងជាសាធារណៈ**

ក្នុងរយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃចាប់ផ្ដើមធ្វើបរិវិសកម្មមូលបត្របំណុល បុគ្គលបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ពី **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១- ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀតរបស់បុគ្គលបោះផ្សាយ។

២- ចំនួន និងប្រភេទមូលបត្របំណុលដែលត្រូវធ្វើសំណើលក់។

៣- ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុល។

៤- កាលបរិច្ឆេទនៃការធ្វើបរិវិសកម្មមូលបត្របំណុល។

៥-សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជីពី **គ.ម.ក.**។

៦-សេចក្តីថ្លែងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកលើឯកសារសំណើលក់មូលបត្របំណុល។

៧-សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្របំណុលឡើយ។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមលើនេះ បុគ្គលបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែបុគ្គលបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់អេឡិចត្រូនិច ឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៦
## លក្ខខណ្ឌតម្រូវក្រោយពេលបោះផ្សាយលក់មូលបត្របំណុល

**ប្រការ ៣៩.- ព័ត៌មានដែលត្រូវបង្ហាញ**

បុគ្គលបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម និងត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ករណីមានព្រឹត្តិការណ៍ដូចខាងក្រោម÷

១-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំកិច្ចប្រជុំម្ចាស់មូលបត្របំណុល ដោយលម្អិតអំពីទីកន្លែង ពេលវេលា របៀបវារៈប្រជុំ និងលក្ខខណ្ឌសម្រាប់ការចូលរួម និងអ្នកចូលរួម។

២-សេចក្តីសម្រេចរបស់ម្ចាស់មូលបត្របំណុលក្រោយពេលកិច្ចប្រជុំ។

៣-នៅពេលមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន។

៤-នៅពេលដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពបង់ការប្រាក់ និង/ឬប្រាក់ដើមទៅតាមរយៈពេលនៃការទូទាត់ដូចមានចែងក្នុងលក្ខខណ្ឌនៃមូលបត្របំណុល។

៥-នៅពេលមានការបង់ការប្រាក់។

៦-នៅពេលមានគម្រោងធ្វើការពន្យារពេលបង់ការប្រាក់នៃមូលបត្របំណុល។

៧-នៅពេលដែលបុគ្គលបោះផ្សាយទិញមកវិញនូវមូលបត្របំណុលមួយផ្នែក ឬទាំងអស់របស់ខ្លួនពីទីផ្សារបន្ទាប់។

៨-រាយការណ៍ជូន **គ.ម.ក.** ជាប្រចាំឆ្នាំបន្ទាប់ពីទទួលបានរបាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង

ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** នូវការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុលដូចមានចែងក្នុងចំណុចទី ៥ ប្រការ ៦ នៃប្រកាសនេះ រហូតដល់ការសងត្រឡប់ប្រាក់ដើមបញ្ចប់។ អគ្គនាយកនៃ**គ.ម.ក.** អាចលើកលែងនូវការរាយការណ៍អំពីការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុលដោយពិចារណាពីភាពចាំបាច់នៃព័ត៌មានអំពីការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុលចំពោះវិនិយោគិន។

៩-ករណីមានការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

១០-ករណីមានការផ្លាស់ប្តូរ ឬកែប្រែលក្ខខណ្ឌ និង/ឬទ្រព្យធានានៃមូលបត្របំណុលដោយត្រូវដាក់ជូន **គ.ម.ក.** នូវឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។ ការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំម្ចាស់មូលបត្របំណុលដោយត្រូវបញ្ជាក់ពីមូលហេតុនៃការផ្លាស់ប្តូរ ឬការកែប្រែ និងវិបាកដែលកើតមាន ឬអាចនឹងកើតមានចំពោះការសម្រេចចិត្តរបស់ម្ចាស់មូលបត្របំណុល។

១១-នៅពេលដែលគណនីរបស់បុគ្គលបោះផ្សាយនៅធនាគារត្រូវបានបង្កក ឬគណនីរបស់បុគ្គលបោះផ្សាយត្រូវបានអនុញ្ញាតឱ្យដំណើរការវិញបន្ទាប់ពីមានការបង្កកគណនីនោះ។

១២-នៅពេលមានព័ត៌មានដែលអាចមានឥទ្ធិពលលើបុគ្គលបោះផ្សាយ និង/ឬមានឥទ្ធិពលលើទំនុកចិត្តឥណទាន (Credit Worthiness) របស់បុគ្គលបោះផ្សាយ។

### ប្រការ ៤០.- កាតព្វកិច្ចរក្សាកម្រិតអនុបាតហិរញ្ញវត្ថុ

បុគ្គលបោះផ្សាយត្រូវរក្សាឱ្យបាននូវកម្រិតអនុបាតហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការ ៤៨ នៃប្រកាសនេះ។

### ប្រការ ៤១.- កាតព្វកិច្ចរាយការណ៍អំពីការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

បុគ្គលបោះផ្សាយត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** អំពីការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ហើយបន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល បុគ្គលបោះផ្សាយត្រូវដាក់ជូន **គ.ម.ក.** នូវកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលថ្មីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទតែងតាំង។

## ជំពូកទី ៧
## កម្រៃសេវាក្នុងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

### ប្រការ ៤២.- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវបង់ថ្លៃពាក្យស្នើសុំ និង

សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១- ជាប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ។

២- ជាប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម។

**ប្រការ ៤៣.- សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ត្រូវបង់សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួសនៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១- ជាប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ។

២- ជាប្រាក់ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម។

**ប្រការ ៤៤.- សោហ៊ុយសិក្សាចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ត្រូវបង់សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានឡើងវិញឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១- ជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ។

២- ជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម។

**ប្រការ ៤៥.- ការមិនសងត្រឡប់វិញនូវថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារ**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារ ដូចមានចែងក្នុងប្រការ ៤២ ប្រការ ៤៣ និងប្រការ ៤៤ នៃប្រកាសនេះមិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយទោះជាឯកសារផ្តល់ព័ត៌មានមិនទទួលបានការអនុញ្ញាត និងចុះបញ្ជីក៏ដោយ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**ប្រការ ៤៦.- វិធានការរដ្ឋបាល**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ការព្រមាន ឬដាស់តឿន។

២-ការស្នើឱ្យដាក់អនុស្សារណៈ។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

៥-ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៤៧.- វិធានការផាកពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា បុគ្គលបោះផ្សាយ ឬក្រុមហ៊ុនធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**ប្រការ ៤៨.- លក្ខខណ្ឌលើកលែង**

ករណីពុំទាន់មានភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ពី **គ.ម.ក.** បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍អនុបាតហិរញ្ញវត្ថុសំខាន់ៗដែលមានដូចជា អនុបាតចំណេញភាព និងលំហូរសាច់ប្រាក់ (Profitability and Cash Flow Ratio) អនុបាតឡេវើរ៉េច (Leverage Ratio) និងអនុបាតលទ្ធភាពសង (Coverage Ratio) ជាដើម ដែលមានការបញ្ជាក់ពីភាពសមស្របដោយអ្នកជំនាញ ឬក្រុមហ៊ុនធានាទិញមូលបត្ររបស់បុគ្គលបោះផ្សាយ។

ករណីពុំទាន់មានភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលដែលទទួលស្គាល់ពី **គ.ម.ក.** បុគ្គលបោះផ្សាយអាចជ្រើសរើសភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ដើម្បីផ្តល់សេវាជាប់ពាក់ព័ន្ធនឹងការចុះបញ្ជីមូលបត្របំណុល ការផ្ទេរមូលបត្របំណុល និងការទូទាត់ជូនម្ចាស់មូលបត្របំណុល។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

### ប្រការ ៤៩.- ការចេញគោលការណ៍ណែនាំ

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

### ប្រការ ៥០.- បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

### ប្រការ ៥១.- ការអនុវត្ត

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៧

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពី ការដាក់អោយអនុវត្ត វិធានចុះបញ្ជីលក់មូលបត្រ បំណុលរបស់ក្រុមហ៊ុនផ្សារ មូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០១៦/១៧ គ.ម.ក./ប្រ.ក.

# ប្រកាស

## ស្ដីពី

## ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ០០៩/១៧ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- យោងតាមសំណើសុំអនុម័តវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

### ប្រការ ១.-

ដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ ២.-

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០១៦/១៧
ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧
ស្តីពី
# វិធានចុះបញ្ជីលក់មូលបត្របំណុល
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

វិធាននេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌតម្រូវ នីតិវិធី និងការគ្រប់គ្រងពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្របំណុលនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះនិងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត÷

-**បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល** សំដៅដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុល នៅ **ផ.ម.ក.** ។

-**បុគ្គលចុះបញ្ជីលក់មូលបត្របំណុល** សំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនោះជាផ្លូវការនៅ **ផ.ម.ក.**។

-**បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ** សំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនោះជាផ្លូវការនៅ **ផ.ម.ក.**។

**ប្រការ ៣.- វិសាលភាព**

វិធាននេះមានវិសាលភាពអនុវត្តទៅលើមូលបត្របំណុលដែលបោះផ្សាយលក់ជាសាធារណៈ ដែលជាសញ្ញាបណ្ណសាជីវកម្ម ដែលមានប្រភេទជាសញ្ញាបណ្ណធម្មតា (Plain Bond) សញ្ញាបណ្ណមានវត្ថុធានា (Secured Bond) សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond) និងប្រភេទមូលបត្របំណុលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

## ជំពូកទី ២

## លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល

**ប្រការ ៤.- ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល ដោយត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃការចុះបញ្ជីលក់មូលបត្របំណុលនៅ **ផ.ម.ក.**។

**ប្រការ ៥.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលត្រូវផ្តល់ព័ត៌មាន និងឯកសារភ្ជាប់ដូចខាងក្រោម ÷

១- ព័ត៌មានទូទៅ

ក- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ជាភាសាខ្មែរ និងអក្សរឡាតាំង

ខ- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល

គ- កាលបរិច្ឆេទនៃការបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល

ឃ- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល។

២- លក្ខន្តិកៈរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ ។

៤- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៥- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៦- លិខិតប្រគល់សិទ្ធិជូនបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលនិងឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលតំណាង។

៧- ព័ត៌មានអំពីភាគហ៊ុនិក ។

៨- ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម។

៩- ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលរួមមាន ព័ត៌មានអំពីធុរកិច្ច និងព័ត៌មានអំពីហានិភ័យ។

១០- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលរួមមាន៖

ក- ព័ត៌មានសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុ ដោយរាប់បញ្ចូលទាំងព័ត៌មានអំពីមូលបត្របំណុល និងមូលបត្រកម្មសិទ្ធិទាំងអស់ និងលទ្ធភាពទទួលបានប្រាក់ចំណេញ។

ខ- ការវាយតម្លៃទ្រព្យសកម្ម និង/ ឬ ការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

គ- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម អនុលោមតាមលក្ខខណ្ឌតម្រូវនៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

១១- របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ឬរបាយការណ៍ស្តីពីអនុបាតចំណេញភាព និងលំហូរសាច់ប្រាក់ (Profitability and Cash Flow Ratio) អនុបាតឡេវើរ៉េច (Leverage Ratio) និងអនុបាតលទ្ធភាពសង (Coverage Ratio) ជាដើម ដែលមានការបញ្ជាក់ពីភាពសមស្របដោយអ្នកជំនាញ ឬក្រុមហ៊ុនធានាទិញមូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលដែលជាសញ្ញាបណ្ណធម្មតា ករណីពុំទាន់មានភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ពី គ.ម.ក.។

១២- ព័ត៌មានពាក់ព័ន្ធនឹងវត្ថុធានា ករណីបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា។

១៣- ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលធានាដែលរួមមាន ព័ត៌មានទូទៅ របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា និងកិច្ចព្រមព្រៀងធានាជាមួយបុគ្គលធានា ករណីបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា ដែលបានការទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)។

១៤- ឯកសារស្តីពីមូលបត្របំណុលដែលស្នើសុំចុះបញ្ជីលក់ដែលមានព័ត៌មានដូចខាងក្រោម៖

ក- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលឱ្យធ្វើការបោះផ្សាយមូលបត្របំណុល។

ខ- សេចក្តីលម្អិតពីមូលបត្របំណុលដែលស្នើសុំចុះបញ្ជី៖

- អត្រាគូប៉ុង និងកាលវិភាគទូទាត់ការប្រាក់
- តម្លៃចារឹកនៃមូលបត្របំណុល
- កាលបរិច្ឆេទបោះផ្សាយ និងកាលប្រតិទាន
- ផែនការបែងចែកមូលបត្របំណុល

គ- ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយមូលបត្របំណុល។

ឃ- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងអ្នកកាន់កាប់មូលបត្របំណុលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

១៥-ព័ត៌មានចាំបាច់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ បំណុល។

ករណីបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ឯកសារតម្រូវនៅក្នុងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ ទី៧ ទី៨ និងទី៩ ខាងលើ ត្រូវបានលើកលែង ប្រសិនបើព័ត៌មានទាំងនោះត្រូវបានធ្វើបច្ចុប្បន្នកម្មមក ន.ម.ក. រួចហើយ។

### ប្រការ ៦.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពដែលអាចចុះបញ្ជីលក់មូលបត្របំណុល

ន.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលទៅបុគ្គល ស្នើសុំចុះបញ្ជីលក់មូលបត្របំណុលក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។ រយៈពេលនៃការពិនិត្យត្រូវបានកាត់បន្ថយមកត្រឹមយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

ករណី ន.ម.ក. បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ន.ម.ក. ត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលអាចស្នើសុំការបំភ្លឺពី ន.ម.ក.។ បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលដែលត្រូវបានបដិសេធអាច ធ្វើការតវ៉ាមក គ.ម.ក. ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្របំណុល

### ប្រការ ៧.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្របំណុល

ក្នុងរយៈពេល ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមូលបត្របំណុលត្រូវបានបញ្ចូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការនៅ ន.ម.ក. ។

### ប្រការ ៨.- លក្ខខណ្ឌចុះបញ្ជីលក់មូលបត្របំណុល

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលអាចចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការបាននៅ ន.ម.ក ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.÷

១-មូលធនភាគហ៊ុនិកសរុប ត្រូវមានយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល លើកលែងចំពោះការចុះបញ្ជីសញ្ញាបណ្ណមានវត្ថុធានា។

២-ទំហំមូលបត្របំណុលដែលបោះផ្សាយនិងចុះបញ្ជី ត្រូវមានយ៉ាងតិចចំនួន ១.០០០.០០០.០០០ (មួយប៊ីលាន) រៀល ឬយ៉ាងតិចចំនួន ៥០០.០០០.០០០(ប្រាំរយលាន) រៀល ចំពោះសញ្ញាបណ្ណមានវត្ថុធានា។

៣-តម្លៃចារឹក ត្រូវមានតម្លៃ ១០០.០០០(មួយរយពាន់) រៀល។

៤-មូលបត្របំណុលទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក.។

**ប្រការ ៩.- ឯកសារភ្ជាប់ដែលត្រូវផ្តល់ជូន ផ.ម.ក.**

ក្នុងការបំពេញនីតិវិធីនៃការចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារភ្ជាប់ខាងក្រោម÷

១-ឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជីជាស្ថាពររួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់ពីការទូទាត់បរិវិសកម្មមូលបត្របំណុល។

៣-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្របំណុលនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក.។

៤-របាយការណ៍បែងចែកមូលបត្របំណុល។

៥-ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងដែលធ្វើឡើងជាមួយនឹងភ្នាក់ងារតំណាងអ្នកកាន់កាប់មូលបត្របំណុល ឬភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់។

៦-ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងធានាទិញមូលបត្រ។

**ប្រការ ១០.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុល**

មុននឹងត្រូវបានចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវចុះកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុល ជាមួយ ផ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុលដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ។

**ប្រការ ១១.- ការចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ**

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ ៩ នៃវិធាននេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

ប្រការ ៦ ខាងលើ តម្រូវឱ្យមានសម្រាប់រយៈពេលតែ ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងមានរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ប្រសិនមាន។

**ប្រការ ១០.- ឯកសារប្រើសម្រាប់ស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវមាន÷

១- ពាក្យស្នើសុំបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ខ- លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

គ- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ឃ- លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃបុគ្គលបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

ង- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ច- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ក្នុងករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៦ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.**។

ឆ- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

ជ- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ពី **គ.ម.ក.**។

ឈ- របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

ញ- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ ដែលមាន។

ដ- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនមាន។

ឋ- កិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញជាមួយក្រុមហ៊ុនធានាទិញមូលបត្រថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

**ប្រការ ១៤.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្របំណុល ដែលដកចេញពីបញ្ជីលក់មូលបត្របំណុលជាផ្លូវការ**

នៅពេលដកចេញពីបញ្ជីនូវមូលបត្របំណុលណាមួយជាផ្លូវការ ជ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្របំណុលនោះ។

ករណីដកចេញពីបញ្ជីនូវមូលបត្របំណុលណាមួយ ជ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្របំណុលនោះ សម្រាប់រយៈពេល ១០(ដប់) ថ្ងៃនៃថ្ងៃជួញដូរ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

## ជំពូកទី ៥
## ការគ្រប់គ្រងលើមូលបត្របំណុលដែលបានចុះបញ្ជីលក់

**ប្រការ ១៥.- កាតព្វកិច្ច និងនីតិវិធីផ្ដល់ព័ត៌មាន**

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវដាក់ជូន ជ.ម.ក. ឱ្យទាន់ពេលវេលានូវព័ត៌មានសាជីវកម្ម និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចបង្ហាញព័ត៌មានសាជីវកម្មរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ១៦.- ការព្យួរការជួញដូរ និងការចាប់ផ្ដើមជួញដូរជាថ្មី**

ជ.ម.ក. អាចព្យួរការជួញដូរមូលបត្របំណុលដែលចុះបញ្ជី ក្នុងករណីណាមួយដូចខាងក្រោម÷

១-ករណីមូលបត្របំណុលចុះបញ្ជីមួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីបុគ្គលចុះបញ្ជីលក់មូលបត្របំណុលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្របំណុលជាផ្លូវការ ដូចមានចែងក្នុងប្រការ ១៣ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្របំណុលមិនទាន់បានអនុវត្ត។

៣-ករណីប្រតិបត្តិការរបស់បុគ្គលចុះបញ្ជីលក់មូលបត្របំណុលជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្របំណុលដែលអនុលោមតាមកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច ។

**ប្រការ ១៧.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្របំណុល**

ករណីមានការកែប្រែទាក់ទងនឹងព័ត៌មានមូលបត្របំណុលដែលចុះបញ្ជីលក់ បុគ្គលចុះបញ្ជីលក់មូលបត្របំណុល ត្រូវបំពេញពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្របំណុលនៅ **ផ.ម.ក** និងត្រូវផ្សព្វផ្សាយភ្លាម នូវព័ត៌មានអំពីការកែប្រែនេះជាសាធារណៈ បន្ទាប់ពីទទួលបានការអនុញ្ញាតលើការកែប្រែនេះពី **ផ.ម.ក**។

## ជំពូកទី ៦
## ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុល

**ប្រការ ១៨.- ថ្លៃសេវាសម្រាប់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា **ផ.ម.ក** លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលចំនួន ១.០០០.០០០(មួយលាន) រៀល នៅពេលដាក់ពាក្យស្នើសុំ។

**ប្រការ ១៩.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្របំណុល ចំនួន ២.០០០.០០០ (ពីរលាន) រៀល ឬ 0,0១% (សូន្យក្បៀសសូន្យមួយភាគរយ) នៃតម្លៃមូលបត្របំណុលសរុបដែលបោះផ្សាយ ដោយយកចំនួនណាមួយដែលធំជាង និងថ្លៃអតិបរមាមិនលើសពី ១០.០០០.០០០(ដប់លាន) រៀល។ ថ្លៃសេវា នេះត្រូវបង់មុនពេលចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ។

**ប្រការ ២០.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្របំណុល ចំនួន ៥០០.០០០(ប្រាំរយពាន់) រៀល។ ថ្លៃសេវានេះត្រូវបង់យ៉ាងយូររយៈពេល៣០(សាមសិប) ថ្ងៃ ក្រោយពេលចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ និងសម្រាប់ឆ្នាំបន្តបន្ទាប់ ត្រូវបង់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែមករា ជារៀងរាល់ឆ្នាំ។

************************

# ឧបសម្ព័ន្ធទី៤៖ ប្រកាសស្តីពីការដាក់អោយអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០០៦/១៤ គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្ដីពី

## ការដាក់ឱ្យអនុវត្តទិដ្ឋានុប្បវត្តិប្រព័ន្ធមូលបត្រកម្មសិទ្ធិ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
Phone: 855-23-885-611 Fax: 855-23-885-6[illegible]
E-mail: info@secc.gov.kh

- បានឃើញប្រកាសលេខ ០០៤/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- បានឃើញប្រកាសលេខ ០០១/១២ ស្នន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំការពិនិត្យ វិសោធនកម្ម និងអនុម័ត លើវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសនេះ ត្រូវជំនួសប្រកាសលេខ ០០៤/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងប្រកាសលេខ ០០១/១២ ស្នន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..០០៦/១៥...

ស្ដីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

# វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានាដែលចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា ផ.ម.ក.) អនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងវិធាននេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

-បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ សំដៅដល់បុគ្គលដែលមានបំណងធ្វើសំណើចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ដែលមិនធ្លាប់បានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-បុគ្គលចុះបញ្ជីលក់មូលបត្រសំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយបានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ សំដៅដល់ភាគហ៊ុនិក និងបុគ្គលពាក់ព័ន្ធពិសេសនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេរបស់បុគ្គលស្នើសុំចុះបញ្ជីនេះ។ ក្នុងករណីនេះ ភាគហ៊ុនដែលកាន់កាប់ក្នុងគោលបំណងវិនិយោគជាកញ្ចប់ដោយវិនិយោគិនស្ថាប័ន ត្រូវបានដកចេញពីការគណនាចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ។

**-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់** សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ៣០ (សាមសិប) ភាគរយ ឡើងទៅ នៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

**-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ** សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ ឡើងទៅនៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

**-ភាគហ៊ុនិកយុទ្ធសាស្ត្រ** (Strategic Shareholders) សំដៅដល់ភាគហ៊ុនិកដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់នៃបុគ្គលចុះបញ្ជីលក់មូលបត្រ និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលទាំងនេះ។

**-មូលធនភាគហ៊ុនិក** (Shareholders Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

## ជំពូកទី ២
## លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

### ប្រការ ៣.- ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ជ.ម.ក.។

### ប្រការ ៤.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម មក ជ.ម.ក. ÷

១- ព័ត៌មានទូទៅ÷

ក- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង។

ខ- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

គ- កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ឃ- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ង- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២-ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ÷ អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣-ព័ត៌មានអំពីភាគហ៊ុនិក÷ អត្តសញ្ញាណភាគហ៊ុនិក។

៤-ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ខ- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។

គ- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

ឃ-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥-ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក-ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច។

ខ-ព័ត៌មានអំពីហានិភ័យ។

៦-ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧-ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

## ប្រការ ៥.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី

ផ.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

ករណី ផ.ម.ក. បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ផ.ម.ក. ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រអាចស្នើសុំការបំភ្លឺពី ផ.ម.ក.។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក គ.ម.ក. ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។

## ប្រការ ៦.- ការដាក់ផ្ញើមូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលទទួលបានការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រត្រូវដាក់ផ្ញើមូលបត្រដែលមានស្រាប់នៅប្រតិបត្តិកររក្សាទុកមូលបត្រ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមុនដំណើរការនៃការកំណត់ថ្លៃលក់មូលបត្រ។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

### ប្រការ ៧.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ៨.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

ឃ- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយ ដូចខាងក្រោម÷

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (Positive Operating Cashflow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

### ប្រការ ១២.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ តាមគំរូដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

### ប្រការ ១៣.- ការមិនសងត្រលប់នៅវិញនូវឯកសារពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រវិញនោះទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវដកទៅវិញក៏ដោយ។

## ជំពូកទី ៤
## លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

### ប្រការ ១៤.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

ផ.ម.ក ត្រូវដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនូវមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.÷

១-បុគ្គលចុះបញ្ជីលក់មូលបត្រមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយក្នុងអំឡុងពេល ៣ (បី) ខែ បន្ទាប់ពីកាលវសានដែលកំណត់ដោយ គ.ម.ក.។

២-យោបល់របស់សវនករនៅក្នុងរបាយការណ៍សវនកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ មានយោបល់ជំទាស់ ឬបដិសេធ សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ។

៣-របាយការណ៍ប្រចាំឆ្នាំបានបង្ហាញថា មូលធនភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្របានថយចុះក្នុងរយៈពេល ២ (ពីរ) ឆ្នាំជាប់គ្នា ច្រើនជាង ៥០ (ហាសិប) ភាគរយ។

៤-បុគ្គលចុះបញ្ជីលក់មូលបត្របានបំពានលើកាតព្វកិច្ចផ្ដល់ព័ត៌មានជាញឹកញាប់។

៥-បុគ្គលចុះបញ្ជីលក់មូលបត្រមិនអាចទូទាត់ជាស្ថាពរលើផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ ឬប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៦-បុគ្គលចុះបញ្ជីលក់មូលបត្រស្ថិតក្រោមករណីណាមួយនៃមូលហេតុរំលាយ ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវបានដាក់កំហិតក្នុងការផ្ទេរកម្មសិទ្ធិភាគហ៊ុន។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវបានអនុវត្តនោះទេ ចំពោះករណីដែលការដាក់កំហិតត្រូវបានចាត់ទុកថាមិនប៉ះពាល់ដល់ ការជួញដូរនៅលើទីផ្សារ ពីព្រោះការដាក់កំហិតនេះត្រូវធ្វើឡើងដោយច្បាប់ផ្សេងទៀតដែលមិន ពាក់ព័ន្ធដល់វិស័យមូលបត្រ។

## ប្រការ ១៥.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រដែលដក ចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

នៅពេលដកចេញពីបញ្ជីនូវមូលបត្រចុះបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ ផ.ម.ក. ត្រូវផ្សព្វផ្សាយ ជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្រដែលពាក់ព័ន្ធ។

ករណីដកចេញពីបញ្ជីនូវមូលបត្រណាមួយ ផ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្រ នោះ សម្រាប់រយៈពេល ១០ (ដប់) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

# ជំពូកទី ៥
# ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

## ប្រការ ១៦.- ភាតព្វកិច្ច និងនីតិវិធីផ្តល់ព័ត៌មាន

បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ជូន ផ.ម.ក. ឱ្យទាន់ពេលវេលានូវឯកសារផ្តល់ព័ត៌មានជាប្រចាំ និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ១៧.- កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យា ដូចខាងក្រោម÷

១. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរ ភាគហ៊ុន ដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែដំបូង នៃ រយៈពេល ១ (មួយ) ឆ្នាំ។ សម្រាប់រយៈពេលនៅសល់ ៦ (ប្រាំមួយ) ខែទៀត ភាគហ៊ុនិកនេះ អាច ធ្វើការលក់ភាគហ៊ុនរបស់ខ្លួនក្នុងកម្រិតអតិបរមា ៥០ (ហាសិប) ភាគរយ នៃភាគហ៊ុនដែលខ្លួន កាន់កាប់។

២.ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ និងភាគហ៊ុនិកយុទ្ធសាស្ត្រ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ ។

កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុនដូចមានចែងក្នុងកថាខណ្ឌទី១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

## ប្រការ ១៨.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី

ផ.ម.ក អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម÷

១-ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយនៃប្រការ ១៤ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្រមិនទាន់បានអនុវត្ត។

៣-ករណីមានការបំបែក ឬការបង្រួមមូលបត្រកម្មសិទ្ធិ ឬតាមសំណើរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្រ ស្របតាមកថាខណ្ឌទី ១ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច លើកលែងតែមានការសម្រេចបន្ថែមពីអគ្គនាយកនៃ គ.ម.ក.។

## ប្រការ ១៩.- ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម ត្រូវអនុវត្តនីតិវិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដូចមានចែងក្នុងវិធាននេះ។

## ប្រការ ២០.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ករណីមានការកែប្រែឈ្មោះបុគ្គលចុះបញ្ជីលក់មូលបត្រ តម្លៃចារឹករបស់មូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ ឬចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបំពេញនីតិវិធីកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

## ប្រការ ២១.- ការផ្លាស់ប្តូរទីផ្សារចុះបញ្ជី

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងផ្លាស់ប្តូរទីផ្សារចុះបញ្ជីពីទីផ្សារកំណើន ទៅទីផ្សារគោលត្រូវបំពេញតាមលក្ខខណ្ឌចុះបញ្ជីនៃទីផ្សារដែលបុគ្គលចុះបញ្ជីមានបំណងផ្ទេរទៅ និងត្រូវដាក់ពាក្យស្នើសុំផ្ទេរទីផ្សារមកកាន់ ផ.ម.ក ។

## ប្រការ ២២.- ការជូនដំណឹងអំពីការក្លែងបន្លំផ្ទេរមូលបត្រ

ករណីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមក គ.ម.ក. អំពីករណីមានការក្លែងបន្លំក្នុងការផ្ទេរមូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងភ្លាមមក ផ.ម.ក.។ ការជូនដំណឹងមក ផ.ម.ក. នេះ អាចធ្វើឡើងតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

# ជំពូកទី ៦
# ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

## ប្រការ ២៣.- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវបង់ថ្លៃសេវា ផ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ទីផ្សារគោល និង ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ទីផ្សារកំណើន ។

## ប្រការ ២៤.- ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០៣០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០២៥% |
| ពី | ២០០.០០០.០០០.០០១៛ | ដល់ | ៤០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ៤០០.០០០.០០០.០០០៛ | ០,០១០% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃអប្បបរមា) ឬ ចំនួន ០,០២៥ (សូន្យក្បៀសសូន្យម្ភៃប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដោយយកចំនួនណាមួយដែលធំជាងគេ។

### ប្រការ ២៥.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ពី ០៛ ដល់ ១២.០០០.០០០.០០០៛ | ៣.០០០.០០០៛ |
| ពី ១២.០០០.០០០.០០១៛ ដល់ ៤០.០០០.០០០.០០០៛ | ០,០២០% |
| ពី ៤០.០០០.០០០.០០១៛ ដល់ ២០០.០០០.០០០.០០០៛ | ០,០១៥% |
| លើសពី ២០០.០០០.០០០.០០០៛ | ០,០០៥% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃសេវាប្រចាំឆ្នាំអប្បបរមា) ឬ ចំនួន ០,០១៥ (សូន្យក្បៀសសូន្យដប់ប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយដែលធំជាងគេ។

* * *